- ភារិយ គុ. (<ភារ+ឥយ)មានទម្ងន់ក្រៃពេក; វិ. **អតិភារោ យស្ស អត្ថីតិ>អតិភារិយំ** ; គួរនូវភារៈដ៏ក្រៃលែង; វិ. **អតិភារំ អរហតីតិ> អតិភារិយំ** ។ - មញ្ញេយ្យ កិ. គប្បីមើលងាយ ។ - មធុរ គុ. (<មធុ+រ) មានទឹកឃ្មុំដ៏ក្រៃលែង, មានរសឆ្ងាញ់ដ៏ក្រៃលែង, មានរសផ្អែមដ៏ក្រៃលែង; វិ. **អតិមធុ យស្ស អត្ថីតិ > អតិមធុរំ** ។ . មាបេតិ កិ. រមែងបំផ្លាញ, សម្លាប់ ។ - មុខរ គុ. (<មុខ+រ) មានមាត់ក្រៃពេក, មានមាត់រឹង (និយាយច្រើន); វិ.ដូច« **អតិមុខរ** » ។ - មុខរតា ឥ. ភាវៈនៃ...ជា...មានមាត់រឹងក្រៃពេក ។ - រិត្ត គុ. (<អតិ+រិច+ត) ដែលសូន្យ, ទទេ, ជារបស់សល់ ។ - រោចតិ កិ. (<រុច+អ+តិ.វ.) រុងរឿងក្រៃលែង, រុងរឿងកន្លង ។ - វត្តតិ កិ. (<វត>វត្ត+អ+តិ.វ.) ប្រព្រឹត្តកន្លង ។ - វស គុ. មានអំណាចក្រៃលែង ។ - វាក្យ នថុំ. (<វច+ណ្យ) ពាក្យដែលបុគ្គលគប្បីពោលកន្លង; វិ. **អតិវត្តព្វន្តិ > អតិវាក្យំ** ។ - វិជ្ឈតិ កិ. (<វិធ+យ+តិ.វ.) ចាក់ធ្លុះកន្លង, ត្រាស់ដឹង ។ - វិត្ថារ ថុំ. (<វិ+ថរ+ណ) សេចក្តីពិស្តារក្រៃពេក, ទូលាយណាស់ ។ - វេគ ថុំ. ការលឿនទៅក្រៃពេក, ការស្ទុះទៅក្រៃពេក, កម្លាំងជាគ្រឿងលឿនទៅក្រៃពេក, ការប្រញាប់ប្រញាល់ពេក ។ - វេលា ឥ. វេលាកន្លង, ប្រព្រឹត្តកន្លងនូវវេលា, ប្រព្រឹត្តកន្លងនូវច្រាំង, ប្រព្រឹត្តកន្លងនូវដែន ។ - សណ្ហ គុ. ល្អិតក្រៃពេក, ឆ្មារក្រៃពេក ។ -សម្ផាធ គុ. ចង្អៀតក្រៃពេក, ណាន់ណាប់ក្រៃពេក ។ - សយត្ត ថុំ.

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីល្អក្រៃពេក; គុ. ដែលមានប្រយោជន៍ដ៏ប្រសើរ ។ - **សារ** ចុំ. រោគញាំងឈាមឱ្យស្ទុះទៅក្រៃពេក (រោគចុះឈាម, រោគមួល); វិ. **អតិសារេតិ លោហិតន្តិ> អតិសារោ** ។ - **សាហសិក** គុ. (<អតិសាហស+ណិក) កម្មដែលបុគ្គលធ្វើដោយរហ័សពេក (-ដោយរួសរាន់ពេក, -ប្រញាប់ប្រញាល់ពេក, -ក្លាហានពេក); វិ. **អតិសាហសេន កតំ> អតិសាហសិកំ** ។ - **សិនេហ** ចុំ. សេចក្ដីស្នេហាដ៏ក្រៃលែង, សេចក្ដីស្រឡាញ់ពេក (<អតិ+សិនិហ+ណ); វិ. **អតិសិនេហនំ > អតិសិនេហោ** ។ - **សុខុម** គុ. ល្អិតក្រៃពេក, សុខុមក្រៃពេក ។ - **សុខុមាល** គុ. ល្អិត ទន់ក្រៃពេក, ដែលចំរើនដោយសេចក្ដីសុខក្រៃពេក, ដែលចំរើនដោយសេចក្ដីសុខក្រៃពេក, ជាកុមារតែងសុខក្រៃពេក (ជាវេវចនៈនៃសុកុមារ) ។

**អតិក្កន្ត** គុ. [ អតិ+កម+ត ] ឈានកន្លងហើយ, កន្លងទៅហើយ ។ - **មត្ត** គុ. គ្រាន់តែកន្លងហើយ ។

**អតិត្ត** គុ. [ ន+តិស ឬតប+ត ] មិនឆ្អែតហើយ, មិនស្កប់ស្កល់ហើយ ។

**អតិត្ថ** គុ. [ ន+តិត្ថ ] មិនមែនលទ្ធិដូចជាកំពង់ជាទីឆ្លង, មិនមែនជាកំពង់ (តិត្ថ<តរ+ថ); វិ. **តរន្តិ ឯត្ថាតិ> តិត្ថំ, ន តិត្ថំ > អតិត្ថំ** ។

**អតិថិ** ចុំ. [ អត>អតិ+ថិ ] អ្នកទើបមកដល់, អ្នកមកដល់កាន់ផ្ទះ(ភ្ញៀវ) ។

**អតិន្តចិត្ត** គុ. [ អតិន្ត+ចិត្ត ] មានចិត្តមិនទទឹកហើយ, មានចិត្តមិនជ្រួតជ្រាបហើយ (អតិន្ត<ន+តិម+ត); វិ. **អតិន្តំ ចិត្តំ យស្ស សោ > អតិន្តចិត្តោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អតិរេក** គុ. [ អតិ+ឯក+វ.អា.] មួយដ៏ក្រៃលែង ឬដ៏ក្រៃលែងជាងមួយ (ក្រៃលែង, ច្រើន) ។ - **ឧដ្ឋានសម្បន្ន** គុ. ដល់ព្រមដល់បណ្ណាការសម្រាប់ឡើងដ៏ច្រើន, បរិបូណ៌ដោយសួយ (អាករ) ដ៏ច្រើន ។ - **តរ** គុ. ដ៏ច្រើនជាង, ដ៏ក្រៃលែងជាង, ដ៏ច្រើនដ៏វិសេស ។ - **មល** គុ. មានមន្ទិលដ៏ក្រៃលែង, ជាមន្ទិលដ៏ក្រៃលែង ។ - **លាភយសគ្គប្បត្ត** គុ. ដល់ហើយនូវលាភនិងយសដ៏ប្រសើរក្រៃលែង, មានលាភនិងយសដ៏ប្រសើរក្រៃលែងដល់ហើយ ។

**អតីត** គុ. [ អតិ+ឥ+ត ] ដែលប្រព្រឹត្តកន្លងហើយ, កន្លងទៅហើយ ។ - **ទិវស** ពុំ. ឬ នពុំ. ថ្ងៃដែលកន្លងទៅហើយ ។ - **វត្ថុ** នពុំ. រឿងដែលកន្លងទៅហើយ ។

**អតុច្ឆហត្ថ** គុ. [ អតុច្ឆ+ហត្ថ ] មានដៃមិនទទេ; វិ. **អតុច្ឆា ហត្ថា យេសំ តេ > អតុច្ឆហត្ថា** ។

**អតេកិច្ឆភាវ** ពុំ. [ អតេកិច្ឆ+ភាវ ] ភាវៈនៃ...ជា...មិនមានកិ.រក្សាបាន (ភាវៈនៃ...ជា...គឺអ្នកណាមួយមិនគប្បីរក្សាបាន, -មិនគប្បីកែបាន); វិ. **នត្ថិ តេកិច្ឆំ អស្សាតិ > អតេកិច្ឆោ, តស្ស ភាវោ > អតេកិច្ឆភាវោ** ។

**អត្ត** ពុំ. [ អទ+ត ] (សភាវៈ) ស៊ី ឬរងនូវសុខនិងទុក្ខ (ខ្លួន, ចិត្ត); វិ. **អទតិ សុខទុក្ខំ អនុភវតីតិ > អត្តា** ។ - **គុត្ត** គុ. មានខ្លួនគ្រប់គ្រងហើយ, ដែលគ្រប់គ្រងនូវខ្លួន ។ - **ឃញ្ញ** នពុំ. (<ហន>ឃញ្ញ+

Websites: WatKhemaraRatanaram.org or WatKhmers.org

ណ) កិ.សម្លាប់នូវខ្លួន ។ - ឃាត ចុំ. កិ.សម្លាប់នូវខ្លួន ។ - ទណ្ឌ គុ. មានអាជ្ញាក្នុងខ្លួន, មានអាជ្ញាកើតអំពីខ្លួន, មានអាជ្ញាអាស្រ័យនូវខ្លួន ។ - ទត្ថ ចុំ. (<អត្ត+ អត្ថ, ចុះទ.អា.) ប្រយោជន៍របស់ខ្លួន ។ - ទន្ត គុ. (<ទម+ត) មានខ្លួនទូន្មានហើយ; ដែលទូន្មានហើយនូវខ្លួន ។ - ទមន នចុំ. (<ទម+ យុ) កិ.ទូន្មាននូវខ្លួន ។ - ទុតិយ គុ. មានខ្លួនជាទីពីរ ឬជាគំរប់ពីរ ។ - បច្ចក្ខ គុ. (<បតិ+ឥក្ខ+ណ ឬអ) ដែលជាក់ច្បាស់ចំពោះខ្លួន, ដែលឃើញចំពោះខ្លួន, ប្រចក្សចំពោះខ្លួន, ប្រាកដចំពោះខ្លួន ។ -បញ្ចទសម គុ. មានខ្លួនជាគំរប់ ១៥ ។ - ភរ ចុំ. (<ភរ+អ) អ្នកចិញ្ចឹមនូវខ្លួន ។ - មន គុ. មានចិត្តជារបស់នៃខ្លួន ។ - វត្តវណ្ណនា ឥ. កថាជាគ្រឿងពណ៌នានូវសេចក្ដីនៃអត្តវត្ត ។ - សម្ភវ គុ. មានខ្លួនជាដែនកើតព្រម (<សំ+ ភូ+អ); វិ. **សម្ភវតិ អនេនាតិ > សម្ភវោ, អត្តា សម្ភវោ យស្ស សោ > អត្តសម្ភវោ** ។ ជាដែនកើតព្រមអំពីខ្លួន ។ -ហេតុ ចុំ. ហេតុនៃខ្លួន; គុ. មានខ្លួនជាហេតុ ។ - អនុយោគ ចុំ. កិ.ប្រកបតាមនូវខ្លួន, ព្យាយាមជាគ្រឿងប្រកបតាមនូវខ្លួន ។

**អត្តភាវ** ចុំ. [ អត្ត+ភាវ ] ភាវៈនៃខ្លួន, ភាពនៃខ្លួន, អត្តភាព ។ - គេហ នចុំ. ផ្ទះគឺអត្តភាព ។ - នាវា ឥ. ទូកគឺអត្តភាព ។ - បដិពទ្ធ គុ. ដែលជាប់ចំពោះដោយអត្តភាព ។ - មណ្ឌន នចុំ. កិ.ប្រដាប់នូវអត្តភាព, កិ.តែងនូវអត្តភាព ។ - សង្ខាត គុ. ពោលគឺអត្តភាព ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អត្រជ** ចុំ. [ អត្ត>អត្រ+ជាត, ជាត>ជ ] សត្វដែលកើតអំពីខ្លួន (កូន); វ. **អត្តនា ជាតោ > អត្រជោ** ។

**អត្ថ** ចុំ. [ អរ>អត+ថ ] អាការៈជាគ្រឿងប្រព្រឹត្តទៅ (ទ្រព្យ, សម្បត្តិ, សេចក្ដីចំរើន, ប្រយោជន៍); វ. **អរន្តិ បវត្តន្តិ ឯតេនាតិ > អត្ថោ** ។ (អត្ថ<អស>អត+ថ) សភាវៈកើតតាមសមគួរដល់ស័ព្ទ (សេចក្ដី, សេចក្ដីអធិប្បាយ); វ. **សទ្ធានុរូបំ អសតិ ភវតីតិ > អត្ថោ** ។ **-កាម** គុ. ដែលប្រាថ្នានូវប្រយោជន៍ ។ **-កុសល** គុ. ដែលឈ្លាសក្នុងសេចក្ដី ។ **-ទស្សី** ចុំ. អ្នកឃើញនូវប្រយោជន៍ (នាមរបស់ព្រះពុទ្ធមួយអង្គហៅថាអត្ថទស្សី) ។ **-ធម្មានុសាសក** ចុំ. (<ធម្ម+អនុ+សាស+ណ្វុ) អ្នកប្រៀនប្រដៅនូវអត្ថនិងធម៌ ។ **-និស្សិត** គុ. (<និ+សិ+ត) ដែលអាស្រ័យនូវប្រយោជន៍ ។ **-បទ** នចុំ. បទជាគ្រឿងសំដែងនូវសេចក្ដី, បទនៃសេចក្ដី ។ **-បុរេក្ខារតា** ឥ. ភាវៈនៃ...ជាអ្នកធ្វើនូវប្រយោជន៍ក្នុងខាងមុខ (**បុរេក្ខារ**<បុរេ+ករ, ករ>ខារ+ណ) ។ **-ភញ្ជនក** គុ. (<ភញ្ជ+យុ+ក_ស.) ដែលបំបាក់នូវប្រយោជន៍ ។ **-ធម្មុបនិស្សិត** គុ. (<អត្ថធម្ម+ឧប+និ+សិ+ត) ចូលទៅអាស្រ័យហើយនូវអត្ថនិងធម៌, គឺអត្ថនិងធម៌ចូលទៅអាស្រ័យហើយ ។ **-វស** ចុំ. អំណាចនៃប្រយោជន៍, -នៃសេចក្ដី ។ **-វិញ្ញាបនី** ឥ. វាចាជាហេតុញុំាងបុគ្គលឱ្យដឹងច្បាស់នូវសេចក្ដី ។ **-សាធក** ចុំ. អ្នកញុំាងប្រយោជន៍ឱ្យសម្រេច, អ្នកសម្រេចនូវប្រ.

Websites: WatKhemaraRatanaram.org or WatKhmers.org

យោជន៍ (<សាធ(១)+ណ្យ); វិ. អត្ថំ សាធេតីតិ > អត្ថសាធកោ ។

**អត្ថានត្ថ** បុំ. [ អត្ថ+អនត្ថ ] ប្រយោជន៍និងមិនមែនជាប្រយោជន៍, សេចក្ដីចម្រើននិងសេចក្ដីវិនាស ។ -ជាននក បុំ. អ្នកដឹងនូវប្រយោជន៍និងមិនមែនជាប្រយោជន៍ (ជាននក<ញា>ជា+យុ, យុ>អាននក) ។

**អត្ថង្គមិត** ត្រ. [ អត្ថំ+គម+ឥ+ត ] ដែលដល់ហើយនូវកិ.តាំងនៅមិនបាន, អស្តង្គត; (អត្ថ<ន+ថា+អ) ។ -កាលេ បុំ. កាលនៃព្រះអាទិត្យដល់ហើយនូវកិ.តាំងនៅមិនបាន, កាលនៃព្រះអាទិត្យអស្តង្គតហើយ ។

**អត្ថង្គមេតិ** កិ. [ អត្ថំ+គម+អ, អ>ឯ+តិ.វ.] រមែងដល់នូវកិ.តាំងនៅមិនបាន, រមែងដល់នូវកិ.សាបសូន្យ ។

**អត្ថត** ត្រ. [ អា+ថរ+ត ] ដែល...ក្រាលហើយ, -លាហើយ, -ត្រដាងហើយ, -តម្រៀបហើយ ។ -ផលក នបុំ. ផែនក្ដារ ឬបន្ទះក្ដារដែល...ក្រាលហើយ; វិ. អត្ថរិយិត្ថាតិ > អត្ថតោ ។

**អត្ថរណ** នបុំ. [ អា+ថរ+យុ ] វត្ថុសម្រាប់ក្រាល (កម្រាល); វិ. អត្ថរតិ ឯតេនាតិ > អត្ថរណំ ។ ទីជាទីក្រាល; វិ. អត្ថរតិ ឯត្ថាតិ >អត្ថរណំ ។ កិ.ក្រាល; វិ. អត្ថរិយតេតិ > អត្ថរណំ ។ -ដ្ឋាន នបុំ. ទីជាទីក្រាល ។ -បាវុរណនិសីទន នបុំ. វត្ថុសម្រាប់ក្រាលនិងសម្រាប់ដណ្ដប់និងសម្រាប់អង្គុយ (កម្រាលនិងភួយនិងសំពត់និសីទនៈ) ។

---

(១) សធ+ណ ក៏បាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អត្ថរន្ទិ កិ. [ អា+ថរ+អ+អន្ទិ_វ.] ក្រាល, លាត, លា, ត្រដាង ។

អត្ថរសិ កិ. [ អា+ថរ+អ+សិ_វ.] ក្រាល, ... ។

អត្ថរាបេត្វា អ. [ អា+ថរ+ណាបេ+ត្វា ] ញ៉ាំង...ឱ្យក្រាលហើយ, ... ។

អត្ថរិត្វា អ. [ អា+ថរ+ឥ_អា.+ត្វា ] ក្រាលហើយ... ។

អត្ថរិតុកាម គុ. [ អត្ថរិតុំ+កាម ] អ្នកប្រាថ្នាដើម្បីក្រាល, ចង់ដើម្បីក្រាល, មានប្រាថ្នាដើម្បីក្រាល ។

អត្ថវណ្ណនា ឥ. [ អត្ថ+វណ្ណ+យុ+អា_ឥ.] កថាជាគ្រឿងពណ៌នានូវសេចក្តី; វិ. **អត្ថំ វណ្ណេតិ ឯតាយាតិ > អត្ថវណ្ណនា** ។

អត្ថិក គុ. [ អត្ថ+ណិក ] មានប្រយោជន៍, មានសេចក្តីត្រូវការ; វិ. **អត្ថោ យស្ស អត្ថីតិ> អត្ថិកោ** ។ ប្រកបដោយប្រយោជន៍; វិ. **អត្ថេន និយុត្តោ > អត្ថិកោ** ។

អត្ថិ កិ. [ អស+អ+តិ, តិ>ត្ថិ ] រមែងមាន, រមែងជា... ។ - **តា** ឥ. **ភាវៈនៃ** ...ជា...មាននៅ ។ - **ភាវ** បុ. ភាវៈនៃ...ជា...មាន ។ - **ភាវកាល** បុ. កាលនៃភាវៈនៃ...ជា...មាននៅ, កាលគឺភាវៈនៃ...ជា...មាននៅ ។

អត្ថុប្បត្តិ ឥ. [ អត្ថ+ឧប្បត្តិ ] កិ.កើតឡើងនៃសេចក្តី, ហេតុជាគ្រឿងកើតឡើងនៃសេចក្តី (ឧប្បត្តិ<ឧ+បទ+តិ); វិ. **អត្ថស្ស ឧប្បត្តិ > អត្ថុប្បត្តិ** ។

អថ និ. ( ប្រាប់កាល )=គ្រានោះ, លំដាប់នោះ, ក្នុងកាលនោះ ។ និ.(ប្រាប់សេចក្តីជញ្ជីង ឬស្មាន)=បើ, បើជា, ... ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អថាវរត្ថ** ចុំ. [ អថាវរ+អត្ថ ] សេចក្ដីថាមិនមាំមួន, -មិនឋិតថេរ ។

**អថោ** និ. មួយទៀត, មួយវិញទៀត, មយ៉ាងទៀត... ។

**អទណ្ឌ** គុ. [ ន+ទណ្ឌ ] មានអាជ្ញាមិនមាន, មិនមានអាជ្ញា; វិ. **នត្ថិ ទណ្ឌោ អស្សាតិ > អទណ្ឌោ** ។

**អទលិទ្ទ** គុ. [ ន+ទលិទ្ទ ] មិនមែនអ្នកដល់នូវភាពនៃខ្លួនជាបុគ្គលទុគ៌ត, មិនមែនអ្នកកំសត់, មិនមែនអ្នកទាល់ក្រ (**ទលិទ្ទ**<ទល+ឥទ្ទ); វិ. **ទលតិ ទុគ្គតភាវំ គច្ឆតីតិ > ទលិទ្ទោ, ន ទលិទ្ទោ > អទលិទ្ទោ** ។

**អទស្សន** នចុំ. [ ន+ទិស+យុ ] ទីជាទីមិនឃើញ, កិ.មិនឃើញ, កិ.មិនសម្ដែង, កិ.មិនបង្ហាញ ។

**អទហនកាល** ចុំ. [ អទហន+កាល ] កាលនៃកិ.មិនឆេះ, កាលជាទីមិនឆេះ ។

**អទាតុកាម** គុ. [ អទាតុំ+កាម ឬន+ទាតុកាម ] ជាអ្នកចង់ដើម្បីមិនឱ្យ, មិនចង់ដើម្បីឱ្យ ។

**អទានសីល** គុ. [ អទាន+សីល ] មានកិ.មិនឱ្យជាប្រក្រតី; វិ. **អទានំ សីលមស្សាតិ > អទានសីលោ** ។

**អទិដ្ឋ** គុ. [ ន+ទិស+ត ] គឺ...មិនឃើញហើយ ។ - **ធម្ម** គុ. មានធម៌គឺ...មិនឃើញហើយ ។ - **បុព្វក** គុ. អ្នកគឺ...មិនធ្លាប់ឃើញហើយ ។ - **បុព្វមរណ** គុ. មានសេចក្ដីស្លាប់គឺ...មិនធ្លាប់ឃើញហើយ ។ -**បុព្វសហាយក** ចុំ. ជាសំឡាញ់គឺ... មិនឃើញហើយក្នុងកាល

Websites: WatKhemaraRatanaram.org or WatKhmers.org

មុន, ជាសំឡាញ់គឺ...មិនធ្លាប់ឃើញហើយក្នុងកាលមុន ។ - សច្ច គុ. មានសច្ចៈមិនទាន់ឃើញហើយ ។

**អទិត្ត** គុ. [ ន+ទិប+ត ] មិនក្តៅហើយ, មិនរុងរឿងហើយ ។

**អទិន្នក** គុ. [ ន+ទា+ត, ត>ឥន្ន+ក.ស.] (វត្ថុ) ដែលគេមិនឱ្យហើយ ។

**អទិន្ន** គុ. [ ន+ទា+ត ] ដែល...មិនឱ្យហើយ ។ - ភាវ បុំ. ភាវៈនៃ...ជា... គឺ...មិនឱ្យហើយ ។

**អទិស្សមានរូប** គុ. [ អទិស្សមាន+រូប ] មានរូបគឺបុគ្គលកាលមិនឃើញ, មានរូបកាលមិនប្រាកដ; វិ. **អទិស្សមានំ រូបំ យស្ស សោ> អទិស្សមានរូបោ** ។

**អទុដ្ឋ** គុ. [ ន+ទុស+ត ] គឺ...មិនប្រទូស្តហើយ, គឺទោសមិនប្រទូស្តហើយ ។

**អទុស្សន្ត** គុ. [ ន+ទុស+អន្ត ] កាលមិនប្រទូស្ត ។

**អទេន្ត** គុ. [ ន+ទា+អន្ត ] កាលមិនឱ្យ ។

**អទេសេន្ត** គុ. [ ន+ទិស+ណេ+អន្ត ] កាលមិនសំដែង ។

**អទ្ទស** កិ. [ អ+ទិស+អ+អា.ហី.(១) ] បានឃើញហើយ ។

**អទ្ទសា** កិ. [ អ+ទិស+អ+អា.ហី.] បានឃើញហើយ ។

**អទ្ទក្ខ** កិ. [ អ+ទិស, ទិស>ទក្ខ+អ+អា.ហី.(២) ] បានឃើញហើយ ។

**អទ្ទក្ខិ** កិ. [ អ+ទិស, ទិស>ទក្ខ+អ+ឦ.អជ្ជ.] បានឃើញហើយ ។

---

(១) (២) អា.ហី>អ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អទ្ទុពន្ធន** នបុំ.[ អទ្ទុ+ពន្ធន ] វត្ថុជាគ្រឿងចងពីខ្មោះ, ចំណងពីខ្មោះ (អទ្ទុ< អទ+ទុ=វត្ថុសម្រាប់រងនូវទុក្ខនៃជន (ខ្មោះ); វិ. ទុក្ខំ អទតិ អនុភវតិ ឯតេនាតិ > អទ្ទុ; ពន្ធតិ ឯតេនាតិ > ពន្ធនំ, អទ្ទុ ឯវ ពន្ធនំ > អទ្ទុពន្ធនំ ។

**អទ្ធគូ** គុ. [ អទ្ធ+គម+រូ ] អ្នកដើរក្នុងផ្លូវឆ្ងាយ ឬអ្នកទៅកាន់ផ្លូវឆ្ងាយ (អ្នកដំណើរ); វិ. អទ្ធនិ មគ្គេ គច្ឆតីតិ> អទ្ធគូ, អទ្ធានំ គច្ឆតីតិ វា > អទ្ធគូ ។ -ភាវ បុំ. ភាវៈនៃ...អ្នកដើរទៅកាន់ផ្លូវឆ្ងាយ (ផ្លូវវែង, កាលវែង) ។

**អទ្ធា** និ. ពិត, ដោយពិត, ដោយដាច់ខាត ។ ន., បុំ. ផ្លូវ ឬផ្លូវឆ្ងាយ ។

**អទ្ធានគមន** នបុំ.[ អទ្ធាន+គម+យុ ] កិ.ឬដំណើរទៅកាន់ផ្លូវឆ្ងាយ ។

**អទ្ធិក** បុំ. [ អទ្ធ ឬ អទ្ធាន+ណិក ] អ្នកដើរទៅកាន់ផ្លូវ (អ្នកដំណើរ); វិ. អទ្ធំ មគ្គំ គច្ឆតីតិ> អទ្ធិកោ ។ -មនុស្ស បុំ. មនុស្សអ្នកដើរទៅកាន់ផ្លូវ, មនុស្សអ្នកដំណើរ ។

**អធម្មតេជ** បុំ.[ អធម្ម+តេជ ] តេជៈនៃបុគ្គលអ្នកមានធម៌មិនមាន, តេជៈនៃទោសមិនមែនជាធម៌ ។

**អធម្មិក** គុ. [ ន+ធម្ម+ណិក ] អ្នកមិនប្រព្រឹត្តតាមធម៌; វិ. ន ធម្មេន ចរតីតិ > អធម្មិកោ (១); អ្នកមិនតាំងនៅក្នុងធម៌; វិ. ន ធម្មេ តិដ្ឋតីតិ > អធម្មិកោ (១); អ្នកមិនប្រកបដោយធម៌; វិ. ន

(១) ចងវិគ្គហៈជាបទតទ្ធិតសិន ហើយសឹមចងជាបទសមាសមួយលើកទៀតគួរជាង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ធម្មេន និយុត្តោ>អធម្មិកោ (១) ។ -ភាវ ចុំ. ភាវៈនៃបុគ្គលអ្នក... ។ -រាជ ចុំ. ស្ដេចមិនប្រកបដោយធម៌ ។

អធម្ម គុ. [ ន+ធម្ម ] មិនមែនជាធម៌, មិនមានធម៌ ។

អធិកតរ គុ. [ អធិក+តរ ] ដ៏លើសជាង, ដ៏ក្រៃលែងជាង ។

អធិករណ នចុំ. [ អធិ+ករ+យុ ] ទោសជាតជាគ្រឿងធ្វើក្រៃលែង ឬកិ. ធ្វើដ៏ក្រៃលែង (អធិករណ៍, ជំលោះ); វិ. **អធិករោតិ ឯតេនាតិ > អធិករណំ, អធិកំ វា ករណំ > អធិករណំ** ។ -**ប្បសុត** គុ. អ្នកខ្វល់ខ្វាយក្នុងអធិករណ៍ ។ -**វូបសមនាទិក** គុ. មានកិ.ចូលទៅរំងាប់នូវអធិករណ៍ជាដើម, មានកិ.ញ៉ាំងអធិករណ៍ឱ្យចូលទៅរំងាប់ជាដើម ។

អធិការ ចុំ. [ អធិ+ករ+ណ ] កិ.ធ្វើក្រៃលែង; វិ. **ករណំ>ការោ, អធិកោ ការោ>អធិការោ, អធិករណំ វា>អធិការោ** ។ គុណតីបុគ្គលគប្បីធ្វើក្រៃលែង; វិ. **អធិកាតព្វោតិ > អធិការោ** ។ គុណវិសេសជាគ្រឿងធ្វើក្រៃលែង; វិ. **អធិករោតិ ឯតេនាតិ> អធិការោ** (អធិការ, សេចក្ដីកសាង) ។

អធិគច្ឆតិ កិ. [ អធិ+គម, ម>ច្ឆ+អ+តិ_វ.] រមែងបាន, លុះ, ត្រាស់ដឹង ។

អធិគត គុ. [ អធិ+គម+ត ] គឺ...បានហើយ, -លុះហើយ, -ត្រាស់ដឹងហើយ។ -**វិសេស** គុ. មានគុណវិសេសបានហើយ ។

(១) ចងវិគ្គហៈជាបទតទ្ធិតសិន ហើយសឹមចងជាបទសមាសមួយលើកទៀតគួរជាង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អធិគម** ចុំ. [ អធិ+គម+អ ] កិ.ដល់ក្រៃលែង, បាន, លុះ, ត្រាស់ដឹង ។

**-ឧបាយ** ចុំ. ឧបាយជាគ្រឿងបាន... ។

**អធិចិត្ត** នចុំ. [ អធិ+ចិត្ត ] ចិត្តដ៏ក្រៃលែង, ធម៌អាស្រ័យនូវចិត្តហើយប្រព្រឹត្តទៅ, គុណជាតដែលប្រព្រឹត្តទៅអាស្រ័យនូវសមាធិ ។

**អធិចេតស** គុ. [ អធិចេត+ស ] មានចិត្តដ៏ក្រៃលែង; វិ. **អធិកំ ចេតំ > អធិចេតំ, អធិចេតំ ឯតស្ស អត្ថីតិ > អធិចេតសោ** ។

**អធិដ្ឋាន** នចុំ. [ អធិ+ឋា+យុ ] គុណជាតជាគ្រឿងតាំងទុកនូវចិត្តក្នុងអារម្មណ៍ (សេចក្ដីតាំងចិត្ត, អធិដ្ឋាន); វិ. **អធិដ្ឋាតិ** (១) **ឯតេន អារម្មណោ ចិត្តន្តិ > អធិដ្ឋានំ** ។

**អធិដ្ឋាយ** អ. [ អធិ+ឋា+ត្វា, ត្វា>យ ] អធិដ្ឋានហើយ, តាំងចិត្តហើយ ។

**អធិដ្ឋិត** គុ. [ អធិ+ឋា, ឋា>ដ្ឋិ+ត ] គឺ...អធិដ្ឋានហើយ ។

**អធិប្បញ្ញា** ឥ. [ អធិ +បញ្ញា ] បញ្ញាដ៏ក្រៃលែង, គុណជាតអាស្រ័យនូវបញ្ញាហើយប្រព្រឹត្តទៅ, គុណជាតដែលប្រព្រឹត្តទៅអាស្រ័យនូវបញ្ញា ។

**អធិបតិវស** ចុំ. [ អធិបតិ+វស ] អំណាចនៃ...ជាអធិបតី, -ជាធំក្រៃលែង ។

**អធិបន្ន** គុ. [ អធិ+បទ+ត, ត>អន្ន ] គឺ...គ្របសង្កត់ហើយ ។

**អធិប្បេត** គុ.[ អធិ+ប+ឥ+ត ] គឺ...អធិប្បាយហើយ, -ប្រាថ្នាហើយ, -សំដៅហើយ, -បំណងហើយ; វិ. **អធិប្បយិត្ថ ឥច្ឆិយិត្ថាតិ> អធិប្បេតោ** ។

---

(១) អធិដ្ឋហតិ ក៏បាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អធិមត្ត គុ. [ អធិ+មត្ត ] មានប្រមាណដ៏ក្រៃលែង, មាត្រាថាក្រៃលែង ។

-សិនេហ ចុំ. សេចក្ដីស្រឡាញ់មានប្រមាណដ៏ក្រៃលែង ។

អធិមានិក គុ. [ អធិមាន+ណិក ] អ្នកមានមានះដ៏ក្រៃលែង, អ្នកមានសេចក្ដីប្រកាន់ដ៏ក្រៃលែង; វិ. **អធិមានោ យស្ស អត្ថិ > អធិមានិកោ** ។

អធិមុច្ចិ កិ. [ អធិ+មុច+យ+ឦ-អជ្ជ. ] រួចស្រឡះហើយ, មុជចូលហើយ, ជ្រែកចូលហើយ ។

អធិមុញ្ចិត្វា អ. [ អធិ+មុច+និ-អា+ឥ-អា+ត្វា ] ផុតស្រឡះហើយ, ជ្រែកចូលហើយ ។

អធិមុត្ត គុ. [ អធិ+មុច+ត ] ផុតស្រឡះហើយ, ជឿស៊ប់ហើយ, បង្អោនចិត្តទៅហើយ ។

អធិយស្សុ កិ. [ អធិ+ឥ, ឥ>យ+អ+ស្សុ-ប.] ចូររៀន, ចូរសិក្សា ។

អធិរាជ ចុំ. [ អធិ+រាជ ] ស្ដេចក្រៃលែង, ស្ដេចជាធំ; វិ. **អធិកោ រាជា > អធិរាជា** ។

អធិវចន នចុំ. [ អធិ+វច+យុ ] ពាក្យជាគ្រឿងពោលកំណត់ (ឈ្មោះ) ។ យ៉ាងទៀត សំឡេងជាគ្រឿងដែលជនធ្វើនូវការកំណត់ហើយពោល (ឈ្មោះ); វិ. **ការណំ អធិកាំ កត្វា វុច្ចតិ អនេន សទ្ទេនាតិ > អធិវចនំ** ។

អធិវុត្ថ គុ. [ អធិ+វស+ត ] ដែលនៅអាស្រ័យហើយ, នៅសង្កត់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អធិវាសន** នបុំ. [ អធិ+វស+ណេ+យុ ] កិ.ញ៉ាំងពាក្យឱ្យនៅសង្កត់, ការទទួលនិមន្ត, ការទទួលពាក្យ, សេចក្ដីអត់សង្កត់ ។

**អធិវាសយិត្វា** កិ. [ អធិ+វស+ណយ+ត្វា អជ្ជ. ] ញ៉ាំងពាក្យឱ្យនៅសង្កត់ហើយ, ទទួលហើយ, ទទួលពាក្យហើយ, ទទួលនិមន្តហើយ ។

**អធិវាសិត** គុ. [ អធិ+វស+ណេ+ឥ_អា.+ត ] គឺ...ញ៉ាំងពាក្យឱ្យនៅសង្កត់ហើយ, _អត់សង្កត់ហើយ, _ទទួលហើយ, ... ។

**អធិវាសេត្វា** អ. [ អធិ+វស+ណេ+ត្វា ] ញ៉ាំងពាក្យឱ្យនៅសង្កត់ហើយ, អត់សង្កត់ហើយ, ទទួលហើយ, ... ។

**អធិវុត្ថ** គុ. [ អធិ+វស+ត, អនៃវ>ឧ ] ដែលនៅអាស្រ័យហើយ, ទទួលហើយ ។

**អធិសេស្សតិ** កិ. [ អធិ+សី+អ+ស្សតិ_ភ. ] នឹងដេកសង្កត់, នឹងដេកផ្ដល់ ។

**អធុនាគត** គុ. [ អធុនា+អាគត ] ដែលមកហើយក្នុងកាលឥឡូវនេះ, ដែលមកហើយមិនយូរ, ដែលទើបនឹងមកក្នុងកាលអម្បាញ់មិញ ។

**អធុវ** គុ. [ ន+ធុវ ] មិនទៀង, មិនមែនជាប្ដី ។ _ **សីល** គុ. មានសីលមិនទៀងទាត់ ។

**អធោភាគ** គុ. [ អធោ+ភាគ ] មានចំណែកក្នុងខាងក្រោម; ពុំ. ប្រទេសជាចំណែកក្នុងខាងក្រោម ។

**អធោមុខ** គុ. [ អធោ+មុខ ] មានមុខក្នុងខាងក្រោម, មានមុខចុះក្រោម, ខាងក្រោមនៃមុខ; វិ. **មុខស្ស អធោ > អធោមុខំ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អធោសាខ** គុ. [ អធោ+សាខា ] មានមែកក្នុងខាងក្រោម, ខាងក្រោមនៃមែក ។

**អធោសិរ** គុ.[ អធោ+សិរ ] មានក្បាលក្នុងខាងក្រោម, មានក្បាលចុះក្រោម ។

**អនក្កមន** នបុំ. [ ន>អន+អា, អា>អ+កម+យុ ] កិ.មិនជាន់។ - **ភាវ** បុំ. ភាវៈនៃកិ.មិនជាន់ ។

**អនក្កមិត្វា** អ. [ ន+អា+កម+ឥ.អា.+ត្វា ] មិនជាន់ហើយ ។

**អនក្កោសន** នបុំ. [ ន+អា+កុស+យុ ] កិ.មិនជេរ ។ - **ភាវ** បុំ. ភាវៈនៃកិ. មិនជេរ ។

**អនក្កោសិក** គុ. [ ន+អា+កុស+ណិក ] អ្នកមិនជេរ, អ្នកមានកិ.មិនជេរជាប្រក្រតី ។

**អនក្ខាត** គុ. [ ន+អា+ខា+ត ] ដែល...មិនប្រាប់ហើយ, ដែលអ្នកណាមួយមិនពោលហើយ ។

**អនគរ** នបុំ. [ ន+នគរ ] ទីមិនមែនជានគរ, មិនមែនជាក្រុង ។

**អនគារិយ** គុ.[ ន+អគារិយ ] មានកម្មជាប្រយោជន៍ដល់ផ្ទះមិនមាន(សាសនា)។

**អនគ្ឃ** គុ. [ ន+អគ្ឃ ] មានដំឡៃមិនមាន, មិនមានដំឡៃ, មិនគួរដល់ថ្លៃ, មិនដល់ថ្លៃ, កាត់ថ្លៃមិនបាន ។ - **កាសាយ** នបុំ. សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់មានដំឡៃមិនមាន, -កាត់ដំឡៃមិនបាន ។

**អនង្គណ** គុ. [ ន+អង្គណ ] មានកិលេសដូចជាទួលមិនមាន, មានទួលគឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

កិលេសមិនមាន, មានកិលេសជាគ្រឿងរលីបរលមិនមាន; (មិនមាន
កិលេស) ។

**អនញ្ញាត** គុ. [ ន>អន+អា, អា>អ+ញា, ញា>ញ>ញ្ញ+ត ] គឺ...មិនដឹងហើយ ។

**អនញ្ញមន** គុ. [ អនញ្ញ+មន ] មានចិត្តមិនដទៃ, មានចិត្តមិនតាំងនៅក្នុងទីដទៃ, មានចិត្តមិនរីករាយ; (**អនញ្ញ**<ន+អា+ញា+អ=មិនត្រេកអរ, មិនរីករាយ) ។

**អនញ្ញបោសី** ចុំ. [ ន+អញ្ញបោសី ] អ្នកមិនចិញ្ចឹមនូវបុគ្គលដទៃដោយប្រក្រតី; វិ. **អញ្ញំ បោសេតិ សីលេនាតិ>អញ្ញបោសី, ន អញ្ញបោសី > អនញ្ញបោសី** ។

**អនច្ឆរិយ** នចុំ. [ ន+អច្ឆរិយ ] មិនគួរអស្ចារ្យ, មិនជាអស្ចារ្យ, មិនគួរដើម្បីប្រហារនូវម្រាមដៃ ។

**អនតិក្កមិត្វា** អ. [ ន+អតិ+កម+ឥ_អា.+ត្វា ] មិនឈានកន្លងហើយ, មិនប្រ-ព្រឹត្តកន្លងហើយ ។

**អនតិមានី** គុ. [ ន+អតិមានី ] មិនមែនអ្នកមានមានះដ៏ក្រៃលែង, អ្នកមិនមានសេចក្ដីមើលងាយ; វិ. **អតិមានោ យស្ស អត្ថីតិ > អតិមានី, ន អតិមានី > អនតិមានី** ។

**អនត្ត** គុ. [ ន+អត្ត ] មិនមែនជាខ្លួន, សភាពមិនមែនជាខ្លួន ។ - **មនតា** ឥ. ភាវៈនៃ...ជាអ្នកមានចិត្តមិនមែនជារបស់នៃខ្លួន ។ - **មនធាតុក** គុ. មានធាតុនៃបុគ្គលអ្នកមានចិត្តមិនមែនជារបស់នៃខ្លួន, អ្នកមានចិត្តមិនមែនជារបស់នៃខ្លួនជាធាតុ ។ - **មន** គុ. អ្នកមានចិត្តមិនជារបស់

Websites: WatKhemaraRatanaram.org or WatKhmers.org

នៃខ្លួន, (មានចិត្តអាក្រក់) ។ - លក្ខណ ន‌ថុំ. អនត្តលក្ខណ, ធម្មជាត ជាគ្រឿងកំណត់ថារីធមិទាំងឡាយមិនមែនជារបស់នៃខ្លួន, ធម្មជាត ជាគ្រឿងកំណត់ថាមិនមែនជារបស់នៃខ្លួន ។

**អនត្ថ** គុ. [ ន+អត្ថ ] មិនមែនជាប្រយោជន៍, មិនមែនជាសេចក្ដីចម្រើន, កម្មមានប្រយោជន៍មិនមាន ។ - **កាម** គុ. (<កម+ណ)អ្នកប្រាថ្នានូវ កម្មមិនមែនជាប្រយោជន៍; វិ. **អនត្ថំ ការមេតីតិ > អនត្ថ- ការមោ** ។ - **ការក** ថុំ., នថុំ. (<ករ+ណ្វុ) អ្នកធ្វើនូវកម្មមិនមែនជា ប្រយោជន៍; វិ. **អនត្ថំ ករោតីតិ >អនត្ថការកោ** ។

**អនត្ថង្គត** គុ. [ ន+អត្ថង្គត ] មិនទាន់អស្តង្គតហើយ, មិនទាន់ដល់ហើយនូវកិ. តាំងនៅមិនបាន; (ន+អត្ថំ>អនត្ថំ+គម+ត) ។

**អនត្ថង្គមិត** គុ. [ ន+អត្ថង្គមិត ] ប្រែដូច «អនត្ថង្គត» ។

**អនត្ថនិស្សិត** គុ. [ អនត្ថ+និស្សិត ] អាស្រ័យហើយនូវកម្មមិនមែនជា ប្រយោជន៍, គឺកម្មមិនមែនជាប្រយោជន៍អាស្រ័យហើយ ។

**អនត្ថបទសញ្ហិត** គុ. [ អនត្ថបទ+សញ្ហិត ] ប្រកបហើយដោយបទមិនមែនជា ប្រយោជន៍ ឬមិនមានប្រយោជន៍, ប្រកបហើយដោយបទមិនមែន ជាគ្រឿងសំដែងនូវកម្មមិនមែនជាប្រយោជន៍; ( **សញ្ហិត** <សំ+ ហិ+ត ) ។

**អនត្ថិក** គុ. [ ន+អត្ថិក ] អ្នកមិនមានសេចក្ដីត្រូវការ; វិ. **អត្ថោ យស្ស អត្ថីតិ> អត្ថិកោ, ន អត្ថិកោ> អនត្ថិកោ** ។ - **ភាវ** ថុំ. ភាវៈនៃ...ជាអ្នកមិនមានសេចក្ដីត្រូវការ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនទ្ធនិយ** គុ. [ ន+អទ្ធនិយ ] មិនគួរដល់កាលដ៏យូរអង្វែង, មិនមែនជាហេតុជាទីតាំងនៃកាលដ៏យូរអង្វែង, មិនគួរដល់សេចក្ដីមាំមួន ។ - ឝា ៩. ភារៈនៃកាយជារបស់មិនគួរដល់កាលដ៏យូរអង្វែង, ភារៈនៃកាយជារបស់មិនគួរដល់សេចក្ដីមាំមួន ។

**អននុច្ឆវិក** គុ. [ ន+អនុច្ឆវិក ] មិនប្រព្រឹត្តទៅតាមសម្បុរថ្ងៃ; មិនសមគួរ, មិនត្រូវបែប ។

**អននុញ្ញាត** គុ. [ ន+អនុ+ញា+ត ] គឺ...មិនអនុញ្ញាតហើយ, -មិនយល់តាមហើយ ។ - **កាលេ** ចុំ. កាលនៃ...គឺ...មិនអនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតហើយ ។

**អននុរូប** គុ. [ ន+អនុ>អននុ+រូប ] មានសភាពមិនសមគួរ (មិនត្រូវបែប, មិនត្រូវទំនង); វិ. **ន អនុ** > **អននុ**, **អននុ រូបំ យស្ស តំ** > **អននុរូបំ** ។

**អននុវជ្ជ** គុ. [ ន+អនុវជ្ជ ] មិនមានទោសគឺបុគ្គលគប្បីវៀរតាម, មិនមានទោសគឺបុគ្គលគប្បីវៀររឿយៗ; វិ. **អនុវជ្ជេតព្វោតិ** > **អនុវជ្ជោ, នត្ថិ អនុវជ្ជោ ឯតស្សាតិ** > **អននុវជ្ជោ** ។

**អននុស្សរិត្វា** អ. [ ន+អនុ+សរ+ឥ.អា.+ត្វា ] មិនរឭកតាមហើយ, មិនរឭករឿយៗហើយ, នឹកមិនឃើញហើយ ។

**អនន្វាហតចេតស** គុ. [ អនន្វាហត+ចេតស ] មានចិត្តគឺទោសមិនតាមកំចាត់បង់ហើយ, មានចិត្តគឺទោសមិនតាមបៀតបៀនហើយ, មានចិត្តគឺទោសមិនខ្ទាំងខ្ទប់រឿយៗហើយ, មានចិត្តគឺទោសបៀតបៀន

Websites: WatKhemaraRatanaram.org or WatKhmers.org

ទូទៅរៀយៗមិនមាន (អនន្វាហត<ន+អនុ+អា+ហន+ត) ។

**អនន្តគោចរ** គុ. [ អនន្ត+គោចរ ] មាននិព្វានមិនមានទីបំផុតជាអារម្មណ៍ ឬគោចរ (គោចរ=អារម្មណ៍ជាទីចរទៅ ឬជាទីត្រេចទៅនៃឥន្ទ្រិយ៍); វិ.
**អនន្តំ និព្វានំ គោចរំ យស្ស កំ > អនន្តគោចរំ ។**

**អនន្តរ** គុ. [ ន+អន្តរ ] មានចន្លោះមិនមាន (ជាលំដាប់បន្ទាប់) ។ - **ឥត្ថ** ចុំ. បន្ទប់ ឬល្បែងជាលំដាប់ ។ - **គាថា** ឥ. គាថាជាលំដាប់ ។ - **គេហវាសី** ចុំ. អ្នកនៅក្នុងផ្ទះជាលំដាប់ ។ - **អត្តភាវ** ចុំ. អត្តភាពជាលំដាប់ ។ - **អាសន** នចុំ. អាសនៈមានចន្លោះមិនមាន, អាសនៈជាលំដាប់ ។

**អនន្ធ** គុ. [ ន+អន្ធ ] មិនមែនជាបុគ្គលងងឹត, មិនមែនជាបុគ្គលខ្វាក់ (អន្ធ<អន្ធ+អ); វិ. **អន្ធតីតិ> អន្ធោ, ន អន្ធោ>អនន្ធោ** ។

**អនបគន្តា** អ. [ ន+អប+គម+ត្វា ] មិនទៅប្រាសហើយ, មិនគេចចេញហើយ។

**អនបនីតតា** ឥ. [ អនបនីត+តា ] ភាវៈនៃ...ជា...គឺ...មិននាំប្រាសហើយ ឬមិននាំចេញហើយ (<ន+អប+នី+ត); វិ. **ន អបនីយិត្ថាតិ>**
**អនបនីតោ តស្ស ភាវោ > អនបនីតតា ។**

**អនបលោកិត** គុ. [ ន+អប+លោក ឬលុក+ឥ.អា.+ត ] គឺ...មិនលាហើយ, -មិនប្រាប់ហើយ ។

**អនបេក្ខ** គុ. [ ន+អបេក្ខ ] អ្នកមិនមានសេចក្តីសម្លឹង, អ្នកមិនមានសេចក្តី

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រងើយកន្តើយ, អ្នកមិនមានសេចក្ដីអាឡោះអាល័យ, អ្នកមិនមានសេចក្ដីពិនិត្យ ។ (អបេក្ខ<អប+ឥក្ខ+ណ); វិ. **អបេក្ខនំ > អបេក្ខា, នត្ថិ អបេក្ខា ឯតស្សាតិ> អនបេក្ខោ** ។

**អនប្បក** គុ. [ ន+អប្ប+ក ] មិនមានប្រមាណតិច, មិនតិច(ច្រើន); វិ. **អប្បំ បរិមាណំ អស្សាតិ> អប្បកំ, ន អប្បកំ> អនប្បកំ** ។

**អនភិជ្ឈនកសត្ត** ចុំ. [ អនភិជ្ឈនក+សត្ត ] សត្វអ្នកមិនសម្លឹងចំពោះ ឬមិនសម្លឹងរំពៃ (អនភិជ្ឈនក<ន+អភិ+ឈេ+ណ្វុ, ណ្វុ>អនក) ។

**អនភិជ្ឈា** ឥ. [ ន+អភិ+ឈេ+អ+អា_ឥ.] កិ.មិនសម្លឹងចំពោះ ឬមិនសម្លឹងរំពៃ ។ ធម្មជាតមិនសម្លឹងរំពៃនូវសម្បត្តិនៃជនដទៃ; វិ. **បរសម្បត្តឹ អភិជ្ឈាយតីតិ > អភិជ្ឈា, ន អភិជ្ឈា > អនភិជ្ឈា** ។

**អនភិនន្ទិតា** អ. [ ន+អភិ+នន្ទ+ឥ_អា.+តា ] មិនត្រេកអរចំពោះហើយ ។

**អនភិភូត** គុ. [ ន+អភិ+ភូ+ត ] គឺ...មិនគ្របសង្កត់ហើយ, មិនជិះជាន់ហើយ ។

**អនភិរត** គុ. [ ន+អភិ+រម+ត ] មិនត្រេកអរចំពោះហើយ, (អផ្សុកហើយ); វិ. **ន អភិរមីតិ > អនភិរតោ** ។ -**កាល** ចុំ. កាលនៃ...មិនត្រេកអរចំពោះហើយ ។ -**ភិក្ខុ** ចុំ. ភិក្ខុអ្នកមិនត្រេកអរចំពោះហើយ (ភិក្ខុអ្នកអផ្សុកហើយ) ។

**អនមតគ្គ** គុ. [ ន+អញ្ញាត>អនមត+អគ្គ ] មានទីបំផុតគឺបុគ្គលដឹងហើយមិនមាន, មានទីបំផុតគឺបុគ្គលមិនដឹងហើយ, មានទីបំផុតខាងដើមគឺបុគ្គលមិនដឹងហើយ; វិ. **នត្ថិ អញ្ញាតោ អគ្គោ ឯតស្សាតិ** >

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនមតគ្គោ (សំសារោ)** ។ **- ធម្មទេសនា** ៩. ធម្មទេសនាដែលមកហើយក្នុងអនមតគ្គសូត្រ ។ **- បរិយាយ** ចុ. សេចក្ដីបរិយាយនៃអនមតគ្គសូត្រ (**បរិយាយ**<បរិ+អយ, អយ>អាយ+ណ+យ.អា.); វិ. **បរិយាយនំ > បរិយាយោ** ។

**អនមស្សនភាវ** ចុំ. [ អនមស្សន+ភាវ ] ភាវៈនៃកិ.មិនបង្អោនទៅ, ភាវៈនៃកិ. មិនធ្វើនមស្សការ, ភាវៈគឺកិ.មិនថ្វាយបង្គំ ។

**អនម្ពិល** ៣. [ ន+អម្ពិល ] មានរសជូរមិនមាន, មិនមានរសជូរ (**អម្ពិល**< អម្ព+ឥល) វត្ថុជាគ្រឿងជូរគឺថាជាគ្រឿងធ្វើនូវសំឡេងនៃជន (ជូរ, រសជូរ); វិ. **អម្ពន្តិ សទ្ទំ ករោន្តិ ឯតេនាតិ > អម្ពិលំ, នត្ថិ អម្ពិលំ ឯតស្សាតិ > អនម្ពិលំ** ។

**អនម្ពកាល** ចុំ. [ អនម្ព+កាល ] កាលជាទីយំ, កាលជាទីយំរៀបរាប់ (**អនម្ព-កាល** ក៏មាន) ។

**អនយព្យសន** នចុំ. [ អនយ+ព្យសន ] សេចក្ដីមិនចំរើននិងសេចក្ដីវិនាស, សេចក្ដីវិនាសមិនមែនជាសេចក្ដីចំរើន, មុក្ខជាគ្រឿងញុំាងសុខឱ្យវិនាសមិនមែនជាសេចក្ដីចំរើន (**អនយ**<ន+អយ=មិនមែនជាសេចក្ដីចំរើន, សេចក្ដីមិនចំរើន; វិ. **អយនំ ចឡនំ> អយោ, ន អយោ> អនយោ; ព្យសន**<វិ+អស+យុ=ទុក្ខជាគ្រឿងញុំាងសុខឱ្យវិនាស, សេចក្ដីវិនាស; វិ. **សុខំ ព្យសេតិ ខិ-នាសេតិ អនេនាតិ > ព្យសនំ** ) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនរិយ** គុ. [ ន+អរិយ ] មិនប្រសើរ, មិនមែនជារបស់នៃព្រះអរិយៈ, មិនមែនជាព្រះអរិយៈ ។

**អនលង្ករិត្វា** អ. [ ន+អលំ+ករ+ឥ.អា+ត្វា ] មិនធ្វើឱ្យល្អមហើយ, មិនធ្វើប្រដាប់ហើយ, មិនប្រដាប់ហើយ ។

**អនវដ្ឋិតចិត្ត** គុ. [ អនវដ្ឋិត+ចិត្ត ] មានចិត្តមិនតាំងស៊ប់ហើយ ឬមិនដិតល់ចុះហើយ, មានចិត្តមិនតាំងមាំហើយ (**អនវដ្ឋិត**<ន+អវ+ឋា, អានៃ ឋា>ឥ+ត) ។ - **កាល** ឋុំ. កាលនៃ...មានចិត្តមិនតាំងមាំហើយ។

**អនវជ្ជ** គុ. [ ន+អវជ្ជ ] មានទោសគឺបុគ្គលគប្បីវៀរមិនមាន, មិនមានទោសគឺបុគ្គលគប្បីវៀរ (មិនមានទោស); វិ. **វជ្ជគព្ភោតិ>** **វជ្ជោ,** **វជ្ជោ ឯវ** > **អវជ្ជោ** (អ ឥតិ និបាតោ) វិ. **នត្ថិ** **អវជ្ជោ** **ឯតស្សាតិ** > **អនវជ្ជោ** ។ - **អត្ថ** ឋុំ. អត្ថថា ឬសេចក្ដីថាមានទោសគឺបុគ្គលគប្បីវៀរមិនមាន ។

**អនវសេសបរិយាទានវចន** នឋុំ.[ អនវសេស+បរិយាទាន+វចន ] ពាក្យជាគ្រឿងកាន់យកជុំវិញនូវ...មិនមានសេសសល់, ពាក្យជាគ្រឿងកំណត់ដោយមិនមានសេសសល់ (**បរិយាទាន**<បរិ+អា+ទា+យុ, ចុះយុ.អា.) ។

**អនវសេសេត្វា** អ. [ ន+អវ+សិស+ណេ+ត្វា ] មិនញ៉ាំង...ឱ្យសេសចុះហើយ, មិនឱ្យសេសសល់ហើយ ។

**អនវស្សុតចិត្ត** គុ. [ អនវស្សុត+ចិត្ត ] មានចិត្តមិនទទឹកហើយដោយរាគៈ, មានចិត្តគឺរាគៈមិនទទឹកហើយ, មានចិត្តមិនទទឹកហើយ (**អន-**

Websites: WatKhemaraRatanaram.org or WatKhmers.org

វស្សុត < ន+អវ+សុ+ត); វិ. **អនវស្សុតំ ចិត្តំ យស្ស សោ > អនវស្សុតចិត្តោ** ។

**អនស្សវ** ចុំ. [ ន+អ+សុ+ណ ] កិ.មិនស្តាប់, មិនស្តាប់បង្គាប់; វិ. **សុយ្យ-តេតិ>សវនំ, សវនំ ឯវ>អស្សវនំ** (អ.និបាត); **អស្សវនំ > អស្សវោ, ន អស្សវោ > អនស្សវោ** ។

**អនស្សាសិត្វា** អ. [ ន+អា+សស+ឥ.អា.+ត្វា ] មិនដកដង្ហើមចេញហើយ, មិនល្ហងលោមហើយ, មិនត្រេកអរហើយ ។

**អនាកុលតា** ឥ. [ អនាកុល+តា ] ភាវៈនៃ...ជារបស់មិនវឹកវរ ។

**អនាគតំសញ្ញាណ** នចុំ. [ អនាគត+អំស+ញាណ ] ញាណជាចំណែកក្នុងកាលជាអនាគត, ញាណប្រព្រឹត្តទៅក្នុងចំណែកនៃកាលជាអនាគត ។

**អនាគត** តុ. [ ន+អា+គម+ត ] មិនមកហើយ, មិនទាន់មកដល់ហើយ; វិ. **ន អាគមិស្សតិ > អនាគតោ** ។

**អនាគន្ត្វា** អ. [ ន+អា+គម+ត្វា ] មិនមកហើយ, មិនទាន់មកហើយ ។

**អនាគមន** នចុំ. [ ន+អា+គម+យុ ] កិ.មិនមក, កិ.មិនទាន់មក ។

**អនាគាមី** តុ. [ ន+អា+គម+ណី ] ព្រះអនាគាមី, អ្នកនឹងមិនមកដោយប្រក្រតី, អ្នកមានកិ.មិនមកជាប្រក្រតី, អ្នកមានកិ.មកកាន់កាមធាតុដោយអំណាចនៃបដិសន្ធិមិនមាន ។ **. អរិយសាវក** ចុំ. អរិយសាវកជាអនាគាមី ។ **. ឧបាសិកា** ឥ. ឧបាសិកាជាអនាគាមី ។ **. ថេរ** ចុំ. ព្រះថេរៈជាអនាគាមី ។ **. ផលុបនិស្សយ** ចុំ. ធម៌ជាឧបនិស្ស័យនៃ

អនាគាមិផល ។ . **ផល** នបុំ. ផលនៃអនាគាមី ។ . **មគ្គវស** បុំ. អំណាចនៃអនាគាមិមគ្គ ។ . **សុខមត្តក** គុ. ហេតុត្រឹមតែសុខនៃបុគ្គលជាអនាគាមី ។

**អនាគារិក** គុ. [ ន+អាគារិក ] បព្វជិតមានកម្មជាប្រយោជន៍ដល់ផ្ទះមិនមាន, មិនមានកម្មជាប្រយោជន៍ដល់ផ្ទះ (អ្នកមិនគ្រប់គ្រងផ្ទះ, អ្នកបួស); វិ. **អគារស្ស ហិតំ** > **អាគារិកំ** (កម្មំ), **នត្ថិ អាគារិកំ អស្សាតិ** > **អនាគារិកោ** ។

**អនាគារិយ** គុ. ដូច «អនាគារិក» ខុសគ្នាតែបច្ច័យតែប៉ុណ្ណោះ ។ . **មុនិ** បុំ. អ្នកប្រាជ្ញមិនមានកម្មជាប្រយោជន៍ដល់ផ្ទះ, អ្នកប្រាជ្ញមិនគ្រប់គ្រងផ្ទះ, អ្នកប្រាជ្ញជាបព្វជិត ។ . **សីល** នបុំ. សីលនៃ...។

**អនាគារ** គុ. [ ន+អគារ ] អ្នកមានផ្ទះមិនមាន; វិ. **នត្ថិ អគារំ ឯតស្សាតិ** > **អនាគារោ** ។

**អនាចរិយកុល** នបុំ. [ អនាចរិយ+កុល ] ត្រកូលនៃបុគ្គលមិនមែនជាអាចារ្យ; វិ. **ន អាចរិយោ** > **អនាចរិយោ តស្ស កុលំ** > **អនាចរិយកុលំ** ។

**អនាចារកិរិយា** ឥ. [ អនាចារ+កិរិយា ] កិ.ធ្វើនូវអនាចារ, កិ.ធ្វើនូវការប្រព្រឹត្តមិនគួរ, កិ.ធ្វើដោយអំណាចនៃកិ.ប្រព្រឹត្តមិនគួរ ។

**អនាចារ** បុំ. [ ន+អាចារ ] កិ.ប្រព្រឹត្តិខុសទៅមិនគួរ, មារយាទមិនគួរ (ឥតមារយាទ); វិ. **អយុត្តោ អាចារោ** > **អនាចារោ** ។ មានអាចារមិន

Websites: WatKhemaraRatanaram.org or WatKhmers.org

មាន, មានអាចារមិនមាន; វិ. នត្ថិ អាចារោ ឯតស្សាតិ > អនាចារោ ។

**អនាចិក្ខន្តី** គុ.[ ន+អា+ចិក្ខ+អន្ត+ឦ ] កាលមិនប្រាប់, កាលមិនពោល ។

**អនាណត្ត** គុ. [ ន+អាណា+ត, ត>ត្ត ] គឺ...មិនបង្គាប់ហើយ, គឺស្ដេចមិនទ្រង់បង្គាប់ហើយ ។

**អនាតុរ** គុ. [ ន+អាតុរ ] អ្នកមិនមានសេចក្ដីក្ដៅក្រហាយ, អ្នកមិនមានសេចក្ដីរសាប់រសល់; វិ. នត្ថិ អាតុរោ ឯតស្សាតិ > អនាតុរោ ។

**អនាថ** គុ. [ ន+នាថ ] មានទីពឹងមិនមាន (ឥតទីពឹង); វិ. នត្ថិ នាថោ ឯតស្សាតិ > អនាថោ ។ - **សរីរ** នបុំ. សរីរៈនៃបុគ្គលមានទីពឹងមិនមាន ។

**អនាថបិណ្ឌិក** បុំ. [ អនាថបិណ្ឌ+ណិក ] អ្នកឱ្យនូវដុំបាយដល់ជនអ្នកមិនមានទីពឹង; វិ. អនាថានំ បិណ្ឌំ ទទាតីតិ>អនាថបិណ្ឌិកោ (សេដ្ឋីឈ្មោះអនាថបិណ្ឌិក) ។ - **ប្បមុខ** គុ. មានសេដ្ឋីឈ្មោះអនាថ-បិណ្ឌិកជាប្រមុខ ឬជាប្រធាន ។ - **វត្ថុ** នបុំ. រឿងនៃសេដ្ឋីឈ្មោះអនា-ថបិណ្ឌិក ។

**អនាទយិត្វា** អ. [ ន+អា+ទា, អានៃទា>ឥ+យ.អា.+ត្វា ] មិនកាន់យកហើយ, មិនអើពើហើយ ។

**អនាទាន** នបុំ. [ ន+អា+ទា+យុ ] កិ.មិនកាន់យក; គុ. អ្នកមានកិ.កាន់យកមិនមាន, អ្នកមិនមានសេចក្ដីប្រកាន់ ។

**អនាបជ្ជិត្វា** អ. [ ន+អា+បទ+យ, ទ និង យ>ជ្ជ+ឥ.អា.+ត្វា ] មិនដល់ហើយ,

Websites: WatKhemaraRatanaram.org or WatKhmers.org

មិនត្រូវហើយ ។

**អនាបត្តិ** ឥ. [ ន+អាបត្តិ ] កិ.មិនមាននៃអាបត្តិ (មិនមែនជាអាបត្តិ) វិ. **អាបត្តិយា អភាវោ > អនាបត្តិ** ។ - ទិដ្ឋិ ឥ. សេចក្តីឃើញថាកិ.មិនមាននៃអាបត្តិ; គុ. មានសេចក្តីឃើញថាកិ.មិនមាននៃអាបត្តិ ។

**អនាបុច្ឆា** អ. [ ន+អាបុច្ឆា>អនាបុច្ឆា ] មិនលាហើយ, មិនប្រាប់ហើយ ។

**អនាមត** នបុំ. [ ន+អមត ] ទីមិនមានសេចក្តីស្លាប់; វិ. **មរណំ > មតំ, មតំ ឯវ > អមតំ** (អ.និបាត); **នត្ថិ អមតំ ឯត្ថាតិ>អនាមតំ** ។

**អនាមន្តេត្វា** អ. [ ន+អា+មន្ត+ណេ+ត្វា ] មិនហៅហើយ, មិនហៅមកហើយ ។

**អនាមសិត្វា** អ. [ ន+អា+មស+ឥ_អា.+ត្វា ] មិនពាល់ហើយ, មិនស្ទាបអង្អែលហើយ, មិនចាប់កាន់ហើយ ។

**អនារោចិតភាវ** បុំ. [ អនារោចិត+ភាវ ] ភាវៈនៃ...ជា...គឺ...មិនប្រាប់ហើយ ។

**អនារោចេត្វា** អ. [ ន+អា+រុច+ណេ+ត្វា ] មិនប្រាប់ហើយ ។

**អនាលយ** គុ.[ ន+អាលយ ] មានអាល័យមិនមាន (មិនមានអាល័យ, កិ.មិនមាននៃទីជាទីនៅ); វិ. **នត្ថិ អាលយោ ឯតស្សាតិ > អនាលយោ** ។ - ចារី បុំ. អ្នកមានអាល័យមិនមានត្រេចទៅ, អ្នកមានកិ.ត្រេចទៅដោយមិនមានអាល័យ ។

**អនាវដ្ដន** គុ. [ ន+អា+វត្ត, វត្ត>វដ្ដ+អន ] កាលមិនទឹក, កាលមិនវិល, កាល

Websites: WatKhemaraRatanaram.org or WatKhmers.org

មិនពិចារណា ។

អនាវាស គុ. [ ន+អាវាស ] មានអាវាសមិនមាន, មានប្រទេសជាទីនៅអាស្រ័យមិនមាន; វិ. **អាវសន្តិ ឯត្ថាតិ>អាវាសោ, នត្ថិ អាវាសោ ឯតស្សាតិ > អនាវាសោ** ។

អនាវិល គុ. [ ន+អាវិល ] មានល្អក់មិនមាន, មិនល្អក់ ។

អនាសកា ឥ. [ ន+អស+ណុ+អា.ឥ.] កិ.មិនស៊ី (នូវភោជន); វិ. (**ភោជន-ស្ស) អនសនំ អភុញ្ជនំ > អនាសកា** ។

អនាសវ គុ. [ ន+អាសវ ] មានអាសវៈមិនមាន, មានកិលេសជាគ្រឿងត្រាំមិនមាន; វិ. **នត្ថិ អាសវោ ឯតស្សាតិ >អនាសវោ** ។

អនាហរណីយ គុ. [ ន+អា+ហរ+អនីយ, អនីយ>អណីយ ] គឺ...មិនគប្បីនាំមក ។

អនាហរិយមាន គុ. [ ន+អា+ហរ+ឥ.អា.+យ+មាន ] គឺ...កាលមិននាំមក ។

អនិកាមយ គុ. [ ន+និ+កម+ណយ ] មិនមែនអ្នកប្រាថ្នាដោយមិនសល់, អ្នកមិនប្រាថ្នា, មិនត្រេកអរ ។

អនិកេតចារី ចុំ. [ អនិកេត+ចារី ] អ្នកមានទីជាទីនៅមិនមានត្រេចទៅ, អ្នកមានកិ.ត្រេចទៅដោយមិនមានទីជាទីនៅ; វិ. **និកេតិ ចសតិ ឯត្ថាតិ > និកេតំ, នត្ថិ និកេតំ ឯតស្សាតិ>អនិកេតោ, នត្ថិ និកេតំ ឯតស្មិន្តិ ឋា>អនិកេតំ; អនិកេតោ ចរតី-តិ>អនិកេតចារី; អនិកេតេន ចរណំ> អនិកេតចារោ,**

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនិកេតចារោ ឯកស្ស អត្ថិ > អនិកេតចារី** ។

**អនិកេតសារី** ពុំ. ( ដូចអនិកេតចារី ) **សារី**<សរ+ណី, «ត្រេចទៅ»ដូចគ្នា ។

**អនិក្កសាវ** គុ. [ អនិក្ខន្ត+កសាវ ] មានទឹកចត់មិនទាន់ចេញហើយ, មានទឹកចត់គឺរាគាទិក្កិលេសមិនទាន់ចេញហើយ; វិ. **អនិក្ខន្តោ កសាវោ យស្ស សោ> អនិក្កសាវោ** ។

**អនិក្ខមនក** ពុំ. [ ន+និ+កម, កម>ខម+ណ្វុ ] អ្នកមិនឈានចេញ, អ្នកមិនចេញទៅ; វិ. **និក្ខមតីតិ > និក្ខមនកោ, ន និក្ខមនកោ > អនិក្ខមនកោ** ។ ណ្វុ>អនក ។

**អនិក្ខមនត្ថ** ពុំ. [ អនិក្ខមន+អត្ថ ] ប្រយោជន៍ដល់កិ.មិនចេញទៅ, ត្រូវការដល់កិ.មិនចេញទៅ ។

**អនិក្ខិបិត្វា** អ. [ ន+និ+ខិប+ឥ_អា.+ត្វា ] មិនដាក់ចុះហើយ, មិនទុកហើយ ។

**អនិគ្គណ្ហន្ត** គុ. [ ន+និ+គហ+ណ្ហា+អន្ត, លុបហទីបំផុតនៃធាតុ ] កាលមិនផ្ចាញ់ផ្ចាល់, កាលមិនសង្កត់សង្កិន ។

**អនិច្ច** គុ. [ ន+និច្ច ] ដែលមិនទៀង; នពុំ. សេចក្តីមិនទៀង ។ **- លក្ខណ** នពុំ. លក្ខណៈមិនទៀង, លក្ខណៈគឺសេចក្តីមិនទៀង, លក្ខណៈនៃសេចក្តីមិនទៀង, ធម្មជាតជាគ្រឿងកំណត់ថាសង្ខារជារបស់មិនទៀង ។ **- សញ្ញា** ឥ. សេចក្តីសំគាល់ថាមិនទៀង ។

**អនិច្ឆន្ត** គុ. [ ន+ឥស+យ+អន្ត ] កាលមិនប្រាថ្នា, កាលមិនចង់ ។

**អនិច្ឆា** ឥ. [ ន+ឥច្ឆា ] សេចក្តីមិនប្រាថ្នា គុ. មិនមានសេចក្តីប្រាថ្នា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនិច្ឆិត្វា** អ. [ ន+ឥស+យ+ឥ_អា.+ត្វា ] មិនប្រាថ្នាហើយ, មិនចង់ហើយ ។

**អនិដ្ឋិត** គុ. [ ន+និ+ឋា, អាទេឋា>ឥ+ត ] មិនសំរេចហើយ, មិនទាន់សំរេចហើយ, មិនចប់ហើយ, មិនទាន់ចប់ហើយ ។

**អនិដ្ឋារម្មណ** នចុំ. [ អនិដ្ឋ+អារម្មណ ] អារម្មណ៍គឺបុគ្គលមិនប្រាថ្នាហើយ, អារម្មណ៍មិនជាទីប្រាថ្នា ។

**អនិត្ថិគន្ធកុមារ** ចុំ. [ អនិត្ថិគន្ធ+កុមារ ] កុមារមានក្លិននៃស្ត្រីមិនមាន; កុមារឈ្មោះអនិត្ថិគន្ធៈ ។

**អនិទ្ទាយន្ត** គុ. [ ន+និទ្ទ+អាយ+អន្ត ] កាលមិនប្រព្រឹត្តលក់, កាលមិនប្រ-ព្រឹត្តដេកលក់ ។

**អនិន្ទិត** គុ. [ ន+និន្ទ+ឥ_អា.+ត ] គឺ...មិនតិះដៀលហើយ ។

**អនិបជ្ជិត្វា** អ. [ ន+និបជ្ជិត្វា ] មិនដេកហើយ, មិនក្រាបចុះហើយ ។

**អនិប្ផល** គុ. [ ន+និប្ផល ] មិនមែនអ្នកមានផលមិនមាន, (អ្នកមិនឥតផល); វិ. នត្ថិ ផលំ ឯតស្សាតិ > និប្ផលោ, ន និប្ផលោ > អនិប្ផលោ ។

**អនិព្វត្តិ** ឥ. [ ន+និព្វត្តិ ] កិ.មិនកើត ។

**អនិព្វានទីបក** គុ. [ អនិព្វាន+ទីប+ណ្វុ ] ដែលសំដែងនូវធម្មជាតមិនមែនជានិព្វាន ។

**អនិព្វិសំ** គុ. [ ន+និ+វិស+អន្ត+សិ_វិ, ផ្លាស់ន្ត+សិ_វិ>អំ ] កាលមិនបាន, កាលមិនជួប, កាលមិនប្រទះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនិព្វុត** គុ. [ ន+និ+វុ+ត, វ>ព>ព្វ, អានៃវុ>ឧ ] មិនរលត់ហើយ, មិនទាន់រលត់ហើយ (មានទុក្ខមិនទាន់រលត់ហើយ ) ។

**អនិព្វេមតិកភាវ** ចុំ.[ អនិព្វេមតិក+ភាវ ] ភាវៈនៃ...ជា...មិនមែនអ្នកមានសេចក្តីសង្ស័យមិនមាន, .មិនមែនអ្នកមានសេចក្តីសង្ស័យចេញហើយ; វិ. **នត្ថិ វិមតិ អស្សាតិ> និព្វេមតិកោ ; ន និព្វេ-មតិកោ > អនិព្វេមតិកោ តស្ស ភាវោ > អនិព្វេ-មតិកភាវោ** ។

**អនិមិត្ត** គុ. [ ន+និមិត្ត ] មាននិមិត្តមិនមាន, មានហេតុជាគ្រឿងកំណត់មិនមាន, (វិមោក្ខឈ្មោះអនិមិត្ត); វិ. **និម្មិនាតិ ឯតេនាតិ> និមិត្តំ, នត្ថិ និមិត្តំ ឯតស្សាតិ > អនិមិត្តំ** ។

**អនិយតគតិក** គុ.[ អនិយត+គតិ+ក ] អ្នកមានគតិមិនទៀង; វិ. **អនិយតា គតិ យស្ស សោ > អនិយតគតិកោ** ។

**អនិយម** គុ. [ ន+និយម ] មិនកំណត់, មានសេចក្តីនិយមមិនមាន, មិនទៀង ។

**អនិវត្តគមន** នចុំ. [ អនិវត្ត+គមន ] កិ.ទៅមិនត្រឡប់វិញ, ដំណើរមិនវិលវិញ ។

**អនិវត្តនភាវ** ចុំ. [ អនិវត្តន+ភាវ ] ភាវៈនៃ ឬ គឺកិ.មិនត្រឡប់វិញ ។

**អនិវត្តន្ត** គុ. [ ន+និ+វត, វត>វត្ត+អន្ត ] កាលមិនត្រឡប់វិញ, កាលមិនវិលវិញ ។

**អនិវត្ត** គុ. [ ន+និ+វត+ត ] មិនត្រឡប់វិញហើយ, មិនវិលវិញហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនិវេសន** គុ. [ ន+និវេសន ] មានទីជាទីនៅអាស្រ័យមិនមាន (មានផ្ទះមិនមាន); វិ. **និវិសន្តិ និវសន្តិ ឯត្ថាតិ> និវេសនំ, នត្ថិ និវេសនំ ឯតស្សាតិ > អនិវេសនោ** ។

**អនិវេសេត្វា** អ. [ ន+និ+វិស+ណេ+ត្វា ] មិនញ៉ាំង...ឱ្យនៅអាស្រ័យហើយ, មិនដឹកល់ហើយ ។

**អនិសាមេត្វា** អ. [ ន+និ+សម+ណេ+ត្វា ] មិនស្តាប់ហើយ, មិនពិចារណាហើយ, មិនទុកដាក់ហើយ ។

**អនិស្សរ** គុ. [ ន+ឥស្សរ ] មានបុគ្គលជាធំមិនមាន, មិនមានបុគ្គលជាធំ, មិនមែនជាធំ, មិនមែនជាឥស្សរៈ ។

**អនិស្សាយ** អ. [ ន+និ+សី+ត្វា, ត្វា>យ ] មិនអាស្រ័យហើយ ។

**អនិស្សិត** គុ. [ ន+និ+សី+ត ] មិនអាស្រ័យហើយ, គឺ...មិនអាស្រ័យហើយ ។

**អនិសីទិត្វា** អ. [ ន+និ+សទ, សទ>សីទ+ឥ.អា.+ត្វា ] មិនអង្គុយហើយ ។

**អនីឃ** គុ. [ ន+នីឃ ] អ្នកមានទុក្ខមិនមាន, មានសេចក្តីលំបាកមិនមាន (ឥតទុក្ខ) ។

**អនុកន្តតិ** កិ. [ អនុ+កន្ត+អ+តិ.វ.] រមែងតាមមុត, ..កាត់, ..លះ ។

**អនុកម្ប** ធុំ. [ អនុ+កម្ប+អ ] កិ.ញាប់ញ័រតាម (សេចក្តីអនុគ្រោះ, សេចក្តីអាណិត); វិ. **អនុកម្បនំ> អនុកម្បា** ។

**អនុក្កម** ធុំ. [ អនុ+កម+អ ] កិ.ឈានទៅតាម (លំដាប់, លំដាប់ហូរហែ) ។

**អនុករោតិ** ធុំ. [ អនុ+ករ+ឱ+តិ.វ.] ធ្វើតាម, ធ្វើត្រាប់, យកត្រាប់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុកិរិយា** ឥ. [ អនុ+ករ+រិយ+អា.ឥ. ] កិ.ធ្វើតាម, កិ.ធ្វើត្រាប់ ។

**អនុការ** គុ. [ អនុ+ករ+អន្ត+សិ.វិ. ] កាលធ្វើតាម, កាលធ្វើត្រាប់, កាលយកតម្រាប់ ។

**អនុកូល** នថុំ. [ អនុ+កូល ] សេចក្ដីអនុកូល, សេចក្ដីទំនុកបំរុង, កិ.បណ្ដោយតាម, សេចក្ដីអនុគ្រោះ ។ . **ភាវ** ថុំ. ភាវៈនៃ...ជាអ្នកអនុកូល, ...។

**អនុគច្ឆតិ** កិ. [ អនុ+គម+អ+តិ.វ.] រមែងទៅតាម, តាមទៅ, ជូនទៅ ។

**អនុគន្ត្វា** អ. [ អនុ+គម+ត្វា ] ទៅតាមហើយ, តាមទៅហើយ, ជូនទៅហើយ ។

**អនុគ្គហណ** នថុំ.[ អនុ+គហ+យុ ] កិ.កាន់យកតាម, សេចក្ដីអនុគ្រោះ ។

**អនុគ្គហ** ថុំ. [ អនុ+គហ+អ ] កិ.កាន់យកតាម, សេចក្ដីអនុគ្រោះ, វិ. **អនុគ្គហណំ > អនុគ្គហោ** ។

**អនុចរ** ថុំ. [ អនុ+ចរ+អ ] អ្នកត្រេចទៅតាម, កិ.ត្រេចទៅតាម ។

**អនុចារី** ថុំ. [ អនុ+ចរ+ណី ] អ្នកមានកិ.ប្រព្រឹត្តិទៅតាមជាប្រក្រតី, អ្នកត្រេចទៅតាមជាប្រក្រតី, អ្នកត្រេចទៅដោយលំដាប់ ។

**អនុច្ឆមាស** ថុំ. [ អនុ+ឆមាស ] ខែ៦ជាលំដាប់, ៦ខែជាលំដាប់; វិ. **ឆមាសា > ឆម្មាសំ , អនុ ឆម្មាសំ > អនុច្ឆម្មាសំ** ។

**អនុច្ឆវិក** គុ. [ អនុ+ឆវិ+ក ] ដែលប្រព្រឹត្តទៅតាមសម្បុរថ្ងៃ (ដ៏សមគួរ, ត្រូវបែប); **ឆវិយា អនុរូបំ > អនុច្ឆវិកំ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុច្ឆិដ្ឋ** គុ. [ ន+ឧច្ឆិដ្ឋ ] មិនមែនជាដែល, មិនមែនជារបស់ដែល, មិនមែនជារបស់សំណល់ ។

**អនុជាតបុត្ត** បុំ. [ អនុជាត+បុត្ត ] កូនដែលកើតតាម, កូនដែលកើតតាមលំអាន, អនុជាតបុត្រ ។

**អនុជានាបេត្វា** អ. [ អនុ+ញា+នា+ណាបេ+ត្វា ] ញុំាង... ឱ្យដឹងតាមហើយ, ឱ្យយល់តាមហើយ, ឱ្យអនុញ្ញាតតាមហើយ ។

**អនុជានាថ** កិ. [ អនុ+ញា+នា+ថ.ប. ] ចូរដឹងតាម, ចូរអនុញ្ញាត ។

**អនុញ្ញាតសេនាសន** គុ. [ អនុញ្ញាត+សេនាសន ] មានសេនាសនៈដែល... អនុញ្ញាតហើយ ។

**អនុដ្ឋហន្ត** គុ. [ ន+ឧ+ឋា+ហ_អា.+អន្ត ] កាលមិនក្រោកឡើង, កាលមិនតាំងឡើង ។

**អនុដ្ឋហាន** គុ. [ ន+ឧ+ឋា+ហ_អា.+យុ ] អ្នកមិនក្រោកឡើង, អ្នកមិនតាំងឡើង, អ្នកមិនក្រវើនក្រតើន ។

**អនុដ្ឋានមល** គុ. [ អនុដ្ឋាន+មល ] មានកិ.មិនតាំងឡើងជាមន្ទិល, មានកិ.មិនក្រោកឡើងជាមន្ទិល, មានកិ.មិនថែទាំជាមន្ទិល, មានកិ.មិនជួសជុលជាមន្ទិល ។

**អនុដ្ឋាបេន្ត** គុ. [ ន+ឧ+ឋា+ណាបេ+អន្ត ] កាលមិនញុំាង...ឱ្យតាំងឡើង, ឱ្យក្រោកឡើង ។

**អនុដ្ឋិត** គុ. [ ន+ឧ+ឋា, អាទែឋា>ឥ+ត ] មិនតាំងឡើងហើយ, មិនក្រោកឡើងហើយ, មិនទាន់ក្រោកឡើងហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុឌហិតុំ** អ.[ អនុ+ទហ, ទហ>ឌហ+ឥ-អា.+តុំ ] ដើម្បីឆេះតាម, ដើម្បីរលាកតាម, ឬតាមរលាក, ដើម្បីរោលរាលតាម ។

**អនុតប្បតិ** កិ. [ អនុ+តប+អ+តិ-វ. ] រមែងក្ដៅតាម, ក្ដៅរឿយៗ ។

**អនុតីរចារី** បុ.[ អនុតីរ+ចរ+ណី ] អ្នកត្រេចទៅទៀបឆ្នេរជាលំដាប់, អ្នកមានកិ.ត្រេចទៅតាមឆ្នេរ (ច្រាំង, ត្រើយ) ជាប្រក្រតី ។

**អនុត្តរធម្មរាជតា** ន. [ អនុត្តរធម្មរាជ+តា ] ភាវៈនៃ... ជាព្រះរាជាព្រោះធម៌មានគុណជាតដទៃក្រៃលែងជាងមិនមាន, -ជាស្ដេចព្រះធម៌ដ៏ប្រសើរ -ជាស្ដេចប្រកបដោយធម៌ដ៏ប្រសើរ; វិ. **នត្ថិ ឧត្តរំ ឯតស្មាតិ > អនុត្តរោ, អនុត្តរោ ធម្មោ > អនុត្តរធម្មោ, អនុត្តរធម្មោ រាជា យុត្តោ ខា > អនុត្តរធម្មរាជា តស្ស ភាវោ > អនុត្តរធម្មរាជតា** ។

**អនុត្តម** គុ. [ ន+ឧត្តម ] មិនឧត្ដម, មិនខ្ពង់ខ្ពស់, មិនប្រសើរ ។

**អនុត្តរ** គុ. [ ន+ឧត្តរ ] មានបុគ្គលដទៃក្រៃលែងជាងមិនមាន, មិនមានបុគ្គលក្រៃលែងជាង, មិនមានគុណជាតដទៃក្រៃលែងជាង (ប្រសើរ) ។

**អនត្ថុនន្ត** អ. [ អន+ថុ+នា, នា>ន+អន្ត ] កាលដកដង្ហើមចេញ, កាលថ្ងូររឿយៗ, កាលត្អូញត្អែររឿយៗ, កាលនឹកស្ដាយ ។

**អនុថូល** គុ. [ អនុ+ថូល ] តូចនិងធំ, តិចនិងច្រើន, ។ ប្រើជាអណុថូលក៏មាន ។

**អនុត្ថេរ** បុ. [ អនុ+ថេរ ] ព្រះថេរៈតូច, ព្រះថេរៈបន្ទាប់, ព្រះថេរៈជាលំដាប់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុទានភាវ** ពុំ. [ អនុទាន+ភាវ ] ភាវៈនៃកិ.មិនបន្លឺឡើង (អនុទាន<ន+ឧទ+យុ) ។

**អនុទិសា** ឥ. [ អនុ+ទិស ] ទិសតូច, ទិសបន្ទាប់, ទិសជាលំដាប់ ។

**អនុទូត** ពុំ. [ អនុ+ទូត ] អ្នកជាអនុទូត, ទូតតូច, ទូតបន្ទាប់, អ្នកបំរើតូច ។

**អនុទ្ទយា** ឥ. [ អនុ+ទយ+អ+អា.ឥ. ] ធម្មជាតិបៀតបៀននូវទុក្ខរបស់បុគ្គលដទៃផងនូវសុខរបស់ខ្លួនផង (សេចក្តីអាណិត); វិ. **អនុទ្ទយតិ បរទុក្ខំ អត្តសុខញ្ច ហឹសតីតិ > អនុទ្ទយា** ។

**អនុទ្ធត** គុ. [ ន+ឧទ្ធត ] អ្នកមានចិត្តទៅក្នុងខាងលើមិនមាន, អ្នកមានចិត្តមិនអណ្តែតអណ្តូង, អ្នកមានចិត្តមិនរាយមាយ, អ្នកមានចិត្តមិនរសាប់រសល់; វិ. **ឧទ្ធំ ហានតិ គច្ឆតីតិ> ឧទ្ធតំ, នត្ថិ ឧទ្ធតំ ឯតស្សាតិ > អនុទ្ធតោ** ។ (ឧទ្ធតិ<ឧ+ហន+ត, ផ្លាស់ហន> ធ, តម្រូត ទ) ។ ន័យខ្លះទៀត (ឧទ្ធតិ<ឧ+ធុ+ត) ចិត្តតែងញាប់ញ័រក្នុងខាងលើ (ចិត្តអណ្តែតអណ្តូង, ចិត្តរាយមាយ); វិ. **ឧទ្ធំ ធុនាតិ កម្បតីតិ > ឧទ្ធតំ (ចិត្តំ)** ។

**អនុធម្មចារី** ពុំ. [ អនុធម្ម+ចរ+ណី ] អ្នកមានកិ.ប្រព្រឹត្តតាមធម៌ជាប្រក្រតី; វិ. **អនុធម្មំ ចរិតុំ សីលមស្សាតិ > អនុធម្មចារី**, ឥ. **.ចារិនី**, នពុំ. **.ចារិ** ។

**អនុធាវតិ** កិ. [ អនុ+ធាវ+អ+តិ.វ. ] ស្ទុះទៅតាម, លឿនទៅតាម, ស្ទុះទៅរឿយៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុនយវស** បុំ. [ អនុនយ+វស ] អំណាចនៃកិ.នាំទៅតាម, អំណាចនៃកិ. ដឹកនាំរឿយៗ (**អនុនយ**<អនុ+នី+អ) ។

**អនុបគន្ត្វា** អ. [ ន+ឧប+គម+ត្វា ] មិនចូលទៅជិតហើយ ។

**អនុបគមន** នបុំ. [ ន+ឧប+គម+យុ ] កិ.មិនចូលទៅជិត ។ . **ការណ** នបុំ. ហេតុនៃកិ.មិនចូលទៅជិត, ហេតុគឺកិ... ។

**អនុបឃាតាបន** នបុំ. [ ន+ឧប+ហន, ហន>ឃាត+ណាបេ+យុ ] កិ.មិន ញ៉ាំង... ឱ្យចូលទៅបៀតបៀន, .ឱ្យចូលទៅសម្លាប់ ។

**អនុបឃាត** បុំ. [ ន+ឧប+ហន, ហន>ឃាត+អ ] កិ.មិនចូលទៅបៀតបៀន, កិ.មិនចូលទៅសម្លាប់ ។

**អនុបចិត** គុ. [ ន+ឧប+ចិ+ត ] គឺ...មិនចូលទៅសន្សំហើយ, .មិនចូលទៅ កព្ទូនហើយ ។

**អនុបដ្ឋហានភាវ** បុំ. [ អនុបដ្ឋហាន+ភាវ ] ភាវៈនៃកិ.មិនចូលទៅតាំងទុក, .នៃកិ.មិនបំរើ (**អនុបដ្ឋហាន**<ន+ឧប+ឋា+ហ.អា.+យុ) ។

**អនុបដ្ឋាបិត** គុ. [ ន+ឧប+ឋា+ណាបេ+ឥ.អា.+ត ] គឺ...មិនញ៉ាំង...ឱ្យ ចូលទៅតាំងទុកហើយ, .មិនចូលទៅដឹកល់ទុកហើយ, គឺ...មិនឱ្យ បំរើហើយ ។

**អនុបដ្ឋិតស្សតិ** គុ. [ អនុបដ្ឋិត+សតិ ] មានស្មារតីមិនចូលទៅតាំងទុក ហើយ, មានស្មារតីមិនតាំងមាំហើយ; វិ. **អនុបដ្ឋិតា សតិ យេន សោ** > **អនុបដ្ឋិតស្សតិ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុបដ្ឋិត** គុ. [ ន+ឧប+ឋា, អានៃឋា>ឥ+ត ] គឺ...មិនចូលទៅតាំងទុកហើយ, _មិនតាំងមាំហើយ, _មិនដំកល់មាំហើយ ។

**អនុបតន្តិ** កិ. [ អនុ+បត+អ+អន្តិ_វ. ] រមែងធ្លាក់តាម, ធ្លាក់ចុះតាម ។

**អនុបតិត** គុ. [ អនុ+បត+ឥ_អា.+ត ] គឺ... ធ្លាក់ចុះតាមហើយ ។

**អនុបតិត្វា** អ. [ អនុ+បត+ឥ_អា.+ត្វា ] ធ្លាក់តាមហើយ, ឆាបចុះហើយ, បន្ទាបចុះហើយ ។

**អនុបទ** នថុំ. [ អនុ+បទ ] ទីប្រព្រឹត្តទៅតាមស្នាមជើង, លំដាប់នៃស្នាមជើង, ដាននៃជើង, លំអាននៃជើង ។

**អនុបទ្ទវ** គុ. [ ន+ឧបទ្ទវ ] មានឧបទ្ទវៈ (ឧបទ្រព) មិនមាន, មានអន្តរាយចូលទៅបៀតបៀនមិនមាន, មិនមានចង្រៃ (ឧបទ្ទវ>ឧប+ទុ+អ); វិ. ឧបគន្ត្វា ឧទតិ បីឡេតីតិ> ឧបទ្ទវោ, នត្ថិ ឧបទ្ទវោ ឯតស្សាតិ> អនុបទ្ទវោ ។

**អនុបធារេត្វា** អ. [ ន+ឧប+ធរ+ណេ+ត្វា ] មិនចូលទៅទ្រទ្រង់ហើយ, មិនពិចារណាហើយ ។

**អនុបនយ្ហន** នថុំ. [ ន+ឧប+នហ+យ+យុ ] កិ.មិនចូលទៅចងទុក, កិ.មិនចងមាំ ។

**អនុបនយ្ហន្ត** គុ. [ ន+ឧប+នហ+យ+អន្ត ] កាលមិនចូលទៅចងទុក, ... ។

**អនុបបរិក្ខិត្វា** អ. [ ន+ឧប+បរិ+ឥក្ខ+ឥ_អា.+ត្វា ] មិនចូលទៅឃើញជុំវិញហើយ, មិនពិចារណាហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុប្បព្វជិតោ** កិ. [ អនុ+ប+វជ+អ+ត_អជ្ជ. ] បួសតាមហើយ ។

**អនុប្បព្វជ្ជា** ឥ. [ អនុ+ប+វជ+អ+អា_ឥ. ] កិ.បួសតាម (បួសតាម) ។

**អនុបរិយាយតិ** កិ. [ អនុ+បរិ+ឥ ឬអយ+អ+តិ_វ., ចុះយ_អា. ឬអនុ+បរិ+យា+យ+តិ_វ. ] ប្រព្រឹត្តទៅតាមជុំវិញ, វិលទៅតាម, ដើរក្រឡឹង, ដើរវិលវង់ ។

**អនុបរិវារេត្វា** អ. [ អនុ+បរិ+វរ+ណេ+ត្វា ] តាមចោមរោមហើយ, តាមហែហើយ, ហែតាមហើយ ។

**អនុបលិត្ត** គុ. [ ន+ឧប+លិប+ត ] គឺ...មិនចូលទៅជាប់ហើយ, -មិនចូលទៅលោបហើយ, -មិនប្រឡាក់ហើយ, -មិនជិតដាមហើយ ។

**អនុបវជ្ជ** គុ.[ ន+ឧប+វទ, វទ>វជ្ជ+អ ] អ្នកគឺអ្នកណាមួយមិនគប្បីតិះដៀលបាន; វិ. **ន ឧបវទិតព្វោតិ > អនុបវជ្ជោ** ។

**អនុបវត្តេន្ត** គុ. [ អនុ+ប+វត្ត+ណេ+អន្ត ] កាលញ៉ាំង...ឱ្យប្រព្រឹត្តទៅតាម, ... ។

**អនុបវាទន** នបុំ. [ ន+ឧប+វទ+យុ ] កិ.មិនតិះដៀលឯង, -ខ្លួនឯង ។

**អនុបវាទាបន** នបុំ. [ ន+ឧប+វទ+ណាបេ+យុ ] កិ.មិនញ៉ាំងបុគ្គលដទៃឱ្យតិះដៀល ។

**អនុបវាទ** បុំ. [ ន+ឧប+វទ+ណ ] កិ.មិនតិះដៀល; វិ. **អនុបវទនំ > អនុបវាទោ** ។

**អនុប្បវិដ្ឋ** គុ. [ អនុ+ប+វិស+ត ] ចូលទៅតាមហើយ, ចូលទៅដោយលំដាប់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុប្បវិសិត្វា** អ. [ អនុ+ប+វិស+ឥ_អា.+ត្វា ] ចូលទៅតាមហើយ, ចូលទៅតាមលំដាប់ហើយ ។

**អនុបសង្កមន្ត** គុ. [ ន+ឧប+សំ+កម+អន្ត ] កាលមិនចូលទៅជិត, កាលមិនចូលទៅរក, កាលមិនចូលទៅគាល់ ។

**អនុបស្សន្ត** គុ. [ អនុ+ទិស, ទិស>បស្ស+អន្ត ] កាលឃើញតាម, កាលឃើញរឿយៗ, កាលពិចារណា ។

**អនុបហច្ច** អ. [ ន+ឧប+ហន+ត្វា, ត្វា>រច្ច, លុបរនិងន ] មិនចូលទៅបៀតបៀនហើយ, មិនចូលទៅខ្ទាំងខ្ទប់ហើយ, មិនទើសហើយ, មិនទង្គិចហើយ ។

**អនុបហតជិវ្ហាបសាទ** គុ.[ អនុបហត+ជិវ្ហាបសាទ ] មានជិវ្ហាបសាទគឺរោគមិនចូលទៅបៀតបៀនហើយ, មានប្រសាទនៃអណ្តាតគឺទោសមិនចូលទៅកំចាត់បង់ហើយ (**អនុបហត**<ន+ឧប+ហន+ត) ។

**អនុបហនន** នបុំ. [ ន+ឧប+ហន+យុ ] កិ.មិនចូលទៅបៀតបៀន, កិ.មិនចូលទៅសម្លាប់ ។

**អនុបាទាបរិនិព្វាន** នបុំ. [ អនុបាទា+បរិនិព្វាន ] កិ.រលត់នៃសង្ខារគឺឧបាទានមិនចូលទៅកាន់យក, បរិនិព្វានគឺវិបាកក្ខន្ធ និងកម្មក្កិលេសមិនចូលទៅកាន់យក (អនុបាទាបរិនិព្វាន) ។

**អនុបាទាន** គុ. [ ន+ឧប+អា+ទា+យុ ] មានសេចក្តីប្រកាន់មាំមិនមាន, មានកិលេសជាគ្រឿងចូលទៅកាន់យកមិនមាន (មានកំញ្ញមមិនមាន) ។

**អនុបាទាយ** អ. [ ន+ឧប+អា+ទា+ត្វា, ត្វា>យ ] ព្រោះមិនចូលទៅកាន់យក,

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រោះមិនប្រកាន់មាំ (ម្យ៉ាងទៀតៈ «អនុបាទាយ» នេះ បើនាមសព្ទត្រូវប្រកបដោយវិភត្តិនាមក៏បាន) ។

**អនុបាទិន្នក** គុ. [ ន+ឧប+អា+ទា+ត, ត>ឥន្ន+ក.ស. ] (សង្ខារ) គឺវិញ្ញាណមិនចូលទៅកាន់យកហើយ (សង្ខារមិនមានចិត្តគ្រប់គ្រង បានដល់ដើមឈើនិងភ្នំជាដើម) ។

**អនុបាទិយន្ត** គុ. [ ន+ឧប+អា+ទា, អានៃទា>ឥ+យ.អា.+អន្ត ] កាលមិនចូលទៅកាន់យក, កាលមិនប្រកាន់មាំ ។

**អនុបាទិយាន** គុ.[ ន+ឧប+អា+ទា, អានៃទា>ឥ+យ.អា.+យុ ] អ្នកមិនចូលទៅកាន់យក, -មិនប្រកាន់មាំ ។

**អនុបាទិយិត្វា** អ. [ ន+ឧប+អា+ទា, អានៃទា>ឥ+ឥ.អា.+យ.អា.+ត្វា ] មិនចូលទៅកាន់យកហើយ, មិនប្រកាន់មាំហើយ ។

**អនុបាទិសេស** គុ. [ ន+ឧបាទិសេស ] មានកម្មជរូប និងវិបាកក្ខន្ធដ៏សេសគឺកម្មក្កិសេសចូលទៅកាន់យកមិនមាន (អនុបាទិសេសនិព្វាន); វិ. **ឧបាធិយតេ កម្មក្កិលេសេហីតិ >ឧបាធិ, ឧបាធិ-សេសោ>ឧបាធិសេសោ, នត្ថិ ឧបាធិសេសោ ឯតស្សាតិ > អនុបាធិសេសោ** ។

**អនុបាយិនី** ឥ. [ អនុ+ប+ឥ ឬអយ+ណី+ឥនី ] ទៅតាម, ប្រព្រឹត្តទៅតាម, មានគំ.ទៅតាមជាប្រក្រតី, មានគំ.អន្ទោលទៅតាមជាប្រក្រតី; វិ. **អនុបាយិតុំ សីលមស្សាតិ > អនុបាយិនី** ។

**អនុប្បិយ** គុ.[ អនុ+បិយ ] ជាទីស្រឡាញ់រឿយៗ; និគមឈ្មោះអនុប្បិយៈ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុប្បិយម្ពវន** នបុំ. [ អនុប្បិយ+អម្ពវន ] ព្រៃនៃស្វាយ ឬព្រៃដ៏ដេរដាសដោយដើមស្វាយឈ្មោះអនុប្បិយៈ (**អម្ពវន**<អម្ព+វន; វិ. **អម្ពោ-ហិ សញ្ញូនំ វនំ> អម្ពវនំ**); វត្តឈ្មោះអនុប្បិយម្ពវន ។

**អនុបុព្វីកថា** ឥ. [ អនុបុព្វ+កថា, ចុះព្យ.អា.] វាចាជាហេតុពោលតាមលំដាប់, វាចាជាហេតុពោលប្រព្រឹត្តទៅតាមលំដាប់; (ព្យ.អាគមនេះចុះមកដើម្បីឱ្យស្រួលដល់ការអាន ដូច«ធម្មីកថា»ជាដើម) ។

**អនុបុព្វ** គុ. [ អនុ+បុព្វ ] លំដាប់, លំដាប់តមក, លំដាប់ហូរហែ ។

**អនុប្បជ្ជន្ត** គុ. [ ន+ឧ+បទ+យ+អន្ត ] កាលមិនកើតឡើង, កាលមិនទាន់កើតឡើង ។

**អនុប្បជ្ជនកក្កិលេស** បុំ.[ អនុប្បជ្ជនក+កិលេស ] កិលេសដែលមិនកើតឡើង, កិលេសដែលមិនទាន់កើតឡើង; វិ. **ន ឧប្បជ្ជតិ> អនុប្បជ្ជនកោ, អនុប្បជ្ជនកោ កិលេសោ> អនុ-ប្បជ្ជនកក្កិលេសោ** ។

**អនុប្បត្ត** គុ. [ អនុ+បទ(១)+ត ] ដល់តាមហើយ, ដល់ដោយលំដាប់ហើយ ។

**អនុប្បន្ន** គុ. [ ន+ឧ+បទ+ត ] មិនកើតឡើងហើយ, មិនទាន់កើតឡើងហើយ ។

**អនុប្បាទន** នបុំ. [ ន+ឧ+បទ+ណេ+យុ ] កិ.មិនញុំាង...ឱ្យកើតឡើង ។

**អនុប្បាទេន្ត** គុ. [ ន+ឧ+បទ+ណេ+អន្ត ] កាលមិនញុំាង...ឱ្យកើតឡើង ។

---

(១) ន័យខ្លះថា បត_ធាតុ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុប្បាទេត្វា** អ. [ ន+ឧ+បទ+ណេ+ត្វា ] មិនញុំាង...ឱ្យកើតឡើងហើយ ។

**អនុផរិ** កិ. [ អនុ+ផរ+អ+ឦ_អជ្ជ.] ផ្សាយទៅតាមហើយ, ផ្សាយទៅរឿយៗហើយ, ផ្សាយទៅដោយលំដាប់ហើយ ។

**អនុពន្ធតិ** កិ. [ អនុ+ពន្ធ+អ+តិ_វ.] រមែងចងតាម, រមែងជាប់តាម, ដេញតាម ។

**អនុពន្ធន្ត** គុ. [ អនុ+ពន្ធ+អ+អន្ត ] កាលជាប់តាម, កាលដេញតាម ។

**អនុពទ្ធភាវ** បុំ. [ អនុពទ្ធ+ភាវ ] ភាវៈនៃ...ជា...គឺ...ជាប់តាមហើយ, ដេញតាមហើយ (**អនុពទ្ធ**<អនុ+ពធ+ត, ផ្លាស់ធ+ត>ទ្ធ) ។

**អនុពុទ្ធ** បុំ. [ អនុ+ពុធ+ត ] អ្នកត្រាស់ដឹងតាម (អនុពុទ្ធ); វិ. **អនុពុជ្ឈតីតិ** > **អនុពុទ្ធោ** ។

**អនុព្យញ្ជនគ្គាហ** បុំ.[ អនុព្យញ្ជន+គាហ ] កិ.កាន់យកដោយអនុព្យញ្ជនៈ, កិ.កាន់យកនូវនិមិត្តដោយអនុព្យញ្ជនៈ, កិ.កាន់យកនូវអវយវៈតាមចំណែក (**គាហ**<គហ+ណ) ។

**អនុព្យញ្ជនសមុជ្ជល** គុ. [ អនុព្យញ្ជន+សមុជ្ជល ] ដែលរុងរឿងព្រមដោយអនុព្យញ្ជនៈ ។ (**សមុជ្ជល**<សំ+ឧ+ជល+អ) ។

**អនុព្រូហយេ** កិ.[ អនុ+ព្រូហ+ណយ+ឯយ្យ_ស., លុបយ្យ ទុកតែឯ ] គប្បីចំរើនរឿយៗ, គប្បីចំរើនតាម ។

**អនុភវន្ត** គុ. [ អនុ+ភូ+អ+អន្ត ] កាលសោយ, កាលរង ។

**អនុភវមាន** គុ. [ អនុ+ភូ+អ+មាន ] កាលសោយ, កាលរង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុភវិត្វា** អ. [ អនុ+ភូ+ឥ_អា.+ត្វា ] សោយហើយ, រងហើយ ។

**អនុភាវិត** គុ. [ អនុ+ភូ+ណេ+ឥ_អា.+ត ] គឺ...ឱ្យចំរើនរឿយៗហើយ, ..ឱ្យកើតតាមហើយ, អប់រំរឿយៗហើយ ។

**អនុភូត** គុ. [ អនុ+ភូ+ត ] គឺ...កើតតាមហើយ, ..សោយហើយ, ..រងហើយ។

**អនុភោតិ** កិ. [ អនុ+ភូ+អ+តិ_វ.] រមែងសោយ, រង ។

**អនុមោទន** នថុំ. [ អនុ+មុទ+យុ ] សេចក្ដីរីករាយតាម; វិ. **អនុមោទយតេតិ> អនុមោទនំ**; ពាក្យជាគ្រឿងរីករាយតាម; វិ. **អនុមោទន្តិ ឯតេនាតិ > អនុមោទនំ** ។ - **ករណត្ថ** ថុំ. ប្រយោជន៍ ឬសេចក្ដីត្រូវការដល់កិ.ធ្វើនូវពាក្យជាគ្រឿងរីករាយតាម (.. នូវអនុមោទនា) ។ - **កថា** ឥ. វាចាជាគ្រឿងពោលដោយសេចក្ដីរីករាយ, វាចាជាគ្រឿងពោលនូវអនុមោទនា ។ - **កាល** ថុំ. កាលជាទីធ្វើនូវសេចក្ដីរីករាយ, កាលជាទីធ្វើនូវអនុមោទនា ។ - **គាថាវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវគាថាជាគ្រឿងរីករាយតាម ។ - **អត្ថ** ថុំ. ប្រយោជន៍ ឬ សេចក្ដីត្រូវការដល់ធម្មកថាជាគ្រឿងរីករាយតាម ។ - **ធម្មកថា** ឥ. ធម្មកថាជាគ្រឿងរីករាយតាម ។ - **អាវសាន** នថុំ. កាលជាទីបំផុតនៃធម្មកថាជាគ្រឿងរីករាយតាម, កាលជាទីបំផុតនៃអនុមោទនា, កាលជាទីចប់នៃ...។

**អនុមោទនា** ឥ. [ អនុ+មុទ+យុ+អា_ឥ.] វាចាជាគ្រឿងរីករាយតាម; វិ. **អនុមោទន្តិ ឯតាយាតិ> អនុមោទនា** ។

**អនុមោទិត្វា** អ. [ អនុ+មុទ+ឥ_អា.+ត្វា ] រីករាយតាមហើយ, ត្រេកអរតាម

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ ។

**អនុយុញ្ជតិ** កិ. [ អនុ+យុជ+អ+តិ_វ., ចុះនិ_អា. ] រមែងប្រកបតាម, ប្រកបរឿយៗ ។

**អនុយុញ្ជន្ត** គុ. [ អនុ+យុជ+អ+អន្ត ] កាលប្រកបតាម, កាលប្រកបរឿយៗ ។

**អនុយុញ្ជិត្វា** អ. [ អនុ+យុជ+ឥ_អា.+ត្វា ] ប្រកបតាមហើយ, ប្រកបរឿយៗហើយ (សាកសួរហើយ) ។

**អនុយុត្ត** គុ. [ អនុ+យុជ+ត ] ប្រកបតាមហើយ, ប្រកបរឿយៗហើយ ។ _ **តា** ឥ. ភាវៈនៃ...ជាអ្នកប្រកបតាមហើយ ។ _ **ភាវ៌** បុំ. ភាវៈនៃ...ជាអ្នកប្រកបតាមហើយ, _ជាអ្នកប្រកបដោយលំដាប់ហើយ ។

**អនុយោគី** បុំ. [ អនុយោគ+ឦ ] អ្នកមានព្យាយាមជាគ្រឿងប្រកបរឿយៗ; វិ. អនុយុញ្ជតិ ឯតេនាតិ > អនុយោគោ, អនុយោគោ យស្ស អត្ថីតិ > អនុយោគី ។ ឥ. អនុយោគិនី ។ នបុំ. អនុយោគិ ។

**អនុយោជេត្វា** អ. [ អ+ន+យុជ+ណេ + ត្វា ] មិនបញ្ជូនទៅហើយ, មិនប្រើទៅហើយ ។

**អនុរក្ខណត្ថ** បុំ. [ អនុរក្ខណ+អត្ថ ] ប្រយោជន៍ ឬសេចក្ដីត្រូវការដល់កិ.រក្សាតាម, _ដល់កិ.រក្សារឿយៗ (អនុរក្ខណ<អនុ+រក្ខ+យុ) ។

**អនុរក្ខន្ត** គុ. [ អនុ+រក្ខ+អ+អន្ត ] កាលរក្សាតាម, កាលតាមរក្សា, កាលរក្សារឿយៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អនុរក្ខិតុំ អ. [ អនុ+រក្ខ+ឥ.អា.+តុំ ] ដើម្បីរក្សាតាម, ដើម្បីតាមរក្សា, ដើម្បីរក្សារឿយៗ ។

អនុរាធបុរ នថុំ. [ អនុរាធ+បុរ ] បុរី (ក្រុង) ឈ្មោះអនុរាធៈ ។ . មត្ត គុ. មានបុរីឈ្មោះអនុរាធៈជាប្រមាណ ។

អនុរុជ្ឈតិ កិ. [ អនុ+រុធ+យ+តិ.វ., ផ្លាស់ធ+យ>ជ្ឈ ] រមែងត្រេកអរ, រមែងរីករាយ ។

អនុរុជ្ឈន នថុំ. [ អនុ+រុធ+យ+យុ ] សេចក្តីត្រេកអរ, សេចក្តីរីករាយ ។

អនុរុទ្ធសក្ក ថុំ. [ អនុរុទ្ធ+សក្ក ] សក្យៈឈ្មោះអនុរុទ្ធ ។

អនុរូប គុ. [ អនុ+រូប ] មានសភាពដ៏សមគួរ, (សមគួរ, ត្រូវបែប, ត្រូវទំនង); វិ. អនុរូបំ សភាវោ យស្ស សោ> អនុរូបោ ។ . វស ថុំ. អំណាចនៃ...ដ៏សមគួរ ។

អនុរោធ ថុំ. [ អនុ+រុធ+ណ ] សេចក្តីត្រេកអរ, សេចក្តីរីករាយ; វិ. អនុរជ្ឈនំ> អនុរោធោ; អនុរោធនំ វា> អនុរោធោ ។

អនុលិត្តគត្ត គុ. [ អនុលិត្ត+គត្ត ] មានខ្លួនគឺ...លាបរឿយៗហើយ, មានខ្លួនប្រឡាក់ហើយ (អនុលិត្ត<អនុ+លិប+ត = លាប, ប្ញក, ជាប់) ។

អនុលោមខន្តិ ឥ. [ អនុលោម+ខន្តិ ] ខន្តិប្រព្រឹត្តទៅដោយកិ.បណ្តោយតាម, ខន្តិប្រកបដោយអនុលោមញាណ, ខន្តិជាអនុលោម, អនុលោម-ខន្តិ, ខន្តិប្រព្រឹត្តទៅតាមនូវរោម (សេចក្តីអត់ធន់មិនខុស) ។

អនុលោមញាណ នថុំ. [ អនុលោម+ញាណ ] ញាណប្រព្រឹត្តទៅដោយកិ.

Websites: WatKhemaraRatanaram.org or WatKhmers.org

បណ្ដោយតាម, ញាណជាអនុលោម, អនុលោមញ្ញាណ (សេចក្ដីដឹងមិនខុស) ។

**អនុលោមប្បដិលោមវស** បុំ. [ អនុលោមប្បដិលោម+វស ] អំណាចនៃញាណប្រព្រឹត្តបណ្ដោយតាម និងញាណប្រព្រឹត្តច្រាស, អំណាចនៃញាណជាអនុលោម និងបដិលោម (បណ្ដោយទៅនិងត្រឡប់មកវិញ) ។

**អនុលោមិក** គុ. [ អនុលោម+ណិក ] ប្រកបដោយអនុលោមញ្ញាណ, ដែលប្រព្រឹត្តក្នុងកិ.អនុលោម ។

**អនុវត្តាមិ** កិ. [ អនុ+វត, វត>វត្ត+អ, អ>អា+មិ_វ. ] រមែងប្រព្រឹត្តតាម, ប្រ-ព្រឹត្តរឿយៗ (បណ្ដោយតាម) ។

**អនុវាត** នបុំ. [ អនុ+វាត ] ទីបណ្ដោយនៃខ្យល់; វិ. **វាតស្ស អនុ> អនុ-វាតំ** ។

**អនុវាតប្បដិវាត** នបុំ. [ អនុវាត+បដិវាត ] ទីបណ្ដោយនៃខ្យល់និងទីច្រាស់នៃខ្យល់; វិ. **វាតស្ស បដិ>បដិវាតំ; អនុវាតញ្ច បដិវាតញ្ច > អនុវាតប្បដិវាតំ** ។

**អនុវិច្ច** អ. [ អនុ+វិច+ត្វា, ត្វា>រច្ច, លុបទីបំផុតធាតុនិងរ ] ពិចារណារឿយៗហើយ, ត្រួតត្រាហើយ ។

**អនុវិចរន្ត** គុ. [ អនុ+វិ+ចរ+អ+អន្ត ] កាលត្រេចទៅតាម, កាលត្រេចទៅរឿយៗ, កាលត្រេចទៅតាមលំដាប់ ។

**អនុវិចរិត្វា** អ. [ អនុ+វិ+ចរ+ឥ_អា.+ត្វា ] ត្រេចទៅតាមហើយ, ដើរតាម

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ, ត្រេចទៅរឿយៗហើយ ។

**អនុវិចិន្តយំ** គុ. [ អនុ+វិ+ចិន្ត+ណយ+អន្ត+សិ.វិ., យក ន្ត+សិ.វិ.>អំ ] កាលតាមគិតផ្សេងៗ, កាលត្រិះរិះតាម, កាលគិតរឿយ ៗ ។

**អនុវិជ្ឈិត្វា** អ. [ អនុ+វិធ+យ+ឥ.អា.+ត្វា, ផ្លាស់ធ+យ>ជ្ឈ ] ចាក់ធ្លុះតាមហើយ, តាមចាក់ហើយ, ចាក់រឿយៗហើយ ។

**អនុវិលោកេត្វា** អ. [ អនុ+វិ+លុក+ណេ+ត្វា ] តាមក្រឡេកមើលហើយ, តាមងាកមើលហើយ, ក្រឡេកមើលរឿយៗហើយ ។

**អនុសន្ធិ** ឥ. [ អនុ+សន្ធិ ] កិ.តភ្ជាប់ជាលំដាប់, កិ.តតាមលំដាប់, វាចាជាគ្រឿងតតាមលំដាប់ ។

**អនុសយ** បុំ. [ អនុ+សី+ណ ឬអ ] កិលេសជាគ្រឿងដេកនៅរឿយៗ; វិ. **អនុសេតិ ឯតេនាតិ> អនុសយោ** ។ កិលេសតែងដេកនៅរឿយៗក្នុងសន្តាន; វិ. **សន្តានេ អនុសេតីតិ > អនុសយោ** ។

**អនុសយានុក្កមសហិត** គុ. [ អនុសយ+អនុក្កម+សហិត ] ប្រព្រឹត្តទៅមួយអន្លើដោយធម៌ដែលឈានទៅតាមនៃកិលេសជាទីដេកនៅរឿយៗ, ប្រកបដោយធម៌ជាលំដាប់នៃអនុសយក្កិលេស (**សហិត**< សហ+ឥ+ត) ។

**អនុសំវច្ឆរ** បុំ., នបុំ. [ អនុ+សំវច្ឆរ ] ឆ្នាំជាលំដាប់, កាលជាលំដាប់នៃឆ្នាំ (រាល់ៗឆ្នាំ) ។

**អនុសាយិក** គុ. [ អនុ+សី+ណី+ក.ស.] រោគតែងដេកនៅរឿយៗ, ដែល

Websites: WatKhemaraRatanaram.org or WatKhmers.org

ដេកនៅរឿយៗ (រោគរឹងរៃ); វិ. អនុ សេតីតិ> អនុសាយី, អនុសាយី ឯវ> អនុសាយិកោ ។

អនុសាសក ពុំ. [ អនុ+សាស+ណ្វុ ] អ្នកប្រៀនប្រដៅតាម, អ្នកតាមប្រៀនប្រដៅ, អ្នកប្រដៅរឿយៗ; វិ. អនុសាសតីតិ > អនុសាសកោ ។

អនុសាសន្ត គុ. [ អនុ+សាស+អ+អន្ត ] កាលប្រៀនប្រដៅរឿយៗ ។

អនុសាសតិ កិ.[ អនុ+សាស+អ+តិ_វ.] រមែងប្រៀនប្រដៅរឿយៗ ។

អនុសាសនីសវនតា ឥ. [ អនុសាសនីសវន+តា ] ភាវៈនៃកិ.ស្តាប់នូវវាចាជាគ្រឿងប្រៀនប្រដៅរឿយៗ; វិ. អនុសាសតិ ឯតាយាតិ > អនុសាសនី , អនុសាសនិយា សវនំ> អនុសាសនីសវនំ , អនុសាសនីសវនស្ស ភាវោ> អនុសាសនីសវនតា ។

អនុសាសមាន គុ.[ អនុ+សាស+អ+មាន ] កាលប្រៀនប្រដៅរឿយៗ ។

អនុសាសិតព្វ គុ. [ អនុ+សាស+ឥ_អា.+តព្វ ] គឺ...គប្បីប្រៀនប្រដៅរឿយៗ ។

អនុសាសិត្វា អ. [ អនុ+សាស+ឥ_អា.+ត្វា ] ប្រៀនប្រដៅរឿយៗហើយ, ផ្ដែផ្ដាំហើយ ។

អនុសាសិតុកាម គុ. [ អនុសាសិតុំ+កាម ] អ្នកចង់ដើម្បីប្រៀនប្រដៅរឿយៗ, មានប្រាថ្នាដើម្បីប្រៀនប្រដៅរឿយៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុសាសិយមាន** គុ. [ អនុ+សាស+ឥ_អា.+យ+មាន ] គឺ...កាលប្រៀនប្រដៅរឿយៗ, កាលប្រៀនប្រដៅតាម ឬតាមប្រៀនប្រដៅ ។

**អនុសិក្ខន្ត** គុ. [ អនុ+សិក្ខ+អ+អន្ត ] កាលសិក្សាតាម, កាលតាមសិក្សា, កាលរៀនរឿយៗ, កាលហាត់រឿយៗ ។

**អនុសិដ្ឋិ** ឥ. [ អនុ+សាស+តិ, តិ>ដ្ឋិ, លុបទីបំផុតធាតុ, ផ្លាស់អានៃសាជាឥ ] សេចក្ដីប្រៀនប្រដៅតាម, សេចក្ដីប្រៀនប្រដៅរឿយៗ ឬវាចាជាគ្រឿងប្រៀនប្រដៅរឿយៗ; វិ. **អនុសាសនំ> អនុសិដ្ឋិ, អនុសាសតិ ឯតាយាតិ ចា> អនុសិដ្ឋិ** ។

**អនុសោចតិ** កិ. [ អនុ+សុច+អ+តិ_វ. ] រមែងសោកតាម, រមែងសោករឿយៗ, រមែងសោកស្ដាយ ។

**អនុសោចន្ត** គុ. [ អនុ+សុច+អ+អន្ត ] កាលសោកស្ដាយ, ... ។

**អនុស្សរិត** គុ. [ អនុ+សរ+ឥ_អា.+ត ] គឺ...រឭករឿយៗហើយ ។

**អនុស្សុទ** គុ. [ ន+ឧស្សុទ ] មិនខ្ពស់ឡើង, មិនប៉ោងឡើង, មិនមែនហើមឡើង, មិនដុះឡើង, មិនក្រាស់ ។

**អនុស្សរណ** នបុំ. [ អនុ+សរ+យុ ] សេចក្ដីរឭករឿយៗ, កិ.នឹករឿយៗ ។

. **កាលេ** បុំ. កាលជាទីរឭករឿយៗ, កាលជាទីនឹកឃើញ ។

**អនុស្សរតិ** កិ. [ អនុ+សរ+អ+តិ_វ.] រមែងរលឹករឿយៗ, រមែងនឹករឿយៗ, នឹកឃើញ ។

**អនុស្សរន្តី** គុ. [ អនុ+សរ+អ+អន្ត+ឦ ] កាលរឭករឿយៗ, កាលតាមនឹក, កាលនឹកឃើញ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនុស្សវន្ត** គុ. [ អនុ+សរ+អ+អន្ត ] កាលរឭករឿយៗ, កាលតាមនឹក ។

**អនុស្សរិត្វា** អ. [ អនុ+សរ+ឥ_អា.+ត្វា ] រឭករឿយៗហើយ, រឭកតាមហើយ, នឹកឃើញហើយ ។

**អនុស្សរិតានុស្សរិតកាល** ចុំ. [ អនុស្សរិតានុស្សរិត+កាល ] កាលនៃ... គឺ ... រឭករឿយៗហើយ រឭករឿយៗហើយ, ... ។

**អនុស្សវាទិ** គ. [ អនុស្សវ+អាទិ ] (កិច្ច) មានកិ.ស្តាប់តមកជាដើម, មានកិ.ឮតាមលំដាប់មកជាដើម (អនុស្សវ<អនុ+សុ+ណ, ឧនៃសុ>ឱ>អវ); វិ. **អនុស្សវចនំ> អនុស្សវោ, អនុស្សវោ អាទិ យស្ស តំ> អនុស្សវាទិ** ។

**អនុស្សាវេសិ** កិ. [ អនុ+សុ+ណេ+ស_អា.+ត្យ-អជ្ជ.] ញ៉ាំង...ឱ្យស្តាប់តាមហើយ, ញ៉ាំងឱ្យឮរឿយៗហើយ ។

**អនុស្សុក្ក** គុ. [ ន+ឧស្សុក្ក ] អ្នកមិនមានសេចក្តីខ្វល់ខ្វាយ; វិ. **នត្ថិ ឧស្សុក្កំ ឯតស្សាតិ> អនុស្សុក្កោ** ។

**អនូបឃាត** ចុំ. [ ន+ឧប+ហន, ហន>ឃាត+អ ] កិ.មិនចូលទៅបៀតបៀន ។

**អនូបវាទ** ចុំ. [ ន+ឧប+វទ+ណ ] កិ.មិនតិះដៀល ។

**អនូហត** គុ. [ ន+ឧ+ហន+ត ] គឺបុគ្គលដកឡើងមិនបានហើយ, គឺ...មិនដកឡើងហើយ, គឺ...មិនទាន់កំចាត់បង់ហើយ ។

**អនេក** គុ. [ ន+ឯក>អនេក ] មិនមែនមួយ, មិនមែនតែមួយ (ច្រើន) ។

**-កោដិសំខ្យា** ឥ. គឺបុគ្គលរាប់ដោយកោដិមិនមែនមួយ ។ **-ជាតិ-**

Websites: WatKhemaraRatanaram.org or WatKhmers.org

**សតសហស្សសំខ្យា** ន. គឺ...រាប់ដោយសែននៃជាតិមិនតែមួយ ។ - **ជាតិសង្សារ** ចុំ. សង្សារមានជាតិមិនតែមួយ ។ - **បរិយាយ** ចុំ. សេចក្ដីបរិយាយមិនតែមួយ ។ - **ប្បការ** ចុំ. ប្រការមិនតែមួយ; គុ. មានប្រការមិនតែមួយ ។ - **ប្បភេទ** គុ. មានប្រភេទមិនតែមួយ ។ - **ផល** គុ. មានផលមិនតែមួយ ។ - **ព្យញ្ជន** គុ. មានព្យញ្ជនៈមិនតែមួយ ។ - **ព្រាហ្មណមហាសាល** ចុំ. ព្រាហ្មណ៍មហាសាល ឬ ព្រាហ្មណ៍ជាមហាសាលមិនតែមួយ ។ - **វណ្ណទេវបុត្ត** ចុំ. ទេវបុត្តឈ្មោះអនេកវណ្ណ, ទេវបុត្តមានវណ្ណៈ (សម្បុរ) មិនតែមួយ ។ - **វស្សកោដិសន្និចិត** គុ. គឺ...សន្សំព្រមហើយអស់កោដិនៃឆ្នាំ មិនតែមួយ (សន្និចិត <សំ+និ+ចិ+ត) ។ - **វិហិត** គុ. មានប្រការៈ (មានបែប) មិនតែមួយ ។ - **វិធ** គុ. មានប្រការៈមិនតែមួយ ។ - **សតសហស្ស** គុ. មានសែនមិនតែមួយ ។ - **សតក្ខត្តុំ** និ. ឬ គិ.វិ. វារៈនៃរយមិនតែមួយ, វារៈមានរយមិនតែមួយ ។ - **សហស្សវដ្តក** ចុំ. ចាបមានពាន់ដ៏ច្រើន ។ - **សូប-ព្យញ្ជនវិកតិ** គុ. មានសម្លទឹកនិងសម្លគោកដ៏ប្លែកច្រើនមុខ, មានស្លបះនិងព្យញ្ជនៈគឺបុគ្គលធ្វើឱ្យវិសេសដ៏ច្រើនមុខ; ន. កិ.ធ្វើប្លែកនៃស្លបះនិងព្យញ្ជនៈមិនតែមួយមុខ (**សូប** នចុំ. សម្ល ឬសម្លទឹក, ម្ហូបទឹក; **ព្យញ្ជន** នចុំ. សម្លគោក, ម្ហូបគោក, ម្ហូបក្រៀម) ។

**អនេជ** គុ. [ ន+ឯជ+ណ ] ដែលមិនញាប់ញ័រ ។

**អនេញ** គុ. [ ន+ឯញ ] អកមានកិលេសជាគ្រឿងញាប់ញ័រមិនមាន, អកមិន

Websites: WatKhemaraRatanaram.org or WatKhmers.org

មានកិលេសជាគ្រឿងញាប់ញ័រ; វិ. ឥញ្ជតិ ឯតេនាតិ> ឥញ្ជោ, នត្ថិ ឥញ្ជោ អស្សាតិ> អនេញ្ជោ (ឥញ្ជ<៨ជ ឬ ឥញ្ជ+ណ) ។ . វិហារសមាបត្តិធម្មបរិភោគ ចុំ. កិ.បរិភោគនូវសមាបត្តិធមិ (នូវធមិដែលប្រកបដោយសមាបត្តិ) ជាទីនៅនៃបុគ្គលអ្នកមិនមានកិលេសជាគ្រឿងញាប់ញ័រ ។

**អនេសន,-នា** នចុំ., ឥ. [ន+ឥស+យុ] កិ.ស្វែងរកមិនគួរ, សេចក្ដីប្រាថ្នាមិនគួរ, កិ.ចង់បានមិនគួរ; វិ. អយុត្តំ ឯសនំ> អនេសនំ, អយុត្តា ខា ឯសនា> អនេសនា ។

**អនោក** នចុំ. [ន+ឱក] កិ.មិនមាននៃទីជាទីនៅ; វិ. ឱកស្ស អភាវោ > អនោកំ ; តុ. (និព្វាន) មានអាល័យមិនមាន; វិ. នត្ថិ ឱកំ ឯតស្សាតិ> អនោកំ ។

**អនោកាសទិវស** ចុំ., នចុំ. [អនោកាស+ទិវស] ថ្ងៃនៃ...មានឱកាសមិនមាន, ថ្ងៃមានឱកាសមិនមាន, ថ្ងៃមិនមានទំនេរ; វិ. នត្ថិ ឱកាសោ ឯតស្សាតិ > អនោកាសោ ។

**អនោកាស** ចុំ., តុ. [ន+ឱកាស] មិនមែនជាឱកាស, មិនមានឱកាស (មិនទំនេរ) ។

**អនោកចារី** ចុំ. [អនោក+ចរ+ណី] អ្នកមានអាល័យមិនមានត្រេចទៅ, អ្នកត្រេចទៅដោយមិនមានអាល័យ ឬដោយកិ.មិនមាននៃទីជាទីនៅ ។ ចូរមើល «អនិកេតចារី» ។

**អនោក្កមន** តុ. [ន+អវ+កម+អ+អន] កាលមិនឈានចុះ, កាលមិនចុះស៊ប់។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អនោជ** បុំ. ននោង ។ - **បុប្ផចង្កោដក** បុំ. ប្រអប់ សម្រាប់ដាក់នូវផ្កាននោង, ប្រអប់ដ៏ពេញដោយផ្កាននោង ។ - **បុប្ផវណ្ណ** គុ. មានពណ៌ដូចជាផ្កានៃននោង ។

**អនោជាទេវី** ឥ. ទេវីឈ្មោះអនោជា ។

**អនោតត្ត** បុំ. [ ន+អវ+តប+ត ] ស្រះជាទីមិនក្តៅព្រោះមិនមាននៃកំដៅតែរស្មីនៃព្រះអាទិត្យពាល់ត្រូវហើយ (ស្រះឈ្មោះអនោតត្ត; វិ. **សុរិយ-រស្មិសម្ផស្សាភាវេន ន អវតប្បតិ ឧទកមេត្ថាតិ> អនោតត្តោ** ។ - **ទហបិដ្ឋ** នបុំ. ខ្នងនៃស្រះឈ្មោះអនោតត្ត ។ - **ទហ** បុំ. ស្រះឈ្មោះអនោតត្ត ។

**អនោតរន្ត** គុ. [ ន+អវ+តរ+អ+អន្ត ] កាលមិនឆ្លងចុះ, កាលមិនចុះឆ្លង, កាលមិនស្លុងទៅ ។

**អនោទក** គុ. [ ន+ឧទក ] មានទឹកមិនមាន, នបុំ. កិ.មិនមាននៃទឹក (ឥតទឹក) ។

**អនោនត** គុ. [ ន+អវ+នម+ត ] គឺ...មិនឱនចុះហើយ, មិនបន្ទន់ចុះហើយ, មិនទ្រោមចុះហើយ ។

**អនោបម** គុ. [ ន+ឧបមា ] មានឧបមាមិនមាន, មិនមានសេចក្តីប្រៀប; វិ. **នត្ថិ ឧបមា ឯតស្សាតិ> អនោបមា** ។

**អនោម** គុ. [ ន+ឱម ] មិនថោកទាប, មិនថយថោក ។ - **គុណត្ត** នបុំ. ភាវៈនៃ...ជាអ្នកមានគុណមិនថោកទាប ។ - **គុណី** គុ. អ្នកមានគុណ

Websites: WatKhemaraRatanaram.org or WatKhmers.org

មិនថោកទាប ។ - ត្ថេរ ពុំ. ព្រះថេរៈឈ្មោះអនោម ។ - ទស្សី ពុំ. ព្រះពុទ្ធទ្រង់ព្រះនាមអនោមទស្សី ។ - បញ្ញ គុ. អ្នកមានប្រាជ្ញាមិនថោកទាប, អ្នកមានប្រាជ្ញាមិនតិច ។

**អនោមានទីតីរ** នពុំ. [ អនោមានទី+តីរ ] ឆ្នេរ (ត្រើយ) នៃស្ទឹងឈ្មោះអនោមា ។

**អនោរមិត្វា** អ.[ ន+អវ+រម+ឥ_អា.+ត្វា ] មិនវៀរហើយ, មិនបន្ធូរបន្ថយហើយ ។

**អនោលោកេត្វា** អ. [ ន+អវ+លោក+អ, អ>ឯ+ត្វា ] មិនក្រឡេកមើលហើយ, មិនរមិលមើលហើយ ។

**អនោវស្សកដ្ឋាន** នពុំ.[ អនោវស្សក+ឋាន ] ទីមានភ្លៀងធ្លាក់ចុះមិនមាន, ទីមិនមានភ្លៀងបង្អុរចុះ (ទីនៃសម្បាបផ្ទះ) ។

**អនោសក្កិត្វា** អ. [ ន+អវ+សក+យ, យ>ក+ឥ_អា.+ត្វា ] មិនរោយរៀវហើយ, មិនថយហើយ ។

**អនោសជ្ជិត្វា** អ.[ ន+អវ+សជ+យ, យ>ជ+ឥ_អា.+ត្វា ] មិនលះបង់ហើយ, មិនបណ្ដោយហើយ ។

**អនោសាទេត្វា** អ. [ ន+អវ+សទ+ណេ+ត្វា ] មិនញ៉ាំង...ឱ្យត្រេកអរហើយ, -ឱ្យត្រេកអរសប់ហើយ, -ឱ្យចូលចិត្តហើយ ។

**អនោសីទិត្វា** អ. [ន+អវ+សទ, សទ>សីទ+ឥ_អា.+ត្វា] មិនលិចចុះហើយ ។

**អន្ន** នពុំ. [ អស ឬអទ+ត ] វត្ថុតីបុគ្គលគប្បីស៊ី (បាយ, ចំណី); វិ. អសិតព្វន្តិ > អន្នំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អន្វឌ្ឍមាស** បុំ. [ អនុ+អឌ្ឍមាស ] កន្លះនៃខែជាលំដាប់, កាលដ៏កន្លះនៃខែជាលំដាប់; វិ. **មាសស្ស អឌ្ឍោ> អឌ្ឍមាសោ , អនុ អឌ្ឍមាសោ> អន្វឌ្ឍមាសោ** ។

**អន្វាគន្ត្វាន** អ. [ អនុ+អា+គម+ត្វាន ] មកតាមហើយ, តាមមកហើយ ។

**អន្វាយ** អ. [ អនុ+ឥ, ឥ>ឯ អយ+ត្វា, លុបត្វា ] ប្រព្រឹត្តទៅតាមហើយ, អាស្រ័យហើយ ។

**អន្វាសត្តតា** ឥ. [ អន្វាសត្ត+តា ] ភាវៈនៃ...ជា...ជាប់តាមហើយ (អន្វាសត្ត <អនុ+អា+សជ+ត) ។

**អន្វេតិ** កិ. [ អនុ+ឥ+អ+តិ.វ. ] រមែងទៅតាម, រមែងតាមទៅ, អន្ទោលតាម ។

**អន្វេសំ** គុ. [ អនុ+ឥស+អន្ត+សិ.វិ., ផ្លាស់ន្ត+សិ.វិ.>អំ ] កាលតាមស្វែងរក, កាលស្វែងរករឿយៗ, កាលស្វែងរកដោយលំដាប់ ។

**អន្តកិរិយា** ឥ. [ អន្ត+ករ+រិយ+អា.ឥ. ] កិ.ធ្វើនូវទីបំផុត, កិ.ធ្វើនូវព្រះនិព្វានជាទីបំផុត ។

**អន្តក** បុំ. [ អន្ត+ករ+វ. ] សភាវៈធ្វើនូវទីបំផុត ឬសភាវៈធ្វើនូវទីបំផុត គឺសេចក្តីវិនាស (មច្ចុ); វិ. **អន្តំ ករោតីតិ> អន្តកោ , អន្តំ វិនាសំ ករោតីតិ វា> អន្តកោ** ។

**អន្តមសោ** និ. [ អន្តម+នា.វិ. ] ដោយកំណត់មានក្នុងទីបំផុត, ដោយហោចទៅ; វិ. **អន្តេ ភវោ បរិច្ឆេទោ> អន្តមោ** ។

**អន្តរឃរ** នបុំ. [ អន្តរ+ឃរ ] ចន្លោះនៃផ្ទះ, រវាងនៃផ្ទះ, លំដាប់នៃផ្ទះ; វិ.

Websites: WatKhemaraRatanaram.org or WatKhmers.org

ឃរស្ស អន្តំ > អន្តរឃរំ ។

**អន្តរទ្វារ** នបុំ. [ អន្តរ+ទ្វារ ] ចន្លោះនៃទ្វារ...; វិ. **ទ្វារស្ស អន្តំ> អន្តរ-ទ្វារំ** ។

**អន្តរទីបក** នបុំ.[ អន្តរ+ទីបក ] ចន្លោះនៃកោះតូច, រវាងនៃកោះតូច, កោះតូចមានក្នុងចន្លោះ, កោះតូចជម្ងៃ ។

**អន្តរធាន** នបុំ. [ អន្តរ+ធា+យុ ] សេចក្ដីអន្តរធាន, កិ.បាត់ទៅ, កិ.សូន្យទៅ, មន្តជាគ្រឿងសូន្យទៅ ។

**អន្តរធាបេយ្យាម** កិ. [ អន្តរ+ធា+ណាបេ+ឯយ្យាម.ស.] គប្បីញុំាង...ឱ្យបាត់ទៅ, ឱ្យសូន្យទៅ, ឱ្យអន្តរធានទៅ ។

**អន្តរធាយមាន** គុ.[ អន្តរ+ធា+ណយ+មាន ] កាលបាត់ទៅ, កាលសូន្យទៅ, កាលអន្តរធានទៅ ។

**អន្តរន្តរ** នបុំ. [ អន្តរ+អន្តរ ] ចន្លោះនិងចន្លោះ, រវាងនិងរវាង, ទីជម្ងៃនិងជម្ងៃ ។

**អន្តរពាហិរ** គុ. [ អន្តរ+ពាហិរ ] ខាងក្នុងនិងខាងក្រៅ, ទាំងខាងក្នុងទាំងខាងក្រៅ, អវយវៈជាខាងក្នុងនិងអវយវៈជាខាងក្រៅ ។

**អន្តរវស្ស** នបុំ. [ អន្តរ+វស្ស] ចន្លោះនៃកាលភ្លៀង, ខាងក្នុងនៃកាលភ្លៀង, កាលភ្លៀងមានក្នុងចន្លោះ ។

**អន្តរវីថិ** ឥ. [ អន្តរ+វីថិ ] ចន្លោះនៃថ្នល់; វិ. **វីថិយា អន្តំ>អន្តរវីថិ** ។

**អន្តរសត្ថិ** ឥ. [ អន្តរ+សត្ថិ ] ចន្លោះនៃភ្លៅ, ខាងក្នុងនៃដើមភ្លៅ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អន្តលិក្ខ** នបុំ. [ អន្តរ+ឥក្ខ+អ, រ>ល ] (ទីឬប្រទេស) សម្រាប់ឃើញនូវភាវៈនៃវត្ថុផ្សេងៗក្នុងចន្លោះនៃលោក (អាកាស); វិ. **ចក្ខុនមន្តរេ នានត្តំ ឥក្ខតេ លោកោ ឯតេនាតិ> អន្តលិក្ខំ** ។

**អន្តរហិត** គុ. [ អន្តរ+ធា+ត, ផ្លាស់ធនៃធា>ហ, អា>ឥ ] តាំងនៅក្នុងទីដទៃហើយ, បាត់ទៅហើយ, អន្តរធានហើយ, សូន្យទៅហើយ ។

**អន្តរាបណ** នបុំ. [ អន្តរ+អាបណ ] ចន្លោះនៃផ្សារ, ចន្លោះនៃរានផ្សារ ។

**អន្តរាភត្ត** នបុំ. [ អន្តរា+ភត្ត ] ចន្លោះនៃភត្ត, រវាងនៃភត្ត ។

**អន្តរាមគ្គ** នបុំ. [ អន្តរា+មគ្គ ] ចន្លោះនៃផ្លូវ, រវាងនៃផ្លូវ, កណ្ដាលនៃផ្លូវ ។

**អន្តរាវាស** បុំ. [ អន្តរ+អាវាស ] កិ.នៅអាស្រ័យក្នុងចន្លោះ, ប្រទេសជាទីនៅអាស្រ័យក្នុងចន្លោះ, ចន្លោះនៃអាវាស ។

**អន្ត** បុំ. [ អម ឬអស+ត ] ទីបំផុត, ចំណែក, ជាយ, ចុង, ព្រំដែន, នបុំ. ពោះវៀនធំ, គុ. លាមក, ថោកទាប ។

**អន្តិម** គុ. [ អន្ត+ឥម ] មានក្នុងទីបំផុត, កើតក្នុងទីបំផុត, ប្រកបក្នុងទីបំផុត; (បើចង់វិគ្គហៈត្រូវប្រកបដោយស័ព្ទគឺ «ភវ, ជាត, និយុត្ត» ចូលមកផង) ។ **-សរីរ** គុ. អ្នកមានសរីរៈមានក្នុងទីបំផុត; វិ. **អន្តិមំ សរីរំ យស្ស សោ> អន្តិមសរីរោ** ។

**អន្តេបុរ** នបុំ. [ អន្តេ+បុរ ] ខាងក្នុងនៃបុរី (ខាងក្នុងនៃព្រះរាជវាំង) ។ **-បាលក** បុំ. អ្នករក្សានូវខាងក្នុងនៃបុរី, អ្នករក្សានូវបុរីក្នុងខាងក្នុង; វិ. **អន្តេបុរំ បាលេតីតិ> អន្តេបុរបាលកោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អន្តេវាសិក** ចុំ.[ អន្តេ+វស+ណី+ណិក.ស.] អ្នកមានកិ.នៅក្នុងទីជិតនៃអាចារ្យជាប្រក្រតី (សិស្ស); រឹ. **អាចរិយស្ស អន្តេ សមីបេ វសិតុំ សីលមស្សាតិ> អន្តេវាសី , អន្តេវាសី ឯវ> អន្តេវាសិកោ** ។ **-ត្ថេរ** ចុំ. ព្រះថេរៈជាអន្តេវាសិក ។ **-បរិសា** ឥ. បរិស័ទគឺអន្តេវាសិក, អន្តេវាសិកជាបរិស័ទ, បរិស័ទនៃអន្តេ-វាសិក ។ **-វាស** ចុំ. កិ.នៅជាអន្តេវាសិក, កិ.នៅដោយអំណាចនៃ... ជាអន្តេវាសិក ។

**អន្តោ** និ. ខាងក្នុង ។ **-អគ្គិ** ចុំ. ភ្លើងខាងក្នុង ។ **-អរុណោ** នចុំ. ខាងក្នុងនៃអរុណ ។ **-អាវដ្ដន** ចុំ. ខាងក្នុងនៃ ទីជាទីវិលមក, ខាងក្នុងនៃវង់មូល ។ **-កុច្ឆិ** ឥ. ខាងក្នុងនៃផ្ទៃ ។ **-គន្ធកុដិ** ឥ. ខាងក្នុងនៃគន្ធកុដិ។ **-គាម** នចុំ. ខាងក្នុងនៃស្រុក ។ **-គេហច្ឆទន** នចុំ. ដំបូលនៃផ្ទះឰដ៏ខាងក្នុង, ខាងក្នុងនៃដំបូលនៃ ផ្ទះ ។ **-គេហប្បវេសន** នចុំ. កិ.ចូលទៅកាន់ខាងក្នុងនៃផ្ទះ, កិ.ចូលទៅកាន់ផ្ទះឰដ៏ខាងក្នុង ។ **-គេហាភិមុខ** គុ. មានមុខឆ្ពោះទៅកាន់ខាងក្នុងនៃផ្ទះ ។ **-គេហ** នចុំ. ខាងក្នុងនៃផ្ទះ ។ **-ឃរ** នចុំ. ខាងក្នុងនៃផ្ទះ ។ **-ចីវរភោគ** នចុំ. ខាងក្នុងនៃផ្នត់នៃចីវរ ។ **-ឆទន** នចុំ. ខាងក្នុងនៃដំបូល, ខាងក្នុងនៃទីជាទីប្រក់ ។ **-ជាល** នចុំ. ខាងក្នុងនៃបណ្ដាញ (-មង, -សំណាញ់, អួន, លប់, បង្កាត់, បន្ទឹង) ។ **-ដ្ឋិតមនុស្ស** ចុំ. មនុស្សដែលស្ថិតនៅក្នុងខាងក្នុង ។ **-ទេវតា** ឥ. ទេវតាក្នុងខាងក្នុង ។ **-ធាតុនិធាន** នចុំ. ខាងក្នុងនៃចេតិយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាទីបញ្ចុះនូវព្រះធាតុ, ចេតិយជាទីបញ្ចុះនូវព្រះធាតុដ៏ខាងក្នុង ។ -**នគរាភិមុខ** គុ. មានមុខឆ្ពោះទៅកាន់ខាងក្នុងនៃនគរ ។ -**នគរ** ឧកុំ. ខាងក្នុងនៃនគរ, -នៃក្រុង ។ -**នទី** ឥ. ខាងក្នុងនៃស្ទឹង, -នៃទន្លេ ។ -**និវេសន** ឧកុំ. ខាងក្នុងនៃនិវេសន៍, ខាងក្នុងនៃទីជាទីនៅអាស្រ័យ, ខាងក្នុងនៃផ្ទះ ។ -**បោក្ខរណី** ឥ. ខាងក្នុងនៃស្រះបោក្ខរណី, ខាងក្នុងនៃស្រះមានឈូក ។ -**មហាសមុទ្ទ** ឧកុំ. ខាងក្នុងនៃសមុទ្រធំ ។ -**វស្សភាវ** បុំ. ភាវៈនៃកាលជាខាងក្នុងនៃរដូវភ្លៀង, ភាវៈនៃកាលជាខាងក្នុងនៃវស្សា ។ -**វស្ស** ឧកុំ. ខាងក្នុងនៃវស្សា ។ -**វិហារាភិមុខី** ឥ. មានមុខឆ្ពោះទៅកាន់ខាងក្នុងនៃវិហារ (វត្ត, កុដិ) ។ -**វិហារ** ឧកុំ. ខាងក្នុងនៃវិហារ ។ -**វីណា** ឥ. ខាងក្នុងនៃពិណ ។ -**សមាបត្តិ** ឥ. ខាងក្នុងនៃសមាបត្តិ ។ -**សាណិ** ឥ. ខាងក្នុងនៃរាំងនន, ខាងក្នុងនៃរនាំង ។

**អន្ធ** គុ. [ អន្ធ+អ ] ងងឹត, ខ្វាក់; វិ. **អន្ធតីតិ** > **អន្ធោ** ។ -**ពាល** គុ. ល្ងង់ដូចជាមនុស្សខ្វាក់; វិ. **អន្ធោ ឥវ ពាលោ**> **អន្ធពាលោ** ។ -**ភូត** គុ. មានងងឹតកើតហើយ ។

**អបកឌ្ឍន្ត** គុ. [ អប+កឌ្ឍ+អ+អន្ត ] កាលទាញទៅប្រាស, កាលកន្ត្រាក់ចេញ, កាលទាញចេញ ។

**អបកឌ្ឍិត្វា** អ. [ អប+កឌ្ឍ+ឥ_អា.+ត្វា ] ទាញទៅប្រាសហើយ, កន្ត្រាក់ចេញហើយ, ទាញចេញហើយ ។

**អបកឌ្ឍ** [illegible] [ អប+កឌ្ឍ ] [illegible] ប្រាសហើយ, វិ. [illegible]

Websites: WatKhemaraRatanaram.org or WatKhmers.org

ភគញ្ញូ យស្មា សោ> អបភគញ្ញូ ។ អ្នកដឹងនូវឧបការដែលអ្នកដទៃធ្វើទៅប្រាសហើយ; វិ. អបគតោ ភគញ្ញូ> អបភគញ្ញូ ។ អ្នកមិនដឹងនូវធម្មវិន័យដែលព្រះមានព្រះភាគធ្វើទូទៅហើយ; វិ. ឆបកំ (ធម្មវិនយំ) ជានាតីតិ> អបភគញ្ញូ ។

**អបក្កម្ម** អ. [ អប+កម+ត្វា ] ឈានទៅប្រាសហើយ, គេចចេញហើយ, ចៀសចេញទៅហើយ ។

**អបក្កមិ** កិ. [ អប+កម+អ+ឦ-អជ្ជ., ឦ-អជ្ជ>ឥ. ] ឈានទៅប្រាសហើយ, គេចចេញហើយ, ចៀសចេញទៅហើយ ។

**អបគច្ឆិ** កិ. [ អប+គម+អ+ឦ-អជ្ជ.] ទៅប្រាសហើយ, គេចចេញហើយ ។

**អបគញ្ឆិ** កិ. [ អប+គម+អ+ឦ-អជ្ជ., ចុះនិ-អា.] ទៅប្រាសហើយ, គេចចេញហើយ ។

**អបគត** គុ. [ អប+គម+ត ] ទៅប្រាសហើយ, ទៅបាត់ហើយ, គេចចេញហើយ, វាំងហើយ ។ - **ឱទ្យារិកក្កិលេស** គុ. មានកិលេសគ្រោតគ្រាតទៅប្រាសហើយ ។ - **កទ្ទម** គុ. មានភក់ទៅប្រាសហើយ ។ - **ក្កិលេសតា** ឥ. ភាវៈនៃ...ជាអ្នកមានកិលេសទៅប្រាសហើយ ។ - **វិញ្ញាណ** គុ. មានវិញ្ញាណទៅប្រាសហើយ ។

**អបគន្ត្វា** អ. [ អប+គម+ត្វា ] ទៅប្រាសហើយ, គេចចេញហើយ, ទៅបាត់ហើយ ។

**អបគមនកាល** ចុំ. [ អបគមន+កាល ] កាលជាទីទៅប្រាស, កាលជាទីចេញទៅ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អប្បច្ចក្កោសន នចុំ. [ ន+បតិ+អា+កុស+យុ ] កិ.មិនជេរតប, កិ.មិនជេរត។

អប្បច្ចវេក្ខិត្វា អ. [ ន+បតិ+អវ+ឥក្ខ+ឥ_អា.+ត្វា ] មិនឃើញចុះចំពោះហើយ, មិនពិចារណាហើយ ។

អបចាយមាន គុ. [ អប+ចិ+មាន ] កាលបូជា, កាលគោរព, កាលកោតក្រែង, កាលប្រព្រឹត្តកោតក្រែង, កាលឱនលំទោន ។

អប្បច្ចាវត្តន នចុំ. [ ន+បតិ+អា+វត្ត+យុ ] កិ.មិនត្រឡប់មក, កិ.មិនត្រឡប់មកវិញ ។

អប្បច្ចាសីសន្ត គុ. [ ន+បតិ+អា+សិស+អន្ត, ចុះនិ.អា ] កាលមិនប្រាថ្នា, កាលមិនប៉ុនប៉ង, កាលមិនចំណង ។

អបជិត គុ. [ អប+ជិ+ត ] ឈ្នះទៅប្រាសហើយ, មានកិ.ឈ្នះទៅប្រាសហើយ, ចាញ់ហើយ ។

អប្បញ្ញត្ត គុ. [ ន+ប+ញប+ត ] គឺ...មិនតែងតាំងហើយ, មិនបញ្ញត្តហើយ ។

អប្បញ្ញ គុ. [ ន+បញ្ញា ] មានប្រាជ្ញាមិនមាន, មិនមានប្រាជ្ញា; វិ. **នត្ថិ បញ្ញា ឯតស្សាតិ> អប្បញ្ញោ** ។

អប្បញ្ញាយមាន គុ. [ ន+ប+ញា+យ+មាន ] គឺ...កាលមិនដឹងទូទៅ, កាលមិនប្រាកដ ។

អប្បដិកុជ្ជិត្វា អ. [ ន+បដិ+កុជ-+ឥ_អា.+ត្វា ] មិនឃាត់ហើយ, មិនប្រកែកហើយ ។

អប្បដិច្ឆន្ន គុ. [ ន+បដិ+ឆទ+ត ] មិនកំបាំងហើយ, មិនបិទបាំងហើយ, គឺ...មិនបិទបាំងហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អប្បដិច្ឆាទន** នបុំ. [ ន+បដិ+ឆទ+យុ ] កិ.មិនបិទបាំង, -មិនទទួល ។

**អប្បដិច្ឆាទេត្វា** អ. [ ន+បដិ+ឆទ+ណេ+ត្វា ] មិនបិទបាំងហើយ, មិនញ៉ាំង...ឱ្យបិទបាំងហើយ, មិនទទួលហើយ, មិនគ្របហើយ ។

**អប្បដិបន្ន** តុ. [ ន+បដិ+បទ+ត ] មិនប្រតិបត្តិហើយ, មិនដើរទៅហើយ ។

**អបណ្ឌិត** តុ. [ ន+បណ្ឌិត ] មិនមែនជាបណ្ឌិត; វិ. **ន បណ្ឌិតោ> អបណ្ឌិតោ** ។

**អប្បណ្ណត្តិកភាវ** បុំ. [ អបណ្ណត្តិក+ភាវ ] ភាវៈនៃ...ជារបស់ដែលបុគ្គលដឹងទូទៅមិនមាន, -ជារបស់មានបញ្ញត្តិមិនមាន (ភាវៈនៃ...ជារបស់សាបសូន្យ); វិ. **បញ្ញាបិយតិ ញាយតីតិ> បញ្ញត្តិ, បញ្ញត្តិ ឯវ> បណ្ណត្តិ** ; (ផ្លាស់ញ្ញ >ណ្ណ), **នត្ថិ បណ្ណត្តិ ឯតស្សាតិ> អប្បណ្ណត្តិកោ, អប្បណ្ណត្តិកស្ស ភាវោ>អប្បណ្ណត្តិកភាវោ** ។

**អបត្តិក** តុ. [ ន+បត្តិក ] អ្នកមានធម្មជាតជាគ្រឿងដល់មិនមាន, អ្នកមានចំណែកជាគ្រឿងដល់មិនមាន, អ្នកមានចំណែកបុណ្យមិនមាន (មិនមែនអ្នកមានចំណែកបុណ្យ); វិ. **នត្ថិ បត្តិ ឯតស្សាតិ> អបត្តិកោ** ។

**អបតិត្វា** អ. [ ន+បត+ឥ_អា.+ត្វា ] មិនធ្លាក់ចុះហើយ, មិនដួលហើយ, មិនរលំហើយ ។

**អបត្ថិយ** តុ. [ ន+បត្ថ+ណ្យ+ឥ_អា.] គឺ...មិនគប្បីប្រាថ្នា; វិ. **ន បត្ថិតព្វន្តិ**

Websites: WatKhemaraRatanaram.org or WatKhmers.org

> **អបក្កិយំ** ។ ជាវេវចនៈនៃ **អបជ្ជិយំ** ។

**អបត្ថេត្វា** អ. [ ន+បត្ថ+ឯ+ត្វា ] មិនប្រាថ្នាហើយ, មិនចង់បានហើយ ។

**អបត្ថេន្ត** គុ. [ ន+បត្ថ+ឯ+អន្ត ] កាលមិនប្រាថ្នា, កាលមិនចង់បាន ។

**អបទ** គុ. [ ន+បទ ] មានស្នាមជើងមិនមាន, មិនមានស្នាមជើង ។

**អបទិសតិ** កិ. [ អប+ទិស+អ+តិ_វ.] សំដែងអាង, អាង, អះអាង ។

**អបទិសន្ត** គុ. [ អប+ទិស+អ+អន្ត ] កាលអាង, ... ។

**អបទិស** បុំ. [ អប+ទិស+អ ] សេចក្ដីអាង, កិ.អាង ។

**អបទិសិត្វា** អ. [ អប+ទិស+ឥ_អា.+ត្វា ] អាងហើយ, ... ។

**អបទេស** បុំ. [ អប+ទិស+ណ ] កិ.សម្ដែងអាង, សេចក្ដីអាង, សេចក្ដីអះអាង ។

**អបនីត** គុ. [ អប+នី+ត ] ត៏...នាំប្រាសហើយ, _នាំចេញហើយ, _ផ្លាស់ចេញហើយ ។

**អបនុទិត្វា** អ. [ ន+ប ឬអប+នុទ+ឥ_អា.+ត្វា ] មិនបន្ទោបង់ហើយ; មិនច្រានចេញហើយ ។

**អបនេត្វា** អ. [ អប+នី+ត្វា ] នាំប្រាសហើយ, ផ្លាស់ចេញហើយ, នាំចេញហើយ ។

**អបនេន្តិ** កិ. [ អប+នី+អ+អន្តិ_វ.] រមែងនាំប្រាស, ផ្លាស់ចេញ, នាំចេញ ។

**អប្បព្វជន្ត** គុ. [ ន+ប+វជ+អ+អន្ត ] កាលមិនបួស (កាលមិនវៀរ) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អបព្វជិត** គុ. [ ន+បព្វជិត ] មិនមែនជាបព្វជិត, មិនបួសហើយ ។ -**សទិស** គុ. ប្រាកដស្មើដោយបុគ្គលមិនបួសហើយ (ប្រហែលនឹងគ្រហស្ថ) ។

**អបព្យាម** គុ. [ អប+ព្យាម ] មានព្យាមទៅប្រាសហើយ, ដែលវៀរចាកទីមានព្យាមមួយជាប្រមាណ ។

**អបពោធេតិ** កិ. [ អប+ពុធ+ណេ+តិ.វ. ] កំចាត់បង់ (នាំចេញនូវកិ.ទ្រមក់) ។

**អបយិរុបាសន្ត** គុ. [ ន+បរិ+ឧប+អាស+អន្ត, ចុះយ.អា. ] កាលមិនអង្គុយជិត, កាលមិនចូលទៅអង្គុយជិត ។

**អបរក្ខរ** នចុំ ឬចុំ. [ អបរ+អក្ខរ ] អក្សរខាងចុង ។

**អបរជ្ឈតិ** កិ. [ អប+រធ+យ+តិ.វិ.] ប្រទូស្ត, បៀតបៀន ( ត្រេកអរប្រាស ) ។

**អបរជ្ឈន្ត** គុ. [ អប+រធ+យ+អ+អន្ត ] កាលប្រទូស្ត, កាលបៀតបៀន ។

**អបរជ្ឈនវស** ចុំ. [ អបរជ្ឈន+វស ] អំណាចនៃកិ.ប្រទូស្ត ។

**អបរទ្ធភាវ** ចុំ. [ អបរទ្ធ+ភាវ ] ភាវៈនៃ...ជាអ្នកប្រទូស្តហើយ, ជា...គឺ...ប្រទូស្តហើយ (**អបរទ្ធ**<អប+រធ+ត) ។

**អបរ** វិស.អ. ដទៃ, ដទៃទៀត, ផ្សេងទៀត; គុ. ខាងចុង, ខាងមុខ, ខាងនាយ ។ -**ភាគ** ចុំ. ចំណែកដទៃទៀត, កាលជាចំណែកដទៃទៀត, កាលជាចំណែកនៅខាងមុខ, កាលជាចំណែកនៅខាងនាយ ។

**អបរាជិត** គុ. [ ន+បរាជិត ] គឺ...មិនចាញ់ហើយ, ទារកឈ្មោះអបរាជិតៈ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

- គ្គហបតិ ពុំ. គហបតីឈ្មោះអបរាជិតៈ ។

**អបរាធ** ពុំ. [ អប+រធ+ណ ឬអប+រាធ ] សេចក្ដីខុស, កំហុស, ទោសៈ គុ. មានសេចក្ដីត្រេកអរទៅប្រាសហើយ; វិ. **អបគតោ រាគោ យស្មា សោ> អបរាគោ** ។ - **ការក** ពុំ. អ្នកធ្វើនូវកំហុស ។

**អបរាធានុរូប** គុ. [ អបរាធ+អនុរូប ] មានសភាពដ៏សមគួរដល់កំហុស ឬដល់ទោស ។

**អបរាបរំ** កិ.វិ. [ អបរ+អបរ ] ដទៃទៀតៗ, ដទៃទៀតនិងដទៃទៀត, ទៅៗ, មកៗ, ទៅមកៗ ។

**អបរាបរុប្បត្តិក** គុ. [ អបរាបរ+ឧប្បត្តិក ] មានកិ.កើតឡើងក្នុងកាលដទៃទៀតៗ, មានកិ.កើតឡើងតៗគ្នា ។

**អបរិច្ឆិន្ន** គុ. [ ន+បរិ+ឆិទ+ត ] គឺ...កំណត់មិនបានហើយ, .មិនកំណត់ហើយ ។

**អបរិច្ចជិត្វា** អ.[ ន+បរិ+ចជ+ឥ_អា.+ត្វា ] មិនលះបង់ហើយ, មិនលះស្រ-ឡះហើយ ។

**អបរិចិត** គុ. [ន+បរិ+ចិ+ត] មិនសន្សំជុំវិញហើយ, មិនស្និទ្ធស្នាលហើយ ។

- **មនុស្ស** ពុំ. មនុស្សអ្នកមិនស្និទ្ធស្នាល, មនុស្សអ្នកមិនជិតដិត ។

**អបរិញ្ញាតធម្ម** គុ. [ អបរិញ្ញាត+ធម្ម ] មានធម៌មិនកំណត់ដឹងហើយ ឬមិនទាន់កំណត់ដឹងហើយ (**អបរិញ្ញាត**<ន+បរិ+ញា+ត) ។

**អបរិបុណ្ណជ្ឈាសយ** គុ. [ អបរិបុណ្ណ+អជ្ឈាសយ ] មានអធ្យាស្រ័យមិន

Websites: WatKhemaraRatanaram.org or WatKhmers.org

បរិបូណ៌ហើយ ឬមិនគ្រប់គ្រាន់ហើយ (អបរិបុណ្ណ<ន+បរិ+បុរ+ត) ។

**អបរិបូរយមាន** គុ. [ ន+បរិ+បុរ+ណយ+មាន ] កាលមិនឱ្យពេញជុំវិញ, កាលមិនបំពេញ, កាលមិនញ៉ាំង...ឱ្យពេញគ្រប់គ្រាន់ ឬឱ្យពេញលេញ ។

**អបរិភាសន** នថុំ. [ ន+បរិ+ភាស+យុ ] កិ.មិនផ្ដាសា, កិ.មិនប្រទេច ឬមិនជេរ ។

**អបរិភុញ្ជិត្វា** អ. [ ន+បរិ+ភុជ ឬភុញ្ជ+ឥ.អា.+ត្វា ] មិនបរិភោគហើយ, មិនប្រើប្រាស់ហើយ ។

**អបរិភោគ** ថុំ. [ ន+បរិ+ភុជ+ណ ] កិ.មិនបរិភោគ, គុ.ជារបស់ដែលបុគ្គលប្រើប្រាស់មិនបាន, ឱ្យជារបស់ដែលបុគ្គលគប្បីប្រើប្រាស់មិនកើត ។

**អបរិមាណ** គុ. [ ន+បរិមាណ ] មានប្រមាណមិនមាន, មិនមានប្រមាណ, មានប្រមាណមិនបាន; វិ. **នត្ថិ បរិមាណំ ឯតស្សាតិ** > **អបរិមាណោ** ។ . **សីលក្ខន្ធគោបនធម្មានុធម្មប្បដិបត្តិបូរណាវស** ថុំ. អំណាចនៃកិ.គ្រប់គ្រងនូវសីលក្ខន្ធ (កងនៃសីល) មានប្រមាណមិនមាន និងកិ.បំពេញនូវសេចក្ដីប្រតិបត្តិនូវធម៌តាមធម៌ ឬដ៏សមគួរដល់ធម៌ ។ . **សីលក្ខន្ធគោបនាទិក** គុ. មានកិ.គ្រប់គ្រងនូវកងនៃសីលមានប្រមាណមិនមានជាដើម ។

**អបរិមុត្តត** នថុំ. [ អបរិមុត្ត+ត្ត ] ភាវៈនៃ...គឺ...មិនរួចស្រឡះហើយ ឬមិនផុតស្រឡះហើយ (អបរិមុត្ត<ន+បរិ+មុច+ត); វិ. **បរិមុច្ច-**

Websites: WatKhemaraRatanaram.org or WatKhmers.org

**យិត្ថាតិ> បរិមុត្តោ , ន បរិមុត្តោ>អបរិមុត្តោ , តស្ស ភាវោ> អបរិមុត្តត្តំ** ។

**អបរិយន្ត** គុ. [ ន+បរិយន្ត ] មានទីបំផុតជុំវិញមិនមាន, មិនមានទីបំផុតជុំវិញ; វិ. **នត្ថិ បរិយន្តោ ឯតស្សាតិ> អបរិយន្តំ** ។ **-គោចរ** គុ. មានគោចរមានទីបំផុតជុំវិញមិនមាន, មានអារម្មណ៍ជាទីត្រាច់ទៅនៃឥន្ទ្រិយមិនមានទីបំផុតជុំវិញ ។ **-តា** ឥ. ភាវៈនៃ...ជា...មានទីបំផុតជុំវិញមិនមាន ។ **-ភាវ** បុំ. ភាវៈនៃ...ជា...មិនមានទីបំផុតជុំវិញ ។

**អបរិយន្តីករ** គុ. [ អបរិយន្ត+ឦ.អា+ករ+អ ] ដែលធ្វើនូវកិលេសឱ្យជារបស់មានទីបំផុតជុំវិញមិនមាន, ធ្វើនូវសេចក្តីស្រឡាញ់មិនមានទីបំផុតជុំវិញ (ឦ.អាគមនេះចុះមកដើម្បីឱ្យងាយស្រួលដល់ការអានប៉ុណ្ណោះ) ។

**អបរិសុទ្ធ** គុ. [ ន+បរិ+សុធ+ត ] ដែលមិនបរិសុទ្ធ, មិនម៉ត់ចត់, មិនស្អាត ។

**អបលាយន្ត** គុ. [ ន+ប+ឥ ឬអយ, ចុះល.អា.+អន្ត ] កាលមិនរត់ទៅ, កាលមិនហើរទៅ, កាលមិនបោលទៅ ។

**អបលាយនត្ថ** បុំ. [ អបលាយន+អត្ថ ] ប្រយោជន៍ដល់កិ.មិនរត់ទៅ, ... ។

**អបលាយិត្វា** អ. [ ន+ប+ឥ ឬអយ, ចុះល.អា.+ឥ.អា.+ត្វា ] មិនរត់ទៅហើយ ។

**អបលិពុទ្ធ** គុ. [ ន+បរិ+ពុធ+ត, រនៃបរិ>ល ] មិនបៀតបៀនហើយ, មិនព័ទ្ធ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព័ទ្ធហើយ ។

**អបលោកិត** គុ. [ អប+លោក+ឥ_អា.+ត ] គឺ...លាហើយ, . ប្រកាសហើយ, . ប្រាប់ហើយ ។

**អបលោកេតព្វ** គុ. [ អប+លោក+អ, អ>ឯ+តព្វ ] គឺ...គប្បីលា ឬគប្បីប្រាប់ ។

**អបលោកេត្វា** អ. [ អប+លោក+អ, អ>ឯ+ត្វា ] លាហើយ, ប្រាប់ហើយ ។

**អបវិទ្ធ** គុ. [ អប+វិធ+ត ] គឺ...បោះចោលហើយ, . ប្រមៀលហើយ ។

**អបវិសិត្វា** អ. [ ន+ប+វិស+ឥ_អា.+ត្វា ] មិនចូលទៅហើយ, កុំចូលទៅឡើយ ។

**អបសក្កិត្វា** អ. [ អប+សក្ក+ឥ_អា.+ត្វា ] ថយទៅហើយ, គេចចេញហើយ ។

**អប្បសាទិត** គុ. [ ន+ប+សទ+ឥ_អា.+ត ] គឺ...មិនជ្រះថ្លាហើយ ឬមិនឱ្យជ្រះថ្លាហើយ ។

**អប្បសាទេត្វា** អ. [ ន+ប+សទ+ណេ+ត្វា ] មិនឱ្យជ្រះថ្លាហើយ ។

**អបស្សន្ត** គុ. [ ន+ទិស, ទិស>បស្ស+អន្ត ] កាលមិនឃើញ ។

**អបស្សនភាវ** ចុំ. [ អបស្សន+ភាវ ] ភាវៈនៃ (ឬគឺ) កិ.មិនឃើញ (អបស្សន<ន+ទិស, ទិស>បស្ស+យុ) ។

**អបស្សយ** ចុំ. [ អប+សី+អ ] ភ្នាក់ដៃ, គ្រឿងផ្អែក, បង្អែក ។

**អបស្សំ** គុ. [ ន+ទិស, ទិស>បស្ស+អន្ត+សិ_វិ., ផ្លាស់ន្ត+សិ វិ.>អំ ] កាលមិនឃើញ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អប្បហាជភាវ ថុំ. [ អបហាជ+ភាវ ] ភាវៈនៃ...គឺ...មិនប្រហារហើយ (អបហាជ<ន+ប+ហរ+ត) ។

អបហារតិ កិ. [ អប+ហរ+អ+តិ.វ.] រមែងនាំប្រាស, នាំចេញ, គេចចេញ ។

អបហារន្ត គុ. [ អប+ហរ+ ឬន+ប+ហរ+អ+អន្ត ] កាលនាំប្រាស, កាលមិនប្រហារ ។

អបហារិត គុ. [ អប+ហរិត ] មានវត្ថុខៀវទៅប្រាសហើយ, មានវត្ថុមានពណ៌ខៀវទៅប្រាសហើយ; វិ. អបគតំ ហរិតំ យស្មា តំ> អប. ហរិតំ ។

អប្បហិណន្ត គុ. [ ន+ប+ហិ+ណា+អន្ត ] កាលមិនបញ្ជូនទៅ, ... ។

អបាកដ គុ. [ ន+បាកដ ] មិនប្រាកដ, មិនល្បី (បាកដ<ប+កដ+អ; វិ. ធស្សនំ កដតិ គច្ឆតីតិ> បាកដោ =សភាវៈដល់នូវកិ. ឃើញ) ។

អបាកតិក គុ. [ ន+បាកតិក ] មិនតាំងនៅដោយប្រក្រតី; វិ. បកតិយា តិដ្ឋតីតិ> បាកតិកំ , ន បាកតិកំ> អបាកតិកំ ។

អបានុទិ កិ. [ អ+ប+អា+នុទ+អ+ឦ.អជ្ជ. ] បានបន្ទោបង់ហើយ ។

អបាបុណិត្វា អ. [ ន+ប+អាប+ឧណា+ឥ.អា.+ត្វា ] មិនដល់ហើយ, មិនទាន់ហើយ ។

អបារ នថុំ. [ ន+បារ ] មិនមែនត្រើយ, ទីមិនមែនជាត្រើយ ។

អបាយ ថុំ. [ អប+អាយ ] ភពមានសេចក្តីចំរើនទៅប្រាសហើយ (អបាយ);

Websites: WatKhemaraRatanaram.org or WatKhmers.org

វិ. អបគតោ អយោ យស្មា សោ> អបាយោ ។ - លោក ចុំ. លោកគឺអបាយ ។ - **គាមី** ចុំ. អ្នកទៅកាន់អបាយ; វិ. **អបាយំ គច្ឆតីតិ** > **អបាយគាមី** ។ - **ទុក្ខ** នចុំ. ទុក្ខក្នុងអបាយ ។ - **ទ្វារ** នចុំ. ទ្វារនៃអបាយ ។ - **បរាយន** គុ. មានអបាយជាទីប្រព្រឹត្តទៅក្នុងខាងមុខ (**បរាយន**<បរ+អយ ឬឥ+យុ) ។ - **សមុទ្ទ** ចុំ. សមុទ្រគឺអបាយ ។ - **សំវត្តនិកកម្ម** នចុំ. កម្មប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីអបាយ ។ - **សំវត្តនិក** គុ. ដែលប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីអបាយ ។ - **ឧបគ** គុ. ដែលចូលទៅដល់នូវអបាយ, កើតក្នុងអបាយ (**ឧបគ**<ឧប+គម+ក្វិ); វិ. **អបាយំ ឧបគច្ឆតីតិ** > **អបាយុបគោ** ។ - **ឧប្បត្តិ** ឥ. កិ.កើតក្នុងអបាយ ។

**អបិលន្ធិត្វា** អ. [ ន+បិលធ+ឥ_អា.+ត្វា ចុះនិ_អា. ] មិនប្រដាប់ហើយ, មិនតាក់តែងហើយ, មិនពាក់ហើយ ។

**អបិសុណវាចា** ឥ.[ អបិសុណ+វាចា ] វាចាមិនស៊ិកសៀត, វាចាមិនញុះញង់; គុ. មានវាចាមិនញុះញង់ (**អបិសុណ**<ន+បិសុ+ឧន, ឧន>ឧណ)។

**អបិវនត្ថ** ចុំ. [ អបិវន+អត្ថ ] ប្រយោជន៍ ឬត្រូវការដល់កិ.មិនផឹក (**អបិវន**<ន+បា>អបិវ+យុ) ។

**អបុច្ឆិត្វា** អ. [ ន+បុច្ឆ+ឥ_អា.+ត្វា ] មិនសួរហើយ ។

**អបុញ្ញតេជ** ចុំ.[ អបុញ្ញ+តេជ ] តេជះនៃបុគ្គលមិនមានបុណ្យ, តេជះនៃកម្ម

Websites: WatKhemaraRatanaram.org or WatKhmers.org

មិនមែនជាបុណ្យ ។

**អបុញ្ញលាភ** ពុំ. [ អបុញ្ញ+លាភ ] កិ.បាននូវកម្មមិនមែនជាបុណ្យ ។

**អបុញ្ញ** គុ. [ ន+បុញ្ញ ] មានបុណ្យមិនមាន, ឥតបុណ្យ; វិ. **នត្ថិ បុញ្ញំ ឯតស្សាតិ> អបុញ្ញោ;** កម្មមិនមែនជាបុណ្យ; វិ. **ន បុញ្ញំ> អបុញ្ញំ** ; កិ.មិនមាននៃបុណ្យ; វិ. **បុញ្ញស្ស អភាវោ> អ. បុញ្ញំ** ។

**អបុដ្ឋការណេ** នពុំ. [ អបុដ្ឋ+ការណេ ] ហេតុនៃ...គឺ...មិនសួរហើយ (**អបុដ្ឋ** <ន+បុច្ឆ+ត) ។

**អបុត្តក** គុ. [ ន+បុត្ត+ក ] មានកូនមិនមាន, មិនមានកូន, ឥតកូន; វិ. **នត្ថិ បុត្តោ ឯតស្សាតិ > អបុត្តកោ** ។ - **សេដ្ឋី** ពុំ. សេដ្ឋីមានកូនមិនមាន ។ - **សេដ្ឋីវត្ថុ** នពុំ. រឿងនៃសេដ្ឋីអ្នកមិនមានកូន ។ ឥ. **អបុត្តិកា** ។

**អបុថុជ្ជនសេវិត** គុ. [ អបុថុជ្ជន+សេវិត ] គឺព្រះអរិយៈមិនមែនជាបុថុជ្ជនសេពហើយ (**អបុថុជ្ជន**<ន+បុថុ+ជន+អ=មិនមែនអ្នកញ៉ាំងកិលេសក្រាស់ឱ្យកើត ឬមិនមែនអ្នកញ៉ាំងកិលេសឱ្យកើតក្រាស់; វិ. **បុថុ កិលេសេ ជនេតីតិ>បុថុជ្ជនោ , ន បុថុជ្ជនោ> អបុថុជ្ជនោ** ; (**សេវិត**>សេវ+ឥ.អា.+ត) ។

**អបុព្វ** គុ. [ ន+បុព្វ ] មិនមុន, មិនមែនជាខាងដើម ។

**អបូរេត្វា** អ. [ ន+បូរ+ណេ+ត្វា ] មិនញ៉ាំង... ឱ្យពេញហើយ, មិនបំពេញ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ ។

**អបេក្ខា** ឥ. [ អប+ឥក្ខ+ណ+អា_ឥ. ] កិ.សម្លឹងប្រាស, កិ.ពិនិត្យ, សេចក្តីអា- ឡោះអាល័យ; វិ. **អបេក្ខនំ> អបេក្ខា** ។

**អបេត** គុ. [ អប+ឥ+ត ] ទៅប្រាសហើយ, ប្រាសទៅហើយ, វៀរហើយ ។

**_កទ្ទម** គុ. មានភក់ទៅប្រាសហើយ, ដែលប្រាសចាកភក់ ។

**_វិញ្ញាណ** គុ. មានវិញ្ញាណទៅប្រាសហើយ, ដែលប្រាសចាកវិញ្ញាណ

**អបេតិ** កិ. [ អប+ឥ+អ+តិ_វ. ] រមែងទៅប្រាស, ប្រាសទៅ, ចៀសចេញ ទៅ, វៀរ ។

**អបេថ** កិ. [ អប+ឥ+អ+ថ_ប. ] ចូរទៅប្រាស, ចូរចៀសចេញ, ចូរវៀរ ។

**អប្បគ្ឃ** គុ. [ អប្ប+អគ្ឃ ] មានថ្លៃតិច, មានតម្លៃតិច (ថោក, ថ្លៃថោក) ។

**អប្បញ្ញត្ត** គុ. [ ន+ប+ញប+ត ] គឺ...មិនតាក់តែងហើយ, _ មិនតែងតាំង ហើយ, _ មិនក្រាលហើយ, _ មិនបញ្ញត្តហើយ ។

**អប្បញ្ញាយន** នបុំ. [ ន+ប+ញា, ផ្លាស់អាទៃញា>អាយ+យុ ] កិ.មិនដឹងទូ ទៅ, កិ.មិនប្រាកដ, កិ.មិនជាក់លាក់ ។

**អប្បប្បញ្ញ** គុ. [ អប្ប+បញ្ញា ] អ្នកមានប្រាជ្ញាតិច ។

**អប្បដិក្កុត្ត** គុ. [ ន+បដិ+កុឋ+ត ] គឺ...មិនហាមហើយ, _ មិនប្រកែកហើយ, _ មិនឃាត់ហើយ ។

**អប្បដិគ្គហណ** នបុំ. [ ន+បដិ+គហ+យុ ] កិ.មិនកាន់យកចំពោះ, កិ.មិន ទទួល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អប្បដិច្ឆន្ន** គុ. [ ន+បដិ+ឆទ+ត ] គឺបុគ្គលមិនបិទបាំងចំពោះហើយ, . មិនលាក់ទុកហើយ, មិនកំបាំងហើយ ។

**អប្បដិជគ្គិតាសន** នបុំ. [ អប្បដិជគ្គិត+អាសន ] អាសនៈដែល...មិនសំអាតហើយ, អាសនៈដែល...មិនជម្រះហើយ, . មិនថែទាំហើយ (អប្បដិជគ្គិត<ន+បដិ+ជគ្គ+ឥ.អា.+ត) ។

**អប្បដិជគ្គិយ** គុ. [ ន+បដិជគ្គិយ ] មិនមែនអ្នកគួរនូវកិ.ជម្រះ, មិនមែនអ្នកគួរនូវកិ.ថែទាំ, មិនគួរដល់នូវកិ.ថែទាំ; វិ. **បដិជគ្គនំ អរហតីតិ> បដិជគ្គិយោ , បដិជគ្គនស្ស អរហតីតិ វា> បដិជគ្គិយោ , ន បដិជគ្គិយោ> អប្បដិជគ្គិយោ** ; (ន+បដិ+ជគ្គ+ណ្យ+ឥ.អា.=គឺ...មិនគប្បីថែទាំ, .មិនគប្បីជម្រះ); វិ. **បដិជគ្គិតព្វន្តិ> បដិជគ្គិយំ , ន បដិជគ្គិយំ> អប្បដិជគ្គិយំ** ។

**អប្បដិនិស្សជ្ជ** អ. [ ន+បដិ+និ+សជ+ត្វា ] មិនលះបង់ហើយ (មិនសំដែងទោសហើយ, មិនឱ្យអត់ទោសហើយ, មិនសូមទោសហើយ) ។

**អប្បដិបុគ្គល** គុ. [ ន+បដិបុគ្គល ] មានបុគ្គលប្រៀបមិនមាន, មិនមានបុគ្គលប្រៀប; វិ. **នត្ថិ បដិបុគ្គលោ ឯតស្សាតិ> អប្បដិបុគ្គលោ** ។

**អប្បដិពទ្ធចិត្ត** គុ. [ អប្បដិពទ្ធ+ចិត្ត ] មានចិត្តមិនជាប់ចំពោះហើយ, មានចិត្តមិនប្រតិព័ទ្ធហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អប្បដិពាហិយភាវ** ចុំ. [ អប្បដិពាហិយ+ភាវ ] ភាវៈនៃ...ជា...គឺ...មិនគប្បី ឃាត់បាន, . មិនគប្បីហាមបាន, . មិនគប្បីការពារបាន ។

**អប្បដិភាគ** គុ. [ ន+បដិភាគ ] មានចំណែកប្រៀបមិនមាន, មិនមានចំណែកប្រៀប; វិ. នត្ថិ **បដិភាគោ អស្សាតិ> អប្បដិភាគោ** ។

**អប្បដិរូបសហាយ** ចុំ. [ អប្បដិរូប+សហាយ ] សំឡាញ់មានរូបប្រៀបមិនមាន, សំឡាញ់មិនសមគួរ (**អប្បដិរូប**<ន+បដិរូប; វិ. **នត្ថិ បដិរូបំ ឯកស្សាតិ> អប្បដិរូបោ**) ។

**អប្បដិវិជ្ឈនកមោហ** ចុំ.[ អប្បដិវិជ្ឈនក+មោហ ] មោហៈដែលញ៉ាំង...មិនឱ្យចាក់ធ្លុះចំពោះ, មោហៈជាហេតុមិនឱ្យចាក់ធ្លុះចំពោះ, មោហៈជាហេតុមិនឱ្យត្រាស់ដឹង ។

**អប្បដិវិជ្ឈន្ត** គុ. [ ន+បដិ+វិធ+យ+អន្ត, ផ្លាស់ធ+យ>ជ្ឈ ] កាលមិនចាក់ធ្លុះចំពោះ, កាលមិនត្រាស់ដឹង ។

**អប្បដិវិជ្ឈិត្វា** អ. [ ន+បដិ+វិធ+យ+ឥ.អា.+ត្វា ] មិនចាក់ធ្លុះចំពោះហើយ, មិនត្រាស់ដឹងហើយ ។

**អប្បដិវេក្ខិយ** អ. [ ន+បដិ+អវ+ឥក្ខ+ឥ.អា.+ត្វា ] មិនឃើញចុះចំពោះហើយ, មិនពិចារណាហើយ ។

**អប្បដិសម** គុ. [ ន+បដិសម ] មានបុគ្គលស្មើប្រៀបមិនមាន, មិនមានបុគ្គលប្រៀបស្មើ; វិ. នត្ថិ **បដិសមោ ឯកស្សាតិ> អប្បដិ-សមោ** ។

**អប្បដិហតចិត្ត** គុ.[ អប្បដិហត+ចិត្ត ] មានចិត្តគឺទោសមិនបៀតបៀនចំពោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ, - មិនខ្លាំងខ្ជប់ហើយ (**អប្បដិហត**<ន+បដិ+ហន+ត); វិ. **អប្បដិហតំ ចិត្តំ យស្ស សោ> អប្បដិហតចិត្តោ** ។

**អប្បដិហតញ្ញាណប្បវេទិត** គុ. [ អប្បដិហតញ្ញាណ+បវេទិត ] ទាំងមានញាណគឺមោសជាតមិនខ្លាំងខ្ជប់ហើយ ទាំងដឹងច្បាស់ហើយ ឬដឹងទូទៅហើយ (**បវេទិត**<ប+វិទ+ឥ_អា.+ត) ។

**អប្បដិហតពុទ្ធិ** គុ.[ អប្បដិហត+ពុទ្ធិ ] មានប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺ...មិនបៀតបៀនចំពោះហើយ, មានប្រាជ្ញាគឺ...មិនខ្លាំងខ្ជប់ហើយ ។

**អប្បដិប្បហារណ** បុំ. [ ន+បដិ+ប+ហរ+យុ ] កិ.មិនប្រហារតប, កិ.មិនវាយតប ។

**អប្បណិហិត** គុ. [ ន+ប+និ, និ>ណ+ធា+ត, ផ្លាស់ធនៃធា>ហ, អា>ឥ ] មិនមានធម្មជាតជាគ្រឿងដំកល់, មិនមានទីជាទីដំកល់; វិមោក្ខឈ្មោះអប្បណិហិតៈ ។

**អប្បតរមូល** គុ. [ អប្បតរ+មូល ] មានមូលតិចជាង, មានតម្លៃតិចជាង ។

**អប្បតិដ្ឋិត** គុ. [ ន+បតិ+ឋា, អានៃឋា>ឥ+ត ] មិនតាំងនៅចំពោះហើយ, មិនដំកល់ស៊ប់ហើយ ។

**អប្បត្ត** គុ. [ ន+បទ+ត ] មិនដល់ហើយ, មិនទាន់ដល់ហើយ ។ **- មានស** គុ. មានសេចក្ដីប្រាថ្នាក្នុងចិត្តមិនទាន់ដល់ហើយ, មានចិត្តមិនទាន់ដល់ហើយ, មានព្រះអរហត្តជាគ្រឿងកំចាត់បង់នូវមានះមិនទាន់ដល់ហើយ ។ **- វិសេស** គុ. មានគុណវិសេសមិនទាន់ដល់ហើយ ។

**អប្បត្វា** អ. [ ន+បទ+ត្វា ] មិនដល់ហើយ, មិនទាន់ដល់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អប្បត្ត** គុ. [ ន+បត្ត+អ ] គឺបុគ្គលមិនប្រាថ្នាហើយ, គឺ...ចោលហើយ ។

**អប្បទុដ្ឋ** គុ. [ ន+ប+ទុស+ត ] គឺ...មិនប្រទូស្តហើយ, គឺទោសមិនប្រទូស្តហើយ, មិនប្រទូស្តហើយ ។

**អប្បនាសមាធិ** បុំ. [ អប្បនា+សមាធិ ] សមាធិជាគ្រឿងចូលទៅអែបនែបក្នុងអារម្មណ៍; វិ. **អារម្មណេ អប្បេតិ បវិសតិ ឯកាយាតិ>អប្បនា** ។ សមាធិប្រព្រឹត្តទៅក្នុងអប្បនា; វិ. **អប្បនាយំ បវត្តោ សមាធិ > អប្បនាសមាធិ**; (អប្បនា <អប+យុ+អា_ឥ.) ។

**អប្បពុទ្ធិក** គុ. [ អប្ប+ពុទ្ធិ+ក ] មានប្រាជ្ញាតិច; វិ. **អប្បា ពុទ្ធិ យស្ស សោ> អប្បពុទ្ធិកោ** ។

**អប្បភិក្ខុកត្ត** នបុំ. [ អប្បភិក្ខុក+ត្ត ] ភាវៈនៃ...ជា...មានភិក្ខុតិច; វិ. **អប្បា ភិក្ខូ យស្មិន្តិ> អប្បភិក្ខុកោ តស្ស ភាវោ> អប្ប-ភិក្ខុកត្តំ** ។

**អប្បមជ្ជតោ** គុ. [ ន+ប+មទ+យ+អន្ត+ស_វិ., ផ្លាស់ន្ត+ស_វិ.>តោ ] កាលមិនប្រមាទ, កាលមិនធ្វេសប្រហែស ។

**អប្បមញ្ញាភាវនា** ឥ. [ អប្បមញ្ញា+ភាវនា ] ភាវនាប្រព្រឹត្តទៅក្នុងព្រហ្មវិហារឈ្មោះអប្បមញ្ញា, ភាវនាមានភាវៈនៃសត្វមិនមានប្រមាណជាអា-រម្មណ៍ ។

**អប្បមត្តក** គុ. [ អប្ប+មត្ត+ក ] មានប្រមាណតិច, មានចំនួនតិច; វិ. **អប្បំ**

Websites: WatKhemaraRatanaram.org or WatKhmers.org

**មត្តំ យសស្ស កំ> អប្បមត្តកំ** ។ - **ដ្ឋានត្ថ** ចុំ. ប្រយោជន៍ដល់ទីមានប្រមាណតិច, សេចក្ដីត្រូវការដល់ដំណែងដ៏តូច ។ - **បរិច្ចាគា-នុភាវ** ចុំ. អានុភាពនៃកិ.បរិច្ចាគមានប្រមាណតិច ។ - **សេយ្យ** គុ. ជាគុណប្រសើរជាងមានប្រមាណតិច ។

**អប្បមត្ត** គុ. [ អប្ប+មត្ត ឬន+ប+មទ+ត ] មានប្រមាណតិច; អ្នកមិនប្រមាទ, អ្នកមិនធ្វេសប្រហែស ។ - **វិហារិតា** ឥ. ភាវៈនៃ...ជាអ្នកមានកិ.នៅដោយភាពជាអ្នកមិនធ្វេសប្រហែសជាប្រក្រតី, -នៅជាមួយនឹងបុគ្គលមិនប្រមាទជាប្រក្រតី ។

**អប្បមំសលោហិត** គុ. [ អប្ប+មំសលោហិត ] មានសាច់និងឈាមតិច ។

**អប្បមាណ** គុ.[ ន+បមាណ ] មិនជាប្រមាណ, មានប្រមាណមិនមាន, មិនមានប្រមាណ, កុំយកជាប្រមាណ (**បមាណ**<ប+មា+យុ) ។

**អប្បមាទ** ចុំ. [ ន+បមាទ ] កិ.មិនស្រវឹងទូទៅ, សេចក្ដីមិនប្រមាទ, សេចក្ដីមិនធ្វេសប្រហែស; វិ. **អប្បមជ្ជនំ>អប្បមាទោ** (**បមាទ**<ប+មទ+ណ) ។ - **ប្បដិបទា** ឥ. ការប្រតិបត្តិដោយសេចក្ដីមិនប្រមាទ, សេចក្ដីប្រតិបត្តិដោយអំណាចនៃសេចក្ដីមិនប្រមាទ ។ - **មូលក** គុ. មានសេចក្ដីមិនប្រមាទជាមូល ឬជាឫស, មានសេចក្ដីមិនប្រមាទជាហេតុជាទីតាំង ។ - **រត** គុ. ត្រេកអរហើយក្នុងសេចក្ដីមិនប្រមាទ ។ - **លក្ខណ** នចុំ. លក្ខណៈនៃសេចក្ដីមិនប្រមាទ; គុ. មានសេចក្ដីមិនប្រមាទជាលក្ខណៈ ។ - **វគ្គវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវអប្បមាទវគ្គ ។ - **វិហារិនី** ឥ. មានកិ.នៅដោយ

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្តីមិនប្រមាទជាប្រក្រតី ។ - **វេគ** ពុំ. កំឡាំងនៃសេចក្តីមិនប្រមាទ ។ - **សមោសរណ** គុ. ជាទីប្រជុំក្នុងសេចក្តីមិនប្រមាទ, មានសេចក្តីមិនប្រមាទជាទីប្រជុំចុះ ។ - **សម្បន្ន** គុ. ដល់ព្រមហើយដោយសេចក្តីមិនប្រមាទ, មានសេចក្តីមិនប្រមាទដល់ព្រមហើយ ។ - **អាធិគត** គុ. ដែលដល់ហើយ ឬដល់ក្រៃលែងហើយដោយសេចក្តីមិនប្រមាទ (អធិគត<អធិ+គម+ត=លុះ, ត្រាស់ដឹង, បាន) ។

**អប្បរស** គុ. [ អប្ប+រស ] មានរសតិច, មានទឹកតិច ។

**អប្បលាភ** គុ. [ អប្ប+លាភ ] មានលាភតិច ។

**អប្បវត្តនភាវ** ពុំ. [ អប្បវត្តន+ភាវ ] ភាវៈនៃ (គឺ) កិ.មិនប្រព្រឹត្តទៅ ។

**អប្បវត្តន្ត** គុ. [ ន+ប+វត, វត>វត្ត+អ+អន្ត ] កាលមិនប្រព្រឹត្តទៅ ។

**អប្បវត្ត** គុ. [ ន+ប+វត+ត ] មិនប្រព្រឹត្តទៅហើយ ។

**អប្បវេស** ពុំ. [ ន+ប+វិស+ណ ] កិ.មិនចូលទៅ ។

**អប្បវិដ្ឋ** គុ. [ ន+ប+វិស+ត ] មិនចូលទៅហើយ, មិនចូលមកហើយ ។

**អប្បសត្ថ** គុ. [ អប្ប+សត្ថ ] មានពួកតិច, មានគ្នាតិច ។

**អប្បសន្ន** គុ. [ ន+ប+សទ+ត ] មិនជ្រះថ្លាហើយ, មិនថ្លា ។

**អប្បស្សាទ** គុ. [ អប្ប+អស្សាទ ] មានសេចក្តីត្រេកអរតិច, (អស្សាទ <អា>អ+សទ+ណ) ។

**អប្បស្សុតតា** ឥ. [ អប្បស្សុត+តា ] ភាវៈនៃ...ជាអ្នកមានកិ.ស្តាប់តិច, - ជា

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកមានពុទ្ធវចនៈតិចស្តាប់ហើយ; វិ. **អប្បំ សុតំ យស្ស ខោ យេន សោ> អប្បស្សុតោ, អប្បស្សុតស្ស ភាវោ> អប្បស្សុតតា ។**

**អប្បស្សុតបុរិស** ពុំ. [ អប្បស្សុត+បុរិស ] បុរសមានពុទ្ធវចនៈតិចស្តាប់ហើយ, បុរសមានកិ.ស្តាប់តិច ។

**អប្បហាយ** អ. [ ន+ប+ហា+ត្វា ] មិនលះបង់ហើយ ។

**អប្បហោន្ត** គុ. [ ន+ប+ហុ+អន្ត ] កាលមិនល្មម, កាលមិនគ្រប់គ្រាន់ ។

**អប្បាយុកសំវត្តនិក** គុ. [ អប្បាយុកសំវត្តន+ណិក ] ដែលប្រព្រឹត្តទៅព្រមដើម្បីជាអ្នកមានអាយុតិច, ប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីជនដែលមានអាយុតិច ។

**អប្បាយុក** គុ. [ អប្ប+អាយុ+ក ] មានអាយុតិច; វិ. **អប្បំ អាយុ យេ-សំ តេ> អប្បាយុកា ។**

**អប្បាហារតា** ឥ. [ អប្បាហារ+តា ] ភាវៈនៃ...ជាអ្នកមានអាហារតិច ។

**អប្បិច្ឆតា** ឥ. [ អប្បិច្ឆ+តា ] ភាវៈនៃ...អ្នកមានសេចក្តីប្រាថ្នាតិច; វិ. **អប្បា ឥច្ឆា យស្ស សោ> អប្បិច្ឆោ កស្ស ភាវោ> អប្បិច្ឆតា ។**

**អប្បិច្ឆតាទិ** គុ.[ អប្បិច្ឆតា+អាទិ ] មានភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចជាដើម; វិ. **អប្បិច្ឆតា អាទិ យស្ស សោ> អប្បិច្ឆ-តាទិ ។ . គុណាយុត្ត** គុ. ដែលប្រកបដោយគុណមានភាវៈនៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចជាដើម ។ - **ប្បុឌិសំយុត្ត** គុ. ដែលប្រកបព្រមចំពោះដោយគុណមានភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចជាដើម ។

**អប្បិច្ឆសន្តុដ្ឋភាវគុណ** ចុំ. [ អប្បិច្ឆសន្តុដ្ឋភាវ+គុណ ] គុណគឺភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច និងអ្នកត្រេកអរដោយវត្ថុជារបស់នៃខ្លួន (**សន្តុដ្ឋ** <សំ+តុស+ត=ត្រេកអរព្រម, សន្តោស) ។

**អប្បិយ** គុ. [ ន+បិយ ] មិនជាទីស្រឡាញ់ (មិនមែនជាអ្នកគឺបុគ្គលគប្បីស្រឡាញ់); វិ. **បិយោតិ គន្តិ**> **បិយោ** , **ន បិយោ**> **អប្បិយោ** ។

**អប្បេកទា** កា.ស. ក្នុងកាលខ្លះ, ក្នុងគ្រាខ្លះ, ក្នុងកាលម្តង១, ....។

**អប្បេវនាម** និ. ធ្វើម្តេចហ្ន, គិតដូចម្តេចហ្ន, ធ្វើម្តេចអេះ, ធ្វើយ៉ាងណាអេះ, .... ។

**អប្បេសក្ខ** គុ. [ អប្ប+សក្ខ ] មានស័ក្តិតិច, មានស័ក្តិតូច ។

**អប្ផោឋិតមត្ត** គុ. [ អប្ផោឋិត+មត្ត ] ត្រឹមតែទះដៃ, អាការគ្រាន់តែទះដៃ (**អប្ផោដិតមត្ត** ក៏មាន) ។

**អប្ផោឋេត្វា** អ. [ អា>អ+ផុឋ+ណេ+ត្វា ] ទះហើយ, ទះដៃហើយ (**អប្ផោដេត្វា** ក៏មាន) ។

**អប្ផោឋេសិ** កិ. [ អា+ផុឋ+ណេ+ឤ.អជ្ជ.+ស.អា. ] ទះហើយ, ទះដៃហើយ (**អប្ផោដេសិ** ក៏មាន) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អប្បោទក** គុ. [ អប្ប+ឧទក ] មានទឹកតិច ។ - **មធុបាយាស** ចុំ. បាយាសគឺបុគ្គលចំអិនហើយដោយទឹកឃ្មុំមានទឹកតិច, បាយាសដ៏លាយដោយទឹកឃ្មុំមានទឹកតិច, មធុបាយាសមានទឹកតិច ។

**អប្បោស្សុក្ក** គុ. [ អប្ប+ឧស្សុក្ក ] មានសេចក្ដីខ្វល់ខ្វាយតិច ។ - **តា** ឥ., - **ត្ត** នចុំ. ភាវៈនៃបុគ្គលអ្នកមានសេចក្ដីខ្វល់ខ្វាយតិច ។

**អផរុសវាចា** ឥ. [ អផរុស+វាចា ] វាចាមិនអាក្រក់, វាចាមិនទ្រគោះ ។

**អផល** គុ. [ ន+ផល ] មានផលមិនមាន, មិនមានផល, ឥតផល ។

**អផាសុក** នចុំ., គុ. [ ន+ផាសុក ] សេចក្ដីមិនសប្បាយ, សេចក្ដីអផ្សុក ។ - **កាល** ចុំ. ភាវៈនៃ.....មិនសប្បាយ, -មិនមានសេចក្ដីសប្បាយ ។

**អផុសិត** គុ. [ ន+ផុស+ឥ_អា.+ត ] គឺ....មិនពាល់ត្រូវហើយ ។

**អពធិរ** គុ. [ ន+ពធិរ ] មិនមែនថ្លង់, មិនថ្លង់ ។

**អពលទុព្វលអនទ្ធនិយតាវកាលិកត្ត** ចុំ. [ អពល_+អត្ត ] សេចក្ដីថាកាយជារបស់មិនមានកំឡាំងនិងជារបស់បានកំឡាំងថយនិងជារបស់មិនតាំងនៅអស់កាលដ៏វែងនិងជារបស់ប្រកបក្នុងកាលបុំណ្ណោះ; **អ-ពល**<ន+ពល=មានកំឡាំងមិនមាន; វិ. **នត្ថិ ពលំ អស្សាតិ**> **អពលោ**; **ទុព្វល**<ទុ+ពល=មានកំឡាំងគឺទោសប្រទូស្តហើយ (មានកំឡាំងខ្សោយ); វិ. **ទុដ្ឋំ ពលំ យស្ស សោ**> **ទុព្វលោ**; **អនទ្ធនិយ**<ន+អទ្ធនិយ=មិនតាំងនៅអស់កាលដ៏វែង ឬមិនគួរដល់សេចក្ដីមាំមួន; វិ. **អទ្ធានំ ខមតីតិ**> **អទ្ធនិយោ** , **អទ្ធស្ស**

Websites: WatKhemaraRatanaram.org or WatKhmers.org

អរហតិ ចា> អទ្ធនិយោ, ន អទ្ធយោ> អនទ្ធនិយោ; តាវកាលិក<តាវកាល+ណិក=ប្រកបក្នុងកាលប៉ុណ្ណោះ (ដូចជារបស់ខ្ចីគេ); វិ. តាវកាលេ និយុត្តោ > តាវកាលិកោ ។

**អពលស្ស** បុំ. [ អពល+អស្ស ] សេះមានកំឡាំងមិនមាន, សេះមិនមានកំឡាំង ។

**អពាធយិត្វា** អ. [ ន+ពាធ+ណយ+ឥ.អា.+ត្វា ] មិនបៀតបៀនហើយ ។

**អពុជ្ឈនក** បុំ. [ ន+ពុធ+យ+ណុ, ណុ>អនក ] អ្នកមិនត្រាស់ដឹង, អ្នកមិនភ្ញាក់; វិ. ពុជ្ឈតីតិ>ពុជ្ឈនកោ , ន ពុជ្ឈនកោ> អពុជ្ឈនកោ ។

**អព្យត្ត** គុ. [ ន+ព្យត្ត ] មិនឈ្លាស, មិនប្រសប់, មិនវាងវៃ ។ - **តា** ឥ. ភាវៈនៃ...ជាអ្នកមិនឈ្លាស, ... (ព្យត្ត<វិ>ព្យ+អជ+ត) ។

**អព្វណ** គុ. [ ន+វណ ] មានដំបៅមិនមាន, មិនមានដំបៅ ។

**អព្វត** គុ. [ ន+វត ] មានវត្តមិនមាន, មិនមានវត្ត ។

**អព្វហន** នបុំ. [ អា>អ+វហ+យុ ] កិ.ទាញចេញ, -ដកចេញ; ជាគ្រឿងទាញចេញ, - ដកចេញ ។

**អព្វុឡ្ហ** គុ. [ អា>អ+វហ, អនៃវ>ឧ+ត ] គឺ...ដកឡើងហើយ ។ - **សល្ល** គុ. មានសរដកឡើងហើយ ។

**អព្វុឡ្ហិ** កិ. [ អា+វហ, អនៃវ>ឧ+យ+ត្យ-អផ្ទ. ] ដកឡើងហើយ (ប្រើជា «អព្វុហិ» ក៏មាន) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អព្ភោកិណ្ណ** គុ. [ ន+វិ+អវ+កិរ+ត ] មិនរោយរាយចុះហើយ, មិនច្រឡូកច្រឡំហើយ ។

**អព្យាកត** គុ. [ ន+វិ+អា+ករ+ត ] គឺ...មិនធ្វើឱ្យជាក់ច្បាស់ហើយ, -មិនព្យាករហើយ, -មិនទាញហើយ (អព្យាក្រឹត) ។

**អព្យាបាទ** ចុំ. [ ន+ព្យាបាទ ] (ចេតសិកធម៌) មិនញុំាំងប្រយោជន៍និងសេចក្ដីសុខឱ្យវិនាស (គុ.មានព្យាបាទមិនមាន); វិ. **ហិតសុខំ ព្យាបាទយតីតិ> ព្យាបាទោ, ន ព្យាបាទោ> អព្យាបាទោ** ។ កិ.មិនមាននៃព្យាបាទ; វិ. **ព្យាបាទស្ស អភាវោ> អព្យាបាទោ** ។

**អព្រវិ** កិ. [ អ+ព្រូ, ឩនៃព្រូ>ឱ>អវ+អ+ឦ-អជ្ជ. ] បានពោលហើយ ។

**អព្ភក្ខាន** នចុំ. [ អភិ>អព្ភ+អា, អា>អ+ខា+យុ ] កិ.ពោលបង្កាច់ ។

**អព្ភញ្ញិត្វា** អ. [ អា>អ+ភជ ឬភញ្ជ+ឥ-អា.+ត្វា ] លាបហើយ, ស្រឡាបហើយ ។

**អព្ភន្តរ** គុ. [ អភិ+អន្តរ ] ខាងក្នុង ។

**អព្ភ** នចុំ. [ អវ+ភ ] ពពក, មេឃ, អាកាស ។

**អព្ភាកុដិក** គុ. [ ន+ភាកុដិក ] មិនមានក្រញូវមុខ, មិនមានខ្មួរមុខ; វិ. **នត្ថិ ភាកុដិកោ អស្សាតិ > អព្ភាកុដិកោ** ។

**អព្ភាចិក្ខនកភិក្ខុ** ចុំ. [ អព្ភាចិក្ខនក+ភិក្ខុ ] ភិក្ខុអ្នកពោលបង្កាច់, -និយាយបង្កាច់; វិ. **អព្ភាចិក្ខតីតិ> អព្ភាចិក្ខនកោ, អព្ភាចិក្ខនកោ**

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុ > អព្ភាចិក្ខនកភិក្ខុ ។

**អព្ភាចិក្ខន្តិ** កិ. [ អភិ+អា+ចិក្ខ+អ+អន្តិ_វ. ] ពោលបង្កាច់, ប្រាប់បង្កាច់ ។

**អព្ភាចិក្ខិត** គុ. [ អភិ+អា+ចិក្ខ+ឥ_អា.+ត ] គឺ...ពោលបង្កាច់ហើយ, _ប្រាប់បង្កាច់ហើយ ។

**អព្ភាទិមលវិរហិត** គុ. [ អព្ភាទិមល+វិរហិត ] ដែលប្រាសហើយ (ដែលវៀរហើយ) ចាកមន្ទិលមានពពកជាដើម ។

**អព្ភានុមោទន្ត** គុ. [ អភិ+អនុ+មុទ+អ+អន្ត ] កាលរីករាយតាមចំពោះ, កាលរីករាយតាមក្រៃលែង ។

**អព្ភុគ្គន្ទា** អ. [ អភិ+ឧ+គម+ត្វា ] ទៅក្នុងខាងលើហើយក្រៃពេក, ហោះឡើងហើយ, អណ្តែតឡើងហើយ, លឿនឈយទៅហើយ ។

**អព្ភុណ្ហ** គុ. [ អភិ+ឧណ្ហ ] ក្តៅក្រៃលែង, ក្តៅណាស់, ក្តៅពេក ។

**អព្ភូត** គុ. [ ន+ភូត ] មិនធ្លាប់កើតហើយ, មិនធ្លាប់មានហើយ, មិនពិត ។

**អព្ភោកាស** បុំ. [ អភិ+ឱកាស ] ឱកាសដ៏ក្រៃលែង, ទីវាលស្រឡះ ។

**អភណិ** កិ. [ អ+ភណ+អ+ឦ_អជ្ជ. ] បានពោលហើយ ។

**អភទ្ទក** គុ. [ ន+ភទ្ទក ] មានសេចក្តីចំរើនមិនមាន, មិនមានសេចក្តីចំរើន; វិ. នត្ថិ ភទ្ទោ ឯតស្សាតិ> អភទ្ទកោ ។

**អភព្វុប្បត្តិក** គុ. [ អភព្វ+ឧប្បត្តិ+ក ] មានកិ.កើតឡើងមិនគួរ, មានហេតុជាគ្រឿងកើតឡើងមិនគួរ; វិ. អភព្វា ឧប្បត្តិ យស្ស សោ> អភព្វុប្បត្តិកោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អភព្វ គុ. [ ន+ភព្វ ] មិនគួរ, អភ័ព្វ ។

អភយ គុ. [ ន+ភយ ] កិ.មិនមាននៃភ័យ; វិ. **ភយស្ស អភាវោ> អភយំ** ; មានសេចក្តីខ្លាចមិនមាន, មានភ័យមិនមាន; វិ. **នត្ថិ ភយំ ឯតស្សាតិ> អភយោ**; ហេតុគឺបុគ្គលមិនគប្បីខ្លាច; វិ. **ភយិតព្វន្តិ> ភយំ, ន ភយំ> អភយំ** ។ - **ទស្សី** ចុំ. អ្នកមានកិ.ឃើញនូវហេតុគឺបុគ្គលមិនគួរខ្លាចជាប្រក្រតី ។ - **ភីរុតា** ឥ. ភាវៈនៃ...ជាអ្នកខ្លាចអំពីវត្ថុដែលមិនគួរខ្លាច ។ - **រាជកុមារ** ចុំ. ព្រះរាជកុមារឈ្មោះអភ័យ ។

អភវិស្ស កិ. [ អ+ភូ+អ+ឥ.អា.+ស្សា.កា.[1] ] នឹងបានមានហើយ, នឹងបាន កើតហើយ ។

អភស្សិថ កិ. [ អ+ភស, ភស>ភស្ស+អ+ស្សថ.កា., លុបស្សនៅតែថ ] បានភ្លាត់ធ្លាក់ហើយ, បានរបូតចុះហើយ ។

អភាជេត្វា អ. [ ន+ភជ+ណេ+ត្វា ] មិនញុំាង...ឱ្យចែកហើយ, កុំអាលចែកឡើយ ។

អភាយន្ត គុ. [ ន+ភិ+អ+អន្ត ] កាលមិនខ្លាច ។

អភាវ ចុំ. [ ន+ភូ+ណ ] កិ.មិនមាន, កិ.មិនកើត; វិ. **ភវនំ> ភាវោ, ន ភាវោ> អភាវោ** ។ - **អត្ថ** ចុំ. សេចក្តីថាកិ.មិនមាន, កិ.មិនកើត ។

---

(១) ស្សា.កា.> ស្ស ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អភាវិត** គុ. [ ន+ភូ+ឥ+អា.+ត ] គឺ...មិនចំរើនហើយ, .មិនអប់រំហើយ ។

**អភាវេត្វា** អ. [ ន+ភូ+ណេ+ត្វា ] មិនញ៉ាំង...ឲ្យចំរើនហើយ, .ឲ្យមានហើយ, មិនចំរើនហើយ ។

**អភាសន្ត** គុ. [ ន+ភាស+អ+អន្ត ] កាលមិនពោល ។

**អភាសិ** កិ. [ អ+ភាស+អ+ឦ.អជ្ជ. ] បានពោលហើយ ។

**អភិកីរតិ** កិ. [ អភិ+កិរ+អ+តិ.វ. ] រមែងរាយមាយ, បាចសាច, ជន់លិច ។

**អភិក្កន្ត** គុ. [ អភិ+កម+ត ] ឈានទៅមុខហើយ, ប្រាថ្នាហើយ, ត្រេកអរហើយ, ល្អ,រុងរឿង, ពិរោះ, អស់ហើយ ។

**អភិក្កម** កិ. [ អភិ+កម+អ+ហិ.ប., លុបហិ ] ចូរឈានចំពោះ, ចូរឈានទៅមុខ, ចូរដើរទៅមុខ ។

**អភិក្កមិតុំ** គុ. [ អភិ+កម+ឥ.អា.+តុំ ] គឺ...ដើម្បីឈានចំពោះ, .គប្បីឈានទៅមុខ, .គប្បីដើរទៅមុខ ។

**អភិក្ខមថ** កិ. [ អភិ+ខម+អ+ថ.ប. ] ចូរអត់ចំពោះ, ចូរអត់សង្កត់ ។

**អភិគមិស្សសិ** កិ. [ អភិ+គម+អ+ឥ.អា.+ស្សសិ.ភ. ] នឹងដល់ចំពោះ, នឹងបាន ។

**អភិជានាតិ** កិ. [ អភិ+ញា, ញា>ជា+នា+តិ.វ. ] រមែងដឹងចំពោះ, ដឹងច្បាស់ ។

**អភិជានិត្វា** អ. [ អភិ+ញា+នា, អានៃនា>ឥ+ត្វា ] ដឹងចំពោះហើយ, ដឹងច្បាស់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អភិជ្ជិតា** អ. [ ន+ភិទ+យ+ឥ_អា.+តា ] មិនបែកហើយ, មិនទំលាយហើយ ។

**អភិជ្ឈាកាយគន្ថ** បុំ. [ អភិជ្ឈា+កាយគន្ថ ] កិលេសជាគ្រឿងដោតក្រងក្នុងកាយគឺអភិជ្ឈា, កិលេសជាគ្រឿងដោតក្រងប្រព្រឹត្តទៅក្នុងកាយគឺអភិជ្ឈា, កិលេសជាគ្រឿងដោតក្រងនូវនាមកាយនិងរូបកាយគឺអភិជ្ឈា ។

**អភិជ្ឈាទិ** គុ. [ អភិជ្ឈា+អាទិ ] (មនោទុច្ចរិត) មានអភិជ្ឈាជាដើម ។

**អភិញ្ញា** ឥ. [ អភិ+ញា+អ+អា_ឥ. ] ប្រាជ្ញាជាគ្រឿងដឹងចំពោះ, គុណជាតិគឺបុគ្គលគប្បីដឹងច្បាស់ ។ . **បរិញ្ញាបហានភាវនាសច្ឆិ-កិរិយាបារគូវស** បុំ. អំណាចនៃបុគ្គលអ្នកដល់នូវត្រើយគឺគុណជាតិនៃបុគ្គលគប្បីដឹងច្បាស់ និងគុណជាតិជាគ្រឿងកំណត់ដឹង និងគុណជាតិជាគ្រឿងលះបង់នូវទុក្ខ និងគុណជាតិជាគ្រឿងញ៉ាំងមគ្គឱ្យចំរើន និងគុណជាតិជាគ្រឿងធ្វើនូវនិព្វានឱ្យជាក់ច្បាស់; (**បរិញ្ញា**<បរិ+ញា+អ+អា_ឥ.; **បហាន**<ប+ហា+យុ; **ភាវនា**<ភូ, ឱ,នៃភូ>ឱ>អវ+យុ+អា_ឥ.; **សច្ឆិកិរិយា**<សច្ឆិ+ករ+រិយ+អា_ឥ.; **បារគូ**<បារ+គម+រូ) ។ . **បាទក** គុ. ជាជើងនៃអភិញ្ញា, ជាទីតាំងនៃអភិញ្ញា (ខ្លះថា មានអភិញ្ញាជាជើង, មានអភិញ្ញាជាទីតាំងប្រព្រឹត្តទៅ) ។ . **បារគាទិវស** បុំ. អំណាចនៃគុណជាតិមានគុណជាតិជាគ្រឿងដល់នូវត្រើយគឺអភិញ្ញាជាដើម ។

**អភិញ្ញាយ** អ. [ អភិ+ញា+ត្វា ] ដឹងចំពោះហើយ, ដឹងច្បាស់ហើយ ។

**អភិញ្ញេយ្យ** គុ. [ អភិ+ញា+តេយ្យ ] គឺបុគ្គលគប្បីដឹងចំពោះ, ធម្មជាតិគឺបុគ្គល

Websites: WatKhemaraRatanaram.org or WatKhmers.org

គប្បីដឹងដោយបញ្ញាដ៏ក្រៃលែង ។

**អភិញ្ញេយ្យាទិភេទ** គុ. [ អភិញ្ញេយ្យាទិ+ភេទ ] មានធម៌គឺបុគ្គលគប្បីដឹងច្បាស់ជាដើមជាប្រភេទ, ផ្សេងដោយធម៌មានធម៌គឺបុគ្គលគប្បីដឹងដោយប្រាជ្ញាដ៏ក្រៃលែងជាដើម; វិ. **អភិជានិតព្វោតិ> អភិញ្ញេយ្យោ , អភិញ្ញេយ្យា អាទិ យស្ស សោ> អភិញ្ញេយ្យាទិ , អភិញ្ញេយ្យាទិ ភេទោ យស្ស សោ> អភិញ្ញេយ្យាទិភេទោ** ។

**អភិណ្ហំ** កិ.វិ. រឿយៗ, ញយ ៗ ។

**អភិត្ថរេថ** កិ. [ អភិ+ថរ+អ+ឯថ_ស. ] គប្បីប្រញាប់ធ្វើ, គប្បីរួសរាន់ធ្វើ, គប្បីធ្វើរួសរាន់ ។

**អភិត្ថវន្ត** គុ. [ អភិ+ថុ, ឧនៃថុ>អវ+អន្ត(១) ] កាលសរសើរ, កាលស្ងើច ។

**អភិត្ថវមាន** គុ. [ អភិ+ថុ+មាន(២) ] កាលសរសើរ, កាលស្ងើច ។

**អភិត្ថវិ** កិ. [ អភិ+ថុ+អ+ឦ_អជ្ជ. ] សរសើរហើយ, ស្ងើចហើយ ។

**អភិត្ថវិត្វា** អ. [ អភិ+ថុ+ឥ_អា.+ត្វា ] សរសើរហើយ, ស្ងើចហើយ ។

**អភិត្ថុតគុណ** គុ. [ អភិត្ថុត+គុណ ] មានគុណគឺ...សរសើរហើយ ឬស្ងើចហើយ ។

**អភិទា** កិ. [ អ+ភិទ+អ+អា_ហី. ] បានបំបែកហើយ, បានទំលាយហើយ ។

**អភិធម្មកថា** ឥ. [ អភិធម្ម+កថ+អ+អា_ឥ. ] វាចាជាគ្រឿងសម្តែងនូវ

---

(១) (២) ចុះអ_បច្ច័យសម្រាប់ពួកធាតុអាខ្យាតមកផងក៏បាន ទេក៏បាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អភិធម្ម, វាចាជាគ្រឿងសម្ដែង (ប្រារព្ធ)នូវអភិធម្ម; វិ. អភិធម្មំ កថេតិ ឯតាយាតិ> អភិធម្មកថា ។

**អភិធម្មទេសនា** ឥ. [ អភិធម្ម+ទិស+យុ+អា_ឥ. ] វាចាជាគ្រឿងសម្ដែងនូវអភិធម្ម ។

**អភិធម្មបិដក** នថុំ. [ អភិធម្ម+បិដក ] អភិធម្មបិដក, បិដកគឺអភិធម្ម ។

**អភិធាវថ** ក. [ អភិ+ធាវ+អ+ថ.ប. ] ចូរលឿនទៅមុខ, ចូរស្ទុះទៅមុខ ។

**អភិនន្ទន្ត** គុ. [ អភិ+នន្ទ(១)+អន្ត ] កាលត្រេកអរចំពោះ, កាលត្រេកអរក្រៃលែង ។

**អភិនន្ទតិ** ក. [ អភិ+នន្ទ+អ+អន្តិ_វ. ] រមែងត្រេកអរចំពោះ, ត្រេកអរក្រៃលែង ។

**អភិនន្ទិត្វា** អ. [ អភិ+នន្ទ+ឥ_អា.+ត្វា ] ត្រេកអរចំពោះហើយ, ត្រេកអរក្រៃលែងហើយ ។

**អភិនវ** គុ. [ អភិ+នវ ] ថ្មីពេក, ថ្មីណាស់, ថ្មីស្រឡាង ។

**អភិនិក្ខមន** នថុំ. [ អភិ+និ+កម, កម>ខម+យុ ] កិ.ចេញទៅចំពោះ, កិ.ចេញទៅដើម្បីគុណដ៏ក្រៃលែង (កិ.ចេញបួស, អភិនិស្ក្រមន៍) ។

**អភិនិក្ខមន្ត** គុ.[ អភិ+និ+កម(២)+អន្ត ] កាលចេញទៅដើម្បីគុណដ៏ក្រៃលែង, (កាលចេញបួស) ។

**អភិនិព្វត្តិ** ឥ. [ អភិ+និ+បទ, ផ្លាស់ប>ព>ព្វ, ទ>ត+តិ ] កិ.កើតចំពោះ ។

---

(១) (២) ធ្មេះ បច្ច័យ សម្រាប់ពួកធាតុអាចឡុតឧកផងក៏បាន ទេក៏បាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អភិនិម្មិនិត្វា** អ. [ អភិ+និ+មា+នា+ត្វា; អានៃមា>ឥ, អានៃនា>ឥ ] និម្មិតចំពោះហើយ, តំណែងហើយ ។

**អភិនីហារ** ពុំ. [ អភិ+និ+ហរ+ណ ] អភិនីហារ, ធម៌ជាគ្រឿងនាំចេញដើម្បីគុណដ៏ក្រៃលែង (សេចក្ដីកសាង) ។ - **សម្បន្ន** គុ. អ្នកដល់ព្រមហើយដោយអភិនីហារ, អ្នកមានអភិនីហារដល់ព្រមហើយ ។

**អភិបត្ថយំ** គុ. [ អភិ+បត្ថ+ណយ+អន្ត+សិ.វិ.ផ្លាស់ន្ត+សិ.វិ>អំ ] កាលប្រាថ្នាចំពោះ ។

**អភិបត្ថិត** គុ. [ អភិ+បត្ថ+ឥ.អា.+ត ] គឺ...ប្រាថ្នាចំពោះហើយ ។

**អភិភវតិ** កិ. [ អភិ+ភូ+អ+តិ.វ. ] រមែងញាំញី, .គ្របសង្កត់ ។

**អភិភវនាទិក** គុ. [ អភិភវន+អាទិ+ក ] មានកិ.គ្របសង្កត់ជាដើម; វិ. អភិភវនំ អាទិ យស្ស តំ> អភិភវនាទិកំ ។

**អភិភវន្ត** គុ. [ អភិ+ភូ+អន្ត ] កាលញាំញី, កាលគ្របសង្កត់ ។

**អភិភវិ** កិ. [ អភិ+ភូ+អ+ឦ.អជ្ជ. ] ញាំញីហើយ, គ្របសង្កត់ហើយ ។

**អភិភវិត** គុ. [ អភិ+ភូ+ឥ.អា.+ត ] ញាំញីហើយ, គ្របសង្កត់ហើយ ។

**អភិភវិត្វា** អ. [ អភិ+ភូ+ឥ.អា.+ត្វា ] ញាំញីហើយ, គ្របសង្កត់ហើយ ។

**អភិភុយ្យ** អ. [ អភិ+ភូ+ត្វា ] គ្របសង្កត់ហើយ ។

**អភិភុយ្យមាន** គុ. [ អភិ+ភូ+យ+មាន ] គឺ...កាលគ្របសង្កត់ ។

**អភិភូត** គុ. [ អភិ+ភូ+ត ] គឺ...គ្របសង្កត់ហើយ, .រួបរឹតហើយ, .ជិះជាន់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អភិមង្គលសម្មត គុ. [ អភិមង្គល+សម្មត ] គឺ...ដឹងដោយល្អហើយថាជាមង្គលក្រៃពេក, . សន្មតហើយថាជាមង្គលដ៏ក្រៃលែង (សម្មត <សំ+មន+ត) ។

អភិមត្ថតិ កិ. [ អភិ+មថ+អ+តិ.វ. ] រមែងញាំញី ។

អភិមុខ គុ. [ អភិ+មុខ ] ទីចំពោះមុខ, ទីចំមុខ, ទីមានមុខចំពោះ, ឆ្ពោះមុខទៅ, បែរមុខទៅ, មានមុខតម្រង់ទៅ, មានមុខសំដៅទៅ ។

អភិយាចិត គុ. [ អភិ+យាច+ឥ.អា.+ត ] គឺ...អារាធនាហើយ, .សូមហើយ, .អង្វរហើយ, .អញ្ជើញហើយ ។

អភិយុញ្ជិតុកាម គុ. [ អភិយុញ្ជិតុំ+កម+ណ ] អ្នកចង់ដើម្បីច្បាំងចំពោះ; វិ. អភិយុញ្ជិតុំ កាមេតីតិ> អភិយុញ្ជិតុកាមោ ។

អភិរត គុ. [ អភិ+រម+ត ] ត្រេកអរចំពោះហើយ, ត្រេកអរស៊ប់ហើយ ។

អភិរតិ ឥ. [ អភិ+រម+តិ ] សេចក្ដីត្រេកអរចំពោះ, សេចក្ដីត្រេកអរក្រៃ-លែង ។

អភិរម កិ. [ អភិ+រម+អ+ហិ.ប., លុបហិ ] ចូរត្រេកអរចំពោះ ។

អភិរមតិ កិ. [ អភិ+រម+អ+តិ.វ. ] រមែងត្រេកអរចំពោះ ។

អភិរមិតុំ អ. [ អភិ+រម+ឥ.អា.+តុំ ] ដើម្បីត្រេកអរចំពោះ ។

អភិរមិត្វា អ. [ អភិ+រម+ឥ.អា.+ត្វា ] ត្រេកអរចំពោះហើយ ។

អភិរាធយេ កិ. [ អភិ+រធ+ណយ+ឯយ្យ.ស. លុប យ្យ ទុក ឯ ] គប្បីញុាំង...ឱ្យត្រេកអរចំពោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អភិរុចិត** គុ. [ អភិ+រុច+ឥ_អា.+ត ] ដែល...គាប់ចិត្តចំពោះហើយ ។

**អភិរុយ្ហ** អ. [ អភិ+រុហ+ត្វា ] ឡើងហើយ, ជិះហើយ ។

**អភិរុឡ្ហ** គុ. [ អភិ+រុហ+ត ] ឡើងហើយ, ចំរើនឡើងហើយ, ដុះឡើងហើយ ។

**អភិរូបតរ** គុ. [ អភិរូប+តរ ] មានរូបល្អជាង (មានរូបខ្ពង់ជាង) ។

**អភិរូបតា** ឥ. [ អភិរូប+តា ] ភាវៈនៃ...ជាអ្នកមានរូបល្អ; វិ. **អភិរូបស្ស ភាវោ> អភិរូបតា** ។

**អភិរុហតិ** កិ. [ អភិ+រុហ+អ+តិ_វ.] ឡើង, ចំរើនឡើង, ដុះឡើង, ជិះ ។

**អភិរុហតោ** គុ. [ អភិ+រុហ+អន្ត+ស_វិ., ផ្លាស់ន្ត+ស_វិ>តោ ] កាលឡើង, កាលដុះឡើង ។

**អភិរុហណ** នបុំ. [ អភិ+រុហ+យុ ] កិ.ឡើង, កិ.ដុះឡើង ។ - **អត្ថ** បុំ. ប្រយោជន៍ (ត្រូវការ) ដល់កិ.ឡើង, -ដុះឡើង ។ - **មគ្គ** បុំ. ផ្លូវជាទីឡើង ។

**អភិរុហន្តី** គុ. [ អភិ+រុហ+អន្ត+ឦ ] កាលឡើង, កាលដុះឡើង, កាលជិះ ។

**អភិរុហិ** កិ. [ អភិ+រុហ+អ+ឦ_អជ្ជ. ] ឡើងហើយ, ដុះឡើងហើយ, ជិះហើយ ។

**អភិរុហិតុំ** អ. [ អភិ+រុហ+ឥ_អា.+តុំ ] ដើម្បីឡើង, ដុះឡើង, ដើម្បីជិះ ។

**អភិរុហិត្វា** អ. [ អភិ+រុហ+ឥ_អា.+ត្វា ] ឡើងហើយ, ដុះឡើងហើយ, ជិះហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អភិវឌ្ឍតិ** កិ. [ អភិ+វឌ្ឍ+អ+តិ.វ. ] រមែងចំរើនក្រៃលែង ។

**អភិវឌ្ឍន** នបុំ. [ អភិវឌ្ឍ+យុ ] កិ.ចំរើនក្រៃលែង ។

**អភិវាទនសីលតា** ឥ. [ អភិវាទនសីល+តា ] ភាវៈនៃ...អ្នកមានកិ.អភិវាទន៍ជាប្រក្រតី, អ្នកមានកិ.ថ្វាយបង្គំជាប្រក្រតី; វិ. **អភិវាទនំ សីលំ យស្ស សោ> អភិវាទនសីលោ , អភិវាទនសីលស្ស ភាវោ> អភិវាទនសីលតា** ។

**អភិវាទនសីលី** បុំ. [ អភិវាទនសីល+ឦ ] អ្នកមានកិ.ថ្វាយបង្គំជាប្រក្រតី; វិ. **អភិវាទនសីលំ យស្ស អត្ថិ> អភិវាទនសីលី** ។

**អភិវាទន** នបុំ. [ អភិ+វន្ទ ឬវាទ+យុ, លុបន, ទីឃៈអនៃវ>អា ] កិ.ថ្វាយបង្គំ, កិ.សំពះ, កិ.អភិវាទន៍; វិ. **អភិវាទិយតេតិ> អភិវាទនំ** ។

**អភិវាទនាទិសក្ការករណដ្ឋាន** នបុំ. [ អភិ...ករណ+ឋាន ] ទីជាទីធ្វើនូវសក្ការៈមានកិ.ថ្វាយបង្គំជាដើម ។

**អភិវាទេត្វា** អ. [ អភិ+វន្ទ ឬវាទ+ណេ+ត្វា ] អភិវាទហើយ, ថ្វាយបង្គំហើយ, សំពះហើយ ។

**អភិវាទេន្តិ** កិ. [ អភិ+វន្ទ ឬវាទ+ណេ+អន្តិ.វ. ] រមែងអភិវាទ, ថ្វាយបង្គំ, សំពះ ។

**អភិវុដ្ឋ** គុ. [ អភិ+វស្ស+ត, ផ្លាស់អនៃវ>ឧ ] គឺភ្លៀងធ្លាក់ចុះហើយក្រៃពេក, គឺភ្លៀងបង្អុរចុះខ្លាំង ។

**អភិសក្ការ** បុំ. [ អភិ+សក្ការ ] សក្ការៈដ៏ក្រៃលែង, គ្រឿងសក្ការៈដ៏ល្អ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អភិសជ្ជេ** កិ. [ អភិ+សជ+យ+ឯយ្យ.ស., លុប យ្យ ទុក ឯ ] គប្បីជាប់នៅចំពោះ, គប្បីចាត់ចែង ។

**អភិសបិ** កិ. [ អភិ+សប+អ+ញ្ញ.អជ្ជ. ] ស្បថចំពោះហើយ, ដាក់សម្បថហើយ, ផ្តាសាហើយ ។

**អភិសបិត** គុ. [ អភិ+សប+ឥ.អា+ត ] ពី...ស្បថចំពោះហើយ, . ដាក់សម្បថហើយ, . ផ្តាសាហើយ ។

**អភិសបិត្វា** អ. [ អភិ+សប+ឥ.អា.+ត្វា ] ស្បថចំពោះហើយ, ដាក់សម្បថហើយ, ផ្តាសាហើយ ។

**អភិសបិត្ថ** កិ. [ អភិ+សប+អ+ឥ.អា.+ញ្ញ.អជ្ជ., ញ្ញ.អជ្ជ>ត្ថ ] ស្បថចំពោះហើយ, ដាក់សម្បថហើយ, ផ្តាសាហើយ ។

**អភិសមយ** ពុំ. [ អភិ+សំ+ឥ, ឥ>ឯ>អយ+ណ ] កិ.ប្រព្រឹត្តទៅព្រមចំពោះ, កិ.ដល់ព្រមហើយ, កិ.លុះ, កិ.បាន, កិ.ត្រាស់ដឹង ។

**អភិសមាចារិក** ពុំ. [ អភិសមាចារ+ណិក ] អ្នកប្រកបដោយអភិសមាចារៈ ឬអ្នកមានមារយាទល្អក្រៃលែង; វិ. **អភិសមាចារេន និយុត្តោ> អភិសមាចារិកោ , អភិសមាចារោ យស្ស អត្ថីតិ វា> អភិសមាចារិកោ;** (**អភិសមាចារ**>អភិ+សំ+អា+ចរ+ណ) ។

**អភិសមេច្ច** អ. [ អភិ+សំ+ឥ, ឥ>ឯ+ត្វា, ត្វា>រច្ច លុបរ ] ត្រាស់ដឹងហើយ, ពិចារណាហើយ (ដល់ព្រមចំពោះហើយ) ។

**អភិសម្បរាយ** ពុំ. [ អភិ+សំ+បរ+ឥ, ឥ>ឯ>អយ+ណ ] ភពគឺសត្វគប្បី

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់ព្រមចំពោះក្នុងខាងក្នុង, បរលោក ។

**អភិសម្ពុជ្ឈិត្វា** អ. [ អភិ+សំ+ពុធ+យ+ឥ_អា.+ត្វា ] ត្រាស់ដឹងព្រមចំពោះហើយ ។

**អភិសម្ពុធាន** គុ. [ អភិ+សំ+ពុធ+យុ ] អ្នកត្រាស់ដឹងព្រមចំពោះ ។

**អភិសង្ខត** គុ. [អភិ+សំ+ករ, ករ>ខរ+ត, លុបរ ] គឺ...តាក់តែងហើយ, -ប្រុងហើយ, -ផ្ដួសផ្ដុលហើយ ។

**អភិសង្ខរិត្វា** អ. [ អភិ+សំ+ករ, ករ>ខរ+ឥ_អា.+ត្វា ] តាក់តែងហើយ, ប្រុងហើយ, ផ្ដួសផ្ដុលហើយ ។

**អភិសង្ខរោតិ** កិ. [ អភិ+សំ+ករ, ករ>ខរ+ឱ+តិ_វ. ] តាក់តែង, ចាត់ចែង, ប្រុង, ផ្ដួសផ្ដុល ។

